**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royal de Droit et des Sciences Economiques**

**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# បទល្មើស និងការទទួលខុសត្រូវព្រហ្មទណ្ឌ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


ស្រាវជ្រាវដោយៈ

និស្សិតឈ្មោះ លោក **តៃ យិន**

**ម៉ី សុវណ្ណាវី**

សាស្ត្រាចារ្យណែនាំៈ

លោក **ជួន ម៉ុនធី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ឆ្នាំចូលសិក្សា ២០១៨

ជំនាន់ទី ២២

ឆ្នាំសរសេរសារណា ២០២២

# សេចក្ដីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំបាទ **តែ យិន** និង **ម៉ី សុវណ្ណាវី** ជានិស្សិតបរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចក្នុងឆ្នាសិក្សា ២០១៨-២០២២។

**សូមគោរពលំអោនកាយវាចាចិត្ត សម្ដែងនូវមហាកតញ្ញូតាធម៌ដឹងគុណយ៉ាងជាលជ្រៅបំផុតចំពោះ ៖**

| | | | |
|---|---|---|---|
| លោកឪពុក | **ហ៊ូវ តែ** | លោកឪពុក | **ម៉ី ឿង** |
| អ្នកម្ដាយ | **ពេជ្រ មុនីរ័ត្ន** | អ្នកម្ដាយ | **ហង់ មោនីង** |

ដែលបានផ្ដល់កំណើត និងខិតខំចិញ្ចឹមបីបាច់ថែរក្សាទូន្មានប្រៀនប្រដៅ និងផ្ដល់ដំបូន្មានល្អៗជួយជំរុញលើកទឹកចិត្តឱ្យកូនប្រឹងប្រែងខិតខំ យកចិត្តទុកដាក់ចំពោះការសិក្សា ជាពិសេសមុខវិជ្ជាដែលសង្គមយើងត្រូវការនាពេលបច្ចុប្បន្ននេះដល់កូនតាំងពីកូននៅតូចរហូតដល់ធំពេញវ័យ និងបានទទួលការបណ្ដុះបណ្ដាលតាំងពីថ្នាក់បឋមសិក្សារហូតឈានដល់កម្រិតថ្នាក់បរិញ្ញាបត្រនេះ។ លោកទាំងពីរបានប្រឹងប្រែងទាំងកម្លាំងកាយ និងកម្លាំងចិត្តជួយទំនុកបម្រុងគ្រប់បែបយ៉ាងទាំងបញ្ញា និងស្មារតីដើម្បីឱ្យកូនមានអនាគតភ្លឺស្វាង និងអភិវឌ្ឍខ្លួនក្លាយជាកូនល្អ សិស្សល្អ ពលរដ្ឋល្អនៅក្នុងសង្គមជាតិ។

ខ្ញុំបាទសូមថ្លែងអំណរគុណដល់ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកគ្រូ-អ្នកគ្រូ សាស្ត្រាចារ្យ** និង**បុគ្គលិកទាំងអស់** ដែលបានគ្រប់គ្រង ដឹកនាំ បង្ហាត់បង្ហាញ អប់រំណែនាំបង្រៀនទាំងផ្នែកទ្រឹស្ដី និងការអនុវត្តផ្ទាល់ ជាពិសេសផ្ដល់ដំបូន្មានល្អៗទាំងការរស់នៅក្នុងសង្គមឱ្យមានតម្លៃដល់យើងខ្ញុំ និងនិស្សិតគ្រប់រូប ប្រកបដោយបទពិសោធន៍ ការទទួលខុសត្រូវខ្ពស់ ក្នុងគោលដៅដើម្បីអភិវឌ្ឍធនធានមនុស្សសម្រាប់អនាគតប្រសើររបស់កម្ពុជា។ ជាមួយគ្នានេះដែរ យើងខ្ញុំសូមគោរពដឹងគុណ និងថ្លែងអំណរគុណពិសេសចំពោះលោកសាស្ត្រាចារ្យ **ជួន ម៉ុនធី** ដែលលោកបានខិតខំចំណាយពេលវេលាដ៏មានតម្លៃផ្ដល់នូវគំនិត ផ្ដល់នូវការណែនាំ គន្លឹះសិក្សាស្រាវជ្រាវ មតិយោបល់កែលម្អសំខាន់ៗក្នុងការកែសម្រួលកំហុសឆ្គងចំពោះការសរសេរសារណាបទរបស់ក្រុមយើងខ្ញុំកន្លងមករហូតសម្រេចបាននូវស្នាដៃមួយនេះឡើង។

ជាមួយគ្នានេះដែរ យើងខ្ញុំសូមអរគុណ និងដឹងគុណដល់បងប្អូន មិត្តភក្តិ មិត្តរួមថ្នាក់ទាំងអស់ដែលតែងលើកទឹកចិត្ត ផ្ដល់ជំនួយគ្រប់ផ្នែក ទាំងស្មារតី និងឯកសារពិគ្រោះនានាតាមគ្រប់មធ្យោបាយ និងលទ្ធភាព។ យើងខ្ញុំក៏សូមគោរពដឹងគុណយ៉ាងធំធេងដល់បុព្វបុរស ដូនតា ថ្នាក់ដឹកនាំគ្រប់ជំនាន់ ដែលបានធ្វើពលិកម្មដើម្បីប្រទេសជាតិ និងបន្សល់ទុកនូវមរតកប្រវត្តិសាស្ត្រយ៉ាងច្រើនដល់កូនចៅជំនាន់ក្រោយ ជាពិសេសថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់នាពេលបច្ចុប្បន្នដែលបានលះបង់ដើម្បីសុខសន្តិភាព និងផ្ដល់នូវការអភិវឌ្ឍន៍រីកចម្រើនឥតឈប់ឈរ។

# អារម្ភកថា

បន្ទាប់ពីបានសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ជំនាន់ទី ២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០១៨-២០២២ អស់រយៈពេល៤ឆ្នាំកន្លងមក ដោយសារការខិតខំប្រឹងប្រែងសិក្សារៀនសូត្រ និងការផ្ដល់ដំបូន្មានល្អៗពីសំណាក់លោក លោកស្រីសាស្ត្រានៅក្នុងសាកលវិទ្យាល័យបានធ្វើឱ្យយើងខ្ញុំទាំងពីររូបទទួលបានការអនុញ្ញាតពីសាកលវិទ្យាល័យក្នុងការសរសេរសារណាបទបញ្ចប់ការសិក្សាក្រោមប្រធានបទ " **បទល្មើស និងការទទួលខុសត្រូវព្រហ្មទណ្ឌ** "។

ក្រុមយើងខ្ញុំពិតជាមានសេចក្ដីសោមនស្សរីករាយណាស់ដែលបានសរសេរ និងរៀបរៀងសារណាបញ្ចប់ការសិក្សាមួយនេះ ដែលកើតចេញពីចម្ងល់ និងការចង់ចេះចង់ដឹងឱ្យកាន់តែស៊ីជម្រៅរបស់ក្រុមយើងខ្ញុំទៅលើផ្នែកបទល្មើសព្រហ្មទណ្ឌនៅកម្ពុជា។ សៀវភៅដែលក្រុមយើងខ្ញុំតាក់តែងនេះបានស្រាវជ្រាវ ប្រមូលផ្ដុំ និងចងក្រងនូវខ្លឹមសារ ដែលជាវិធានច្បាប់សម្រាប់ធ្វើការសិក្សាទៅលើផ្នែកទ្រឹស្ដី ព្រមទាំងឆ្លុះបញ្ចាំងពីការអនុវត្តជាក់ស្តែងរបស់ស្ថាប័នមានសមត្ថកិច្ចនានា។ ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌត្រូវបានបង្កើតជាឧបករណ៍គតិយុត្តមូលដ្ឋានមួយសម្រាប់ដំណើរការរឿងក្ដីព្រហ្មទណ្ឌ តុលាការព្រហ្មទណ្ឌ និងផ្ដល់ភាពយុត្តិធម៌ព្រហ្មទណ្ឌសម្រាប់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ដោយហេតុថាច្បាប់ព្រហ្មទណ្ឌនេះវាពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់កំណត់អំពីអត្ថិភាពនៃបទល្មើសនីមួយៗ។ លើសពីនេះទៀត សារណានេះអាចចេញជារូបរាងឡើងក៏ដោយសារមានការជួយជ្រោមជ្រែងណែនាំ តម្រង់ទិសពីសំណាក់សាស្ត្រាចារ្យ **ជួន ម៉ុនធី** ដែលលោកបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការចែករំលែកនូវចំណេះដឹង បទពិសោធន៍ និងដំបូន្មានល្អៗសម្រាប់ជាពុទ្ធិដល់យើងខ្ញុំ។

បើទោះបីជាយើងខ្ញុំបានធ្វើការពិនិត្យផ្ទៀងផ្ទាត់រួចមកហើយក្ដី កំហុសឆ្គងនៅតែអាចកើតមានឡើងជាពុំខានឡើយ។ ដូចនេះ យើងខ្ញុំសូមធ្វើការអភ័យទោសទុកជាមុននូវរាល់កំហុសឆ្គងដោយអចេតនាដែលអាចកើតមានឡើងនៅក្នុងកិច្ចការស្រាវជ្រាវមួយនេះ ហើយយើងខ្ញុំរង់ចាំទទួលនូវការរិះគន់ និងកែលម្អពីសំណាក់អ្នកអានក្នុងន័យស្ថាបនា ដើម្បីធ្វើឱ្យស្នាដៃមួយនេះកាន់តែមានភាពល្អប្រសើរឡើង។

ជាចុងក្រោយក្នុងនាមយើងខ្ញុំជាអ្នករៀបចំសារណាមួយនេះសង្ឃឹមថា ឯកសារនេះនឹងក្លាយជាប្រយោជន៍ និងជាវិភាគទាន ព្រមទាំងផ្ដល់ជាចំណេះដឹងបន្ថែមសម្រាប់ជាគន្លឹះ និងជំនួយស្មារតីដល់ប្អូនៗជំនាន់ក្រោយៗទៀតអាចធ្វើការសិក្សាស្រាវជ្រាវបន្តបាន។ យើងខ្ញុំទាំងពីររូបក៏សូមជូនពរដល់អស់លោក-លោកស្រីដែលកំពុងអានសៀវភៅមួយនេះ សូមចួបប្រទះនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

## មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........................................ ១

**ជំពូកទី១**

**សញ្ញាណទូទៅ និងធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ**

**១.១ សញ្ញាណទូទៅ** ........................................ ៤

**១.១.១. និយមន័យ** ........................................ ៤

**១.១.២. ភាពខុសគ្នារវាងបទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសដទៃទៀត** ........................................ ៤

១.១.២.១. ភាពខុសគ្នារវាងបទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសផ្នែករដ្ឋប្បវេណី ........................................ ៤

១.១.២.២. ការបែងចែករវាងបទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសផ្នែកវិន័យ ........................................ ៥

**១.២. ធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ** ........................................ ៧

**១.២.១. ធាតុនីត្យានុកូល ឬធាតុច្បាប់** ........................................ ៨

១.២.១.១. គោលការណ៍នីត្យានុកូលភាព ........................................ ៨

ក. នីត្យានុកូលភាពនៃបទល្មើស ........................................ ៨

ខ. នីត្យានុកូលភាពនៃទោស ........................................ ៨

១.២.១.២. ផលវិបាកនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌ ........................................ ៩

១.២.១.៣. ការអនុវត្តច្បាប់ព្រហ្មទណ្ឌ ........................................ ៩

ក. ការបកស្រាយច្បាប់ព្រហ្មទណ្ឌ ........................................ ១០

ខ. ការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងកាល ........................................ ១០

គ. ការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងដែនដី ........................................ ១២

**១.២.២. ធាតុសត្យានុម័ត ឬធាតុសម្ភារៈ** ........................................ ១៤

១.២.២.១. អំពើ ........................................ ១៤

ក. អំពើសកម្ម ........................................ ១៤

ខ. អំពើអកម្ម ........................................ ១៤

១.២.២.២. ព្យសនកម្ម ........................................ ១៥

១.២.២.៣. ទំនាក់ទំនងរវាងអំពើ និងព្យសនកម្ម ឬចំណងហេតុ និងផល ........................................ ១៥

១.២.២.៤. ដំណាក់កាលនៃការប្រព្រឹត្តបទល្មើស ........................................ ១៦

ក. ដំណាក់កាលនៃការគិត និងការសម្រេចចិត្តប្រព្រឹត្តបទល្មើស ..... ១៦
ខ. ដំណាក់កាលនៃការត្រៀមរៀបចំប្រព្រឹត្តបទល្មើស ..... ១៧
គ. ដំណាក់កាលនៃការចាប់ផ្តើមប្រព្រឹត្តបទល្មើស ..... ១៧
ឃ. ដំណាក់កាលនៃការសម្រេចនូវបទល្មើស ឬបទល្មើសមិនបានសម្រេច(ប៉ុនប៉ង) ..... ១៨
**១.២.៣. ធាតុអត្តនោម័ត ឬធាតុចិត្តសាស្ត្រ** ..... ១៩
១.២.៣.១. កំហុស ..... ២០
ក. កំហុសចេតនា ..... ២០
ក.១ កំហុសចេតនាចំពោះ ..... ២១
ក.២ កំហុសចេតនាមិនចំពោះ ..... ២១
ខ. កំហុសអចេតនា ..... ២២
ខ.១. កំហុសអចេតនាដោយធ្វេសប្រហែស ..... ២២
ខ.២. កំហុសអចេតនាដោយមិនគោរពកាតព្វកិច្ចដោយឡែក ..... ២៣
១.២.៣.២. គំនិតផ្តួចផ្តើម ឬមូលហេតុក្នុងការប្រព្រឹត្តបទល្មើស ..... ២៣
១.២.៣.៣. គោលដៅនៃការប្រព្រឹត្តបទល្មើស ..... ២៤

**ជំពូកទី២**

**ចំណាត់ថ្នាក់នៃបទល្មើស**

**២.១. ការបែងចែករវាងបទឧក្រិដ្ឋ មជ្ឈិម និងលហុ** ..... ២៥
២.១.១. លក្ខណៈវិនិច្ឆ័យនៃបទល្មើស ..... ២៥
២.១.១.១. បទល្មើសជាបទឧក្រិដ្ឋ ..... ២៥
២.១.១.២. បទល្មើសជាបទមជ្ឈិម ..... ២៦
២.១.១.៣. បទល្មើសជាបទលហុ ..... ២៦
២.១.២. ផលប្រយោជន៍នៃការបែងចែក ..... ២៧
២.១.២.១. ផលប្រយោជន៍ទាក់ទងនឹងអាជ្ញាយុកាល ..... ២៧
ក. អាជ្ញាយុកាលនៃបទល្មើស ..... ២៧
ខ. អាជ្ញាយុកាលនៃទោស ..... ២៨
២.១.២.២. ផលប្រយោជន៍ទាក់ទងនឹងការអនុវត្តនីតិវិធី ..... ២៨
២.១.២.៣. ផលប្រយោជន៍ទាក់ទងនឹងការប៉ុនប៉ង ..... ២៨

២.១.២.៤. ផលប្រយោជន៍ទាក់ទងនឹងការផ្តើមគំនិត និងការសមគំនិត ...................................... ២៩

**២.២. ចំណាត់ថ្នាក់ដោយផ្អែកលើប្រភេទនៃបទល្មើស** ........................................................ ៣០

២.២.១. ការបែងចែកប្រភេទនៃបទល្មើស ............................................................................. ៣០

២.២.១.១. បទល្មើសនយោបាយ ....................................................................................... ៣០

២.២.១.២. បទល្មើសយោធា ............................................................................................ ៣០

២.២.១.៣. បទល្មើសភេរវកម្ម ......................................................................................... ៣១

២.២.២. សមត្ថកិច្ចទាក់ទងនឹងការបែងចែកបទល្មើស ............................................................ ៣១

## ជំពូកទី៣

## ការទទួលខុសត្រូវព្រហ្មទណ្ឌ និងការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

**៣.១. ការទទួលខុសត្រូវព្រហ្មទណ្ឌ** ............................................................................... ៣២

៣.១.១. ការទទួលខុសត្រូវរបស់រូបវន្តបុគ្គល ........................................................................ ៣២

៣.១.១.១. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិជន ............................................................ ៣៣

៣.១.១.២. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន ......................................................... ៣៤

ក. វិធានការអនុវត្តចំពោះអនីតិជនក្រៅពីទោស ............................................................... ៣៤

ខ. ទណ្ឌកម្មព្រហ្មទណ្ឌលើអនីតិជន ................................................................................ ៣៥

៣.១.២. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល ............................................................ ៣៧

៣.១.២.១. លក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល ........................................ ៣៨

ក. អត្ថិភាពនៃច្បាប់ ឬលិខិតបទដ្ឋានគតិយុត្ត ................................................................... ៣៨

ខ. បទល្មើសប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងនីតិបុគ្គល ................................................... ៣៨

គ. ការប្រព្រឹត្តដើម្បីជាប្រយោជន៍ដល់នីតិបុគ្គល ................................................................. ៣៨

៣.១.២.២. ការដាក់ទណ្ឌកម្មលើនីតិបុគ្គល ........................................................................... ៣៩

**៣.២. ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ** ............................................................................ ៤០

៣.២.១. មូលហេតុទាក់ទងផ្ទាល់ទៅនឹងបុគ្គលនៃចារី ឬអ្នកប្រព្រឹត្តបទល្មើស .................................. ៤១

៣.២.១.១. វិបល្លាសស្មារតី ............................................................................................... ៤១

៣.២.១.២. អានុភាពនៃកម្លាំងបង្ខំ ........................................................................................ ៤២

ក. កម្លាំងបង្ខំលើរូបកាយ ............................................................................................. ៤២

ខ. កម្លាំងបង្ខំលើផ្លូវចិត្ត .............................................................................................. ៤៣

៣.២.២. មូលហេតុខាងក្រៅបុគ្គលនៃចារី ឬអ្នកប្រព្រឹត្តបទល្មើស ........ ៤៤
៣.២.២.១. ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ ........ ៤៤
ក. ការអនុញ្ញាតដោយច្បាប់ ........ ៤៤
ខ. ការអនុញ្ញាតដោយអាជ្ញាធរ ........ ៤៥
ខ.១. អាជ្ញាធរស្របច្បាប់ ........ ៤៥
ខ.២. បញ្ជាស្របច្បាប់ ........ ៤៥
៣.២.២.២. ការការពារស្របច្បាប់ ........ ៤៦
ក. លក្ខខណ្ឌនៃការការពារស្របច្បាប់ ........ ៤៦
ខ. ការឈ្លានពាន ........ ៤៧
គ. ការការពារការឈ្លានពាន ........ ៤៧
៣.២.២.៣. ស្ថានភាពចាំបាច់ ........ ៥០
ក. គ្រោះថ្នាក់កំពុងមាន ឬដែលនឹងកើតមាន ........ ៥០
ខ. ការការពារជាចាំបាច់ ........ ៥០
គ. ការការពារដែលគ្មានវិសមាមាត្រជាមួយនឹងទម្ងន់នៃគ្រោះថ្នាក់ ........ ៥១
**សេចក្ដីសន្និដ្ឋាន** ........ ៥៣
**អនុសាសន៍** ........ ៥៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសមួយដែលប្រកាន់យករបបលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សដោយគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ កាតិកាសញ្ញា និងអនុសញ្ញាអន្តរជាតិទាំងឡាយទៀតដែលពាក់ព័ន្ធ។ ហេតុនេះ សិទ្ធិសេរីភាព និងអាយុជីវិតមនុស្សម្នាក់ៗគឺត្រូវបានធានាដោយច្បាប់ ពោលគឺមនុស្សម្នាក់ៗមានសិទ្ធិសេរីភាពក្នុងការរស់រានមានជីវិត និងមានសន្តិសុខផ្ទាល់ខ្លួនក្នុងការរស់នៅ។ ក៏ប៉ុន្តែទោះជាយ៉ាងណាក្តី ក្នុងសង្គមនីមួយៗតែងតែកើតមានឡើងនូវអំពើរំលោភបំពានទៅលើសិទ្ធិ ក៏ដូចជាអំពើដែលប៉ះពាល់ដល់សន្តិសុខរបស់បុគ្គលណាមួយ ឬប៉ះពាល់ដល់សណ្តាប់សាធារណៈដែលវាបង្កើតបានទៅជាបទល្មើស។

ក្នុងស្ថាប័នតុលាការដែលជាស្ថាប័នផ្តល់យុត្តិធម៌ជូនប្រជាពលរដ្ឋ នៅពេលធ្វើការកាត់ក្តីទៅលើជនណាម្នាក់ ចៅក្រមត្រូវកាត់ក្តី និងដាក់ទោសជនល្មើសទៅតាមច្បាប់ដែលមានចែងជាធរមានតាមប្រភេទទោសដែលជនល្មើសបានប្រព្រឹត្ត ហើយប្រសិនបើជាជនល្មើសបានប្រព្រឹត្តបទល្មើសដែលពាក់ព័ន្ធនឹងរឿងព្រហ្មទណ្ឌ ព្រះរាជអាជ្ញានឹងធ្វើការចោទប្រកាន់ជននោះតាមការចាត់ថ្នាក់នៃបទល្មើសក្នុងក្រមព្រហ្មទណ្ឌ និងធ្វើការបញ្ជូនទៅតុលាការតាមនីតិវិធីដើម្បីធ្វើការជំនុំជម្រះក្តី។

ដូច្នេះនៅពេលណាដែលមានរឿងក្តីមួយបានកើតឡើង ដែលរឿងក្តីនោះវាធ្វើឱ្យប៉ះពាល់សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ ឬសន្តិសុខសង្គម ហើយត្រូវបានកំណត់ទុកជាមុនក្នុងច្បាប់ព្រហ្មទណ្ឌ នោះគេហៅថាជា **បទល្មើសព្រហ្មទណ្ឌ** ហើយតុលាការនឹងធ្វើការផ្តន្ទាទោសទៅលើជនដែលប្រព្រឹត្តបទល្មើសនោះ ហើយជនទៀតសោតនឹង **ទទួលខុសត្រូវព្រហ្មទណ្ឌ** ទៅតាមច្បាប់ដែលមានចែងជាធរមាន។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ការស្គាល់ពី **បទល្មើសព្រហ្មទណ្ឌ** បានច្បាស់លាស់ជារឿងសំខាន់មួយដែលផ្តល់ភាពងាយស្រួលដល់ការចោទប្រកាន់របស់ព្រះរាជអាជ្ញា និងមានភាពងាយស្រួលដល់ការផ្តន្ទាទោសពីសំណាក់ចៅក្រមនៅក្នុងស្ថាប័នតុលាការដើម្បីឱ្យនីតិវិធីអនុវត្តបានត្រឹមត្រូវតាមយុត្តាធិការនៅក្នុងវិស័យយុត្តិធម៌ និងមានមូលដ្ឋានច្បាស់លាស់ក្នុងការចោទប្រកាន់ ដើម្បីឱ្យជនល្មើសត្រូវ **ទទួលខុសត្រូវព្រហ្មទណ្ឌ** តាមអំពើដែលខ្លួនប្រព្រឹត្ត។

ការស្រាវ ជ្រាវប្រធានបទនេះ ជាការឆ្លើយតបទៅនឹងសំណួរដូចខាងក្រោមៈ

- តើអ្វីទៅជា បទល្មើសព្រហ្មទណ្ឌ?
- តើបទល្មើសនេះវាមានសារៈសំខាន់អ្វីខ្លះនៅក្នុងរឿងព្រហ្មទណ្ឌ?
- បទល្មើសព្រហ្មទណ្ឌមានធាតុផ្សំអ្វីខ្លះ?

- តើបទល្មើសព្រហ្មទណ្ឌចែកចេញជាប៉ុន្មានថ្នាក់?អ្វីខ្លះ?
- តើបុគ្គលណាខ្លះដែលអាចទទួលខុសត្រូវព្រហ្មទណ្ឌ? ហើយបុគ្គលណាខ្លះដែលមិនទទួលខុសត្រូវព្រហ្មទណ្ឌ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសម្រេចជ្រើសរើសប្រធានបទមួយនេះសរសេរឡើងមក គឺក្រុមយើងខ្ញុំមើលឃើញថាវាពិតជាមានសារៈសំខាន់នៅក្នុងសង្គម ទាំងផ្នែកសិក្សា និងការអនុវត្ត ហើយកម្មវត្ថុនៅក្នុងការសិក្សាស្រាវជ្រាវនេះចង់បង្ហាញពីបទល្មើសព្រហ្មទណ្ឌដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និងការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលទោសមានពីរប្រភេទគឺ ទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ ហើយទោសទាំងពីរនេះអាចអនុវត្តព្រមគ្នាបានចំពោះបទឧក្រិដ្ឋ បទមជ្ឈិម ឬពេលខ្លះអនុវត្តទោសតែមួយក្នុងចំណោមទោសទាំងពីរទៅតាមបទល្មើសដែលជនល្មើសបានប្រព្រឹត្ត។ មួយវិញទៀតការស្រាវជ្រាវនេះផ្តោតសំខាន់ទៅលើ ធាតុផ្សំនៃបទល្មើស និងការទទួលខុសត្រូវក្នុងរឿងព្រហ្មទណ្ឌ។ តាមរយៈប្រធានបទមួយនេះក៏បានសង្កត់ធ្ងន់ទៅលើអំពើប្រព្រឹត្តផងដែរ ដែលអំពើប្រព្រឹត្តមួយអាចចាត់ទុកថាជាបទល្មើសបានវាទាល់តែមាននូវធាតុផ្សំបីយ៉ាងនៅក្នុងនោះ រួមមានដូចជា **ធាតុ នីត្យានុកូល**(ធាតុច្បាប់) **ធាតុសត្យានុម័ត**(ធាតុសម្ភារៈ) និង**ធាតុអត្តនោម័ត**(ធាតុចិត្តសាស្ត្រ)ដែលសុទ្ធតែជាធាតុផ្សំសំខាន់ៗនៅក្នុងប្រធានបទមួយនេះ។ មួយវិញទៀត ការស្រាវជ្រាវនេះមានគោលបំណងធ្វើឱ្យការសិក្សាផ្នែកច្បាប់ទាក់ទងនឹងរឿងព្រហ្មទណ្ឌកាន់តែមានភាពទូលំទូលាយ មានភាពច្បាស់លាស់ជាងមុនក្នុងការសិក្សាផ្នែកនេះ និងដើម្បីចូលរួមចំណែកក្នុងសង្គមឱ្យប្រជាពលរដ្ឋមានការយល់ដឹងកាន់តែច្រើនជាងមុនជៀស វាងនូវការធ្វើរឿងដែលខុសទៅនឹងច្បាប់ដែលវាបណ្តាលឱ្យកើតមានជាបទល្មើស នាំឱ្យសង្គមមិនរីកចម្រើនលូតលាស់ទៅវិញទេ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ចំពោះទំហំនៃការស្រាវជ្រាវវិញ ក្រុមយើងខ្ញុំក៏បានធ្វើការស្រាវជ្រាវផ្តោតសំខាន់ពីច្បាប់នៅក្នុងបច្ចុប្បន្នភាព និងមានវិសាលភាពតែនៅក្នុងព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

កិច្ចការស្រាវជ្រាវនេះនឹងចូលរួមចំណែកសម្រាប់ការស្រាវជ្រាវរបស់បងប្អូននិស្សិតក៏ដូចជាចូលរួមជាវិភាគទាននៅក្នុងការចែករំលែកនូវពុទ្ធិដល់បងប្អូនប្រជាពលរដ្ឋក្នុងការយល់ដឹងទាក់ទងនឹងបទល្មើសព្រហ្មទណ្ឌ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ក្នុងការស្រាវជ្រាវដើម្បីសម្រេចប្រធានបទមួយនេះឡើង គឺត្រូវបានរៀបរៀង និងធ្វើការស្រាវជ្រាវដោយប្រមូលនូវព័ត៌មានទាំងឡាយរួមមាន៖

- ឯកសារច្បាប់ពាក់ព័ន្ធទៅនឹងប្រធានបទ ដូចជាលិខិតបទដ្ឋានជាតិ និងអន្តរជាតិដែលមានជាធរមាននៅបច្ចុប្បន្ននេះ

- ការដកស្រង់ចេញពីប្រភពផ្សេងៗដូចជាការបកស្រាយរបស់នីតិករ ក៏ដូចជាអ្នកដែលមានបទពិសោធន៍នៅក្នុងវិស័យច្បាប់ និងយោបល់របស់អ្នកជំនាញផ្នែកច្បាប់ជាដើម។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

តាមការស្រាវជ្រាវកន្លងមក យើងខ្ញុំនឹងខិតខំប្រឹងប្រែងធ្វើការបង្ហាញ និងអធិប្បាយឱ្យបានលម្អិត ព្រមទាំងមានភាពភាពច្បាស់លាស់ទៅលើចំនុចមួយចំនួន ដោយក្រុមយើងខ្ញុំបានធ្វើការបែងចែកជា បី ជំពូកធំៗដើម្បីឆ្លើយតបទៅនឹងប្រធានបទខាងលើរួមមាន៖

➢ **សេចក្តីផ្តើម ៖** ផ្នែកនេះនិយាយពីលំនាំនៃបញ្ហាស្រាវជ្រាវ ចំណោទនៃបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ទំហំនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិធីសាស្រ្តក្នុងការស្រាវជ្រាវ និងចុងក្រោយគឺ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

➢ **ជំពូកទី១ សញ្ញាណទូទៅ និងធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ ៖** និយាយពីនិយមន័យ និងទាក់ទងនឹងធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ។

➢ **ជំពូកទី២ ចំណាត់ថ្នាក់នៃបទល្មើស ៖** និយាយពីការបែងចែកចំណាត់ថ្នាក់នៃបទល្មើសព្រហ្មទណ្ឌ និងចំណាត់ថ្នាក់ផ្អែកតាមប្រភេទនៃបទល្មើស។

➢ **ជំពូកទី៣ ការទទួលខុសត្រូវព្រហ្មទណ្ឌ និងការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ៖** និយាយពីការទទួលខុសត្រូវព្រហ្មទណ្ឌ និងការរៀបរាប់ពីការមិនទទួលខុសត្រូវព្រហ្មទណ្ឌទាំងនីតិជន អនីតិជន និងនីតិបុគ្គល។

# ជំពូកទី ១

# សញ្ញាណទូទៅ

# និង

# ធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ

# ជំពូកទី ១
# សញ្ញាណទូទៅនៃបទល្មើស

## ១.១. សញ្ញាណទូទៅ

### ១.១.១. និយមន័យ

បទល្មើសព្រហ្មទណ្ឌគឺជាអំពើប្រព្រឹត្តដោយចេតនា ឬអចេតនាក្តី ដោយសកម្ម ឬដោយអកម្មក្តី ដែលអំពើនោះបណ្តាលឱ្យប៉ះពាល់សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ ឬសន្តិសុខសង្គម ហើយត្រូវបានកំណត់ទុកជាមុនក្នុងច្បាប់ព្រហ្មទណ្ឌ[1] ។ ជាធម្មតាជាគេចាត់អំពើមួយគឺជាបទល្មើស លុះត្រាតែអំពើនោះបង្ហាញនូវគ្រោះថ្នាក់ដល់សង្គមដែលច្បាប់ការពារ។

បទល្មើសគឺជាអំពើខុសនឹងសីលធម៌សង្គមប៉ះពាល់ដល់សណ្តាប់ ធ្នាប់សង្គម និងថែមទាំងបង្កឱ្យមានព្យសនកម្មគួរឱ្យកត់សម្គាល់សម្រាប់សង្គម។ ច្បាប់បានបញ្ញត្តិថា អំពើខ្លះរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបង្កចលាចលដល់សង្គមគឺជា បទល្មើស[2]។ តាមន័យនេះបង្ហាញឱ្យយើងឃើញថា ដើម្បីបង្កើតបានជាបទល្មើស គឺចាំបាច់ត្រូវតែមានច្បាប់ចែង ហើយមានតែអំពើដែលបង្កចលាចលដល់សង្គមប៉ុណ្ណោះដែលត្រូវចាត់ទុកជាបទល្មើសបាន។

មែនទែនទៅ មិនមែនមានតែបទល្មើសព្រហ្មទណ្ឌទេដែលបង្កគ្រោះថ្នាក់ដល់បុគ្គល និងសង្គម គឺនៅមានអំពើមួយចំនួនទៀតដែលជាអំពើបង្កឱ្យមានគ្រោះថ្នាក់ដែរ ក៏ប៉ុន្តែមិនត្រូវបានគេចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌទេ តែត្រូវបានចាត់ទុកថាជាកំហុសរដ្ឋប្បវេណី[3] ហើយចារីនឹងត្រូវចាប់បង្ខំឱ្យបង់ជាប្រាក់សំណង និងជំងឺចិត្តតែប៉ុណ្ណោះ។

### ១.១.២. ភាពខុសគ្នារវាងបទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសដទៃទៀត

#### ១.១.២.១. ភាពខុសគ្នារវាងបទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសផ្នែករដ្ឋប្បវេណី

ភាពខុសគ្នារវាងបទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសផ្នែករដ្ឋប្បវេណីមានដូចខាងក្រោមៈ

អំពើល្មើសផ្នែករដ្ឋប្បវេណីមានប្រភពចេញមកពីបទបញ្ញត្តិនៃក្រមរដ្ឋប្បវេណីដែលបានចែងថា បុគ្គលដែលបំពានដោយខុសច្បាប់នូវសិទ្ធិ ឬផលប្រយោជន៍របស់ជនដទៃដោយកំហុសចេតនា ឬដោយអចេតនាត្រូវទទួល

[1] នីតិព្រហ្មទណ្ឌពិសេស, សាស្ត្រាចារ្យ ជួន ប៊ុនធី (ឆ្នាំ២០២១)។
[2] មាត្រា ២, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។
[3] ពេលខ្លះគេប្រើពាក្យ បទល្មើសរដ្ឋប្បវេណី ផងដែរ។

ខុសត្រូវក្នុងការសងការខូចខាតដែលកើតឡើងដោយអំពើនោះ[4] រីឯបទល្មើសព្រហ្មទណ្ឌវិញត្រូវតែជាអំពើដែលច្បាប់បានចែងយ៉ាងច្បាស់លាស់ទុកជាមុនថាជាបទល្មើសព្រហ្មទណ្ឌ[5]។

សម្រាប់អំពើល្មើសផ្នែករដ្ឋប្បវេណី ព្យសនកម្មគឺជាកត្តាចាំបាច់ដើម្បីអាចឱ្យតុលាការដាក់ទណ្ឌកម្មលើអ្នកប្រព្រឹត្តបាន។ ផ្ទុយទៅវិញ ការបង្កើតជាបទល្មើសព្រហ្មទណ្ឌគឺពុំសុទ្ធតែទាមទារឱ្យមានព្យសនកម្មទេ មានដូចជាបទល្មើសជួញដូរសារធាតុញៀនដោយខុសច្បាប់ ឬការបើកបរយានយន្តក្នុងល្បឿនហួសពីការកំណត់របស់ច្បាប់ជាដើម។

ការបង់ប្រាក់សំណងជំងឺចិត្ត គឺជាទណ្ឌកម្មសម្រាប់អំពើល្មើសរដ្ឋប្បវេណីហើយជាទណ្ឌកម្មដែលផ្តល់ប្រយោជន៍ដល់ជនរងគ្រោះ។ ប៉ុន្តែផ្ទុយទៅវិញ ទោសដែលជាទណ្ឌកម្មព្រហ្មទណ្ឌមានគោលដៅការពារសង្គម នឹងមិនត្រូវបានជាប្រយោជន៍ដល់ជនរងគ្រោះទេ ពោលគឺប្រាក់ពិន័យត្រូវទុកជាចំណូលថវិការបស់រដ្ឋ[6] រីឯប្រាក់សំណងជំងឺចិត្តត្រូវបានទៅជនរងគ្រោះ ព្រោះថាប្រាក់សំណងជំងឺចិត្តមានគោលដៅត្រឹមតែជួសជុលការខូចខាតប៉ុណ្ណោះ។

អំពើមួយអាចជាបទល្មើសព្រហ្មទណ្ឌ តែពុំមែនជាអំពើល្មើសផ្នែករដ្ឋប្បវេណីទេ ឧទាហរណ៍ដូចជា ការល្មើសដោយពុំព្រមឈប់ពេលភ្លើងស្តុបក្រហម ការជួញដូរសារធាតុញៀនដោយខុសច្បាប់ ការជួញដូរអាវុធខុសច្បាប់ជាដើម។ អំពើល្មើសផ្នែករដ្ឋប្បវេណីខ្លះថ្វីត្បិតតែជាអំពើខុសឆ្គងក៏ពិតមែន ក៏ប៉ុន្តែពុំមែនជាបទល្មើសទេ ដូចជាករណីដែលជនម្នាក់ចោលដំបងទៅក្រៅផ្ទះបណ្តាលឱ្យខូចខាតដល់រថយន្តរបស់អ្នកដទៃដោយអចេតនា។

ផ្ទុយមកវិញ អំពើមួយអាចត្រូវបានចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌផង និងជាអំពើល្មើសផ្នែករដ្ឋប្បវេណីផងក៏បានដែរដូចជា បទឃាតកម្ម ឬបទហិង្សាដោយចេតនា[7]ចំពោះអ្នកដទៃជាដើម។ ក្នុងករណីបែបនេះ អំពើល្មើសនាំឱ្យមានបណ្តឹងពីរប្រភេទគឺ បណ្តឹងអាជ្ញា[8] និងបណ្តឹងរដ្ឋប្បវេណី[9]។

### ១.១.២.២. ការបែងចែករវាងបទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសផ្នែកវិន័យ

ការបែងចែករវាងបទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសផ្នែកវិន័យអាចផ្អែកលើមូលដ្ឋានដូចតទៅ៖

---

[4] មាត្រា ៧៤៣ កថាខណ្ឌទី១, ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧ ។

[5] មាត្រា ៣, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

[6] មាត្រា ៥២, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, ចែងថា *ប្រាក់ពិន័យដែលទទួលបានត្រូវបង់ចូលថវិការដ្ឋ*។

[7] ឧទាហរណ៍៖ ការវាយតប់ទៅលើអ្នកដទៃបណ្តាលឱ្យរងរបួស គឺជាអំពើហិង្សាដោយចេតនា។

[8] មាត្រា ២ កថាខណ្ឌទី២, ក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, ចែងថា **បណ្តឹងអាជ្ញា** មានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើសបង្ហាញឱ្យឃើញពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននេះតាមច្បាប់កំណត់។

[9] មាត្រា ២ កថាខណ្ឌទី៣, ក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, ចែងថា **បណ្តឹងរដ្ឋប្បវេណី** មានគោលបំណងធ្វើឱ្យបានជួសជុលការខូចខាតដែលបណ្តាលមកពីអំពើល្មើសដល់ភាគីរងគ្រោះ ហើយក្នុងគោលបំណងនេះឱ្យអ្នករងគ្រោះបានទទួលសំណងជំងឺចិត្តធួនល្មមនឹងព្យសនកម្មដែលខ្លួនបានទទួល។

អំពើល្មើសផ្នែកវិន័យ គឺជាអំពើដែលធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ជាសមូហភាពនៃក្រុមសង្គមណាមួយរួមមានដូចជា ចៅក្រម ពេទ្យ មេធាវី និស្សិត ជាដើម ហើយអំពើនោះមិនត្រូវបានកំណត់ឱ្យច្បាស់លាស់ជាទូទៅទេ។ ឧទាហរណ៍ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី បានចែងថា ត្រូវទទួលទណ្ឌកម្មជាបទវិន័យចំពោះមេធាវីណាដែលប្រព្រឹត្តល្មើសនឹងវិធានវិជ្ជាជីវៈ ឬប្រព្រឹត្តអំពើណាមួយដែលប៉ះពាល់ដល់សីលធម៌ ឬកិត្តិយសមេធាវី ទោះបីប្រព្រឹត្តក្រៅពីការប្រកបវិជ្ជាជីវៈរបស់ខ្លួនក៏ដោយ[10]។ ហេតុដូច្នេះ ការកំណត់របៀបនេះបង្ហាញឱ្យឃើញថា អំពើល្មើសផ្នែកវិន័យសម្រាប់វិជ្ជាជីវៈមេធាវីពុំត្រូវបានបញ្ជាក់ឱ្យបានច្បាស់ជាមុនដូចជាករណីនៃបទល្មើសព្រហ្មទណ្ឌទេ ព្រោះថាអំពើប៉ះពាល់ដល់សីលធម៌ ឬកិត្តិយសមេធាវីជាសញ្ញាណមួយទូលំទូលាយណាស់ និងក្តោបបញ្ចូលនូវអំពើច្រើនបែបច្រើនយ៉ាង។

យ៉ាងណាមិញ បទល្មើសព្រហ្មទណ្ឌ ទោះបីជាមានចំនួនដ៏ច្រើនយ៉ាងណាក៏ដោយ ក៏សុទ្ធសឹងតែជាអំពើដែលច្បាប់បានកំណត់យ៉ាងច្បាស់លាស់ជាមុនរួចស្រេចអស់ទៅហើយ បានន័យថា អំពើណាដែលច្បាប់ពុំបានចែងថាជាបទល្មើសព្រហ្មទណ្ឌទេ គឺពុំអាចចាត់ទុកជាបទល្មើសព្រហ្មទណ្ឌបានទេ ដោយផ្អែកតាមគោលការណ៍នីត្យានុកូលភាពនៃបទល្មើស។

អំពើល្មើសផ្នែកវិន័យ គឺជាអំពើដែលធ្វើឱ្យប៉ះពាល់ផ្នែកណាមួយនៃសង្គមតែប៉ុណ្ណោះ ពោលគឺក្រុមសង្គមដែលជនប្រព្រឹត្តល្មើសស្ថិតនៅ។ ដោយឡែក ប្រសិនបើជាបទល្មើសព្រហ្មទណ្ឌវិញ គឺជាអំពើដែលធ្វើឱ្យប៉ះពាល់ដល់សង្គមជាទូទៅ ឬនិយាយម្យ៉ាងទៀតថា បទល្មើសព្រហ្មទណ្ឌធ្វើឱ្យប៉ះពាល់ដល់សង្គមមនុស្សច្រើនជាងអំពើល្មើសផ្នែកវិន័យទៅទៀត។

ជាធម្មតា ការដាក់ទណ្ឌកម្មទៅលើអំពើល្មើសផ្នែកវិន័យត្រូវតែធ្វើឡើងដោយស្ថាប័នពិសេសសម្រាប់ក្រុមសង្គមណាមួយ។ ឧទាហរណ៍ជាក់ស្តែងនៅក្នុងព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន ក្រុមប្រឹក្សាគណៈមេធាវីគឺជាស្ថាប័នដែលមានសមត្ថកិច្ចក្នុងការដាក់ទណ្ឌកម្មវិន័យលើមេធាវីដែលបានប្រព្រឹត្តខុសឆ្គង ចំណែកគណៈវិជ្ជាជីវៈសុខាភិបាលមានសមត្ថកិច្ចក្នុងការដាក់វិន័យចំពោះអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលដែលបានប្រព្រឹត្តកំហុសឆ្គងវិជ្ជាជីវៈ[11]។ រីឯទណ្ឌកម្មវិន័យចំពោះមេធាវីមានដូចជា ការព្រមាន ការស្តីបន្ទោស ការហាមឃាត់ការប្រកបវិជ្ជាជីវៈមួយរយៈដែលពុំអាចលើសពី ២ឆ្នាំ ការលុបឈ្មោះចោល ឬការហូតងារកិត្តិយស[12]។

រីឯការដាក់ទណ្ឌកម្មព្រហ្មទណ្ឌវិញ គឺជាសមត្ថកិច្ចរបស់សាលាជម្រះក្តីនៃព្រះរាជាណាចក្រកម្ពុជា ហើយទណ្ឌកម្មអាចមានលក្ខណៈធ្ងន់ធ្ងររហូតដល់ការដាក់ពន្ធនាគារអស់មួយជីវិតទៀតផង។

---

[10] មាត្រា ៥៩, ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ១៩៩៥ ។

[11] មាត្រា ១៥, ច្បាប់ស្តីពី ការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល, លេខ នស/រកម/១១១៦/០១៤, ១៩ វិច្ឆិកា ២០១៦ ។ យោងតាមច្បាប់នេះ អ្នកវិជ្ជាជីវៈសុខាភិបាល ដំដៅដល់គ្រូពេទ្យ ទន្តពេទ្យ ឆ្មប គិលានុបដ្ឋាក ឱសថការី។ល។

[12] មាត្រា ៦៣, ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ១៩៩៥ ។

ប្រហាក់ប្រហែលនឹងបំណែងចែកវាងបទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសផ្នែករដ្ឋប្បវេណីដែរ ការបែងចែកវាងអំពើល្មើសផ្នែកវិន័យ និងបទល្មើសព្រហ្មទណ្ឌបានឆ្លុះបញ្ចាំងឱ្យឃើញថា ក្នុងករណីខ្លះ អំពើមួយត្រូវចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ ក៏ប៉ុន្តែពុំមែនជាបទល្មើសផ្នែកវិន័យទេ។ ឧទាហរណ៍ ជនអនាថាម្នាក់បានលួចទ្រព្យសម្បត្តិរបស់អ្នកដទៃ, ស្ត្រីមេផ្ទះម្នាក់បានឆបោកប្រាក់របស់អ្នកជិតខាងរបស់ខ្លួន...។

ពេលខ្លះអំពើមួយត្រូវបានចាត់ទុកថាជាអំពើល្មើសផ្នែកវិន័យ ក៏ប៉ុន្តែពុំត្រូវបានចាត់ចូលជាបទល្មើសព្រហ្មទណ្ឌឡើយ។ ឧទាហរណ៍ វេជ្ជបណ្ឌិត ឬគ្រូពេទ្យមធ្យមដែលបានធ្វើការរំលូតកូនដោយពុំមានការអនុញ្ញាតតាមច្បាប់ស្តីពីការរំលូតកូនឱ្យបានត្រឹមត្រូវ, មន្ត្រីរាជការម្នាក់ដែលមិនបានមកធ្វើការងារជាច្រើនថ្ងៃដោយពុំមានច្បាប់អនុញ្ញាតឱ្យឈប់សម្រាក ឬព្យួរការងារ...។

ដូច្នេះឃើញថា អំពើដែលច្បាប់បានកំណត់ថាជាបទល្មើសមានច្រើនណាស់ ដែលមិនអាចរៀបរាប់ឱ្យអស់សេចក្តីបានទេ ហើយមិនមែនតែក្រមព្រហ្មទណ្ឌនោះទេដែលកំណត់អំពីបទល្មើស គឺនៅមានច្បាប់ជាច្រើនផ្សេងទៀតក៏បានកំណត់បទល្មើសដែរ។ ដូច្នេះ ដើម្បីអាចដឹងពីបទល្មើសទាំងអស់នោះបាន ទាល់តែពិនិត្យឱ្យបានគ្រប់ច្បាប់ និងបទដ្ឋានគតិយុត្តទាំងអស់ទើបអាចដឹងបាន ហើយបន្ទាប់ពីនោះគេក៏អាចធ្វើការសម្គាល់ពីធាតុផ្សំនីមួយៗនៃបទល្មើសព្រហ្មទណ្ឌបានផងដែរ។

## ១.២. ធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ

យោងតាមគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ បុគ្គលម្នាក់ៗត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ[13]។ នៅត្រង់ចំណុចនេះ ការទទួលខុសត្រូវព្រហ្មទណ្ឌបានគោរពតាមគោលការណ៍មួយដែលមានភាពខុសប្លែកពីការទទួលរដ្ឋប្បវេណី ដែលអនុញ្ញាតឱ្យមានវិធានពីការទទួលខុសត្រូវលើអំពើរបស់អ្នកដទៃ បានន័យថាអ្នកទទួលខុសត្រូវមិនមែនជាបុគ្គលដែលបានប្រព្រឹត្តអំពើទេ ក៏ប៉ុន្តែច្បាប់តម្រូវឱ្យបុគ្គលនោះទទួលរងនូវផលវិបាកនៃសកម្មភាពរបស់អ្នកដទៃទៅវិញ។ ជាទូទៅ បុគ្គលម្នាក់ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ កាលបើបុគ្គលនោះបានប្រព្រឹត្តអំពើណាមួយដែលមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់។ ប្រសិនបើខ្វះធាតុផ្សំនៃបទល្មើសណាមួយក៏មិនអាចឱ្យបុគ្គលនោះទទួលខុសត្រូវព្រហ្មទណ្ឌបានដែរ។ ការចោទប្រកាន់ និងការផ្តន្ទាទោសជនណា ឬបុគ្គលណាមួយបានគឺលុះត្រាតែតុលាការបានរកឃើញ និងបានប្រកាសពិរុទ្ធភាពដាក់បន្ទុកលើជននោះជាមុនសិន[14]។

[13] មាត្រា ២៤, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

[14] មាត្រា ២៣, ក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧ ។

### ១.២.១. ធាតុនីត្យានុកូល ឬធាតុច្បាប់

#### ១.២.១.១. គោលការណ៍នីត្យានុកូលភាព

ធាតុនីត្យានុកូលនេះ បើយើងហៅសាមញ្ញថាជាធាតុច្បាប់ មានន័យថា ត្រូវមានច្បាប់ណាមួយចែងកំណត់ថាការប្រព្រឹត្តបែបណាខ្លះដែលគេហៅថាជាបទល្មើសត្រូវផ្តន្ទាទោស[15]។ ធាតុផ្សំនីត្យានុកូលគឺជាធាតុផ្សំទាក់ទងនឹងច្បាប់។ ជាដំបូងបំផុត ដាច់ខាតត្រូវតែមានច្បាប់ចែងដើម្បីកំណត់បានថា អំពើណាមួយគឺជាបទល្មើស នេះគឺជា **គោលការណ៍នីត្យានុកូលភាព**។

ក្រៅពីនេះទៀតគោលការណ៍នីត្យានុកូលភាពក៏ត្រូវបានទទួលស្គាល់ដោយលិខិតូបករណ៍អន្តរជាតិ[16] ដែលមានតម្លៃជារដ្ឋធម្មនុញ្ញនៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាផងដែរ។

**ក. នីត្យានុកូលភាពនៃបទល្មើស**

ក្រមព្រហ្មទណ្ឌបានចែងទទួលស្គាល់យ៉ាងច្បាស់នូវគោលការណ៍នីត្យានុកូលភាពថា " មានតែអំពើដែលបង្កើតជាបទល្មើសនៅពេលដែលអំពើនោះមានចែងក្នុងបទបញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន។ មានតែទោសដែលមានចែងក្នុងបញ្ញត្តិព្រហ្មទណ្ឌជាធរមាននៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចត្រូវប្រកាសបាន[17] " ។ នេះបញ្ជាក់យ៉ាងច្បាស់បានថា នៅពេលដែលមានបទល្មើសណាមួយបានកើតឡើង លុះត្រាតែបទល្មើសនោះមានបញ្ញត្តិទុកនៅក្នុងក្រមព្រហ្មទណ្ឌជាធរមានទើបច្បាប់តម្រូវឱ្យបុគ្គលនោះទទួលខុសត្រូវព្រហ្មទណ្ឌបាន។

**ខ. នីត្យានុកូលភាពនៃទោស**

នីត្យានុកូលភាពនៃទោសបានសេចក្តីថា ដើម្បីយកទោសណាមួយទៅផ្តន្ទាលើបុគ្គលណាមួយបាន លុះត្រាតែទោសនោះមានចែងទុកជាមុននៅក្នុងច្បាប់ព្រហ្មទណ្ឌ បើមិនដូច្នោះទេគឺមិនអាចអនុវត្តទោសទៅលើបុគ្គលនោះបានទេ។

ហេតុដូច្នេះហើយ ទើបមានគោលការណ៍មួយលើកឡើងថា "គ្មានបទល្មើសទេ គ្មានទោសទេ ប្រសិនបើគ្មានច្បាប់ចែង" ដែលជាចរិតគ្រឹះកំណត់ពីគោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងនីត្យានុកូលភាពនៃទោស[18]។

---

[15] ប្រសាសន៍របស់ឯកឧត្តម កើត រិទ្ធ អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ ក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី "ក្រមព្រហ្មទណ្ឌ" ដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌សហការណ៍ជាមួយក្រសួងព័ត៌មានតាមរយៈទូរទស្សន៍ជាតិកម្ពុជា ឆ្នាំ២០១០។

[16] លិខិតូបករណ៍អន្តរជាតិ ជាលិខិតបទដ្ឋានអន្តរជាតិដែលបង្កើតឡើងរវាងរដ្ឋ និងរដ្ឋ ឬក៏រវាងរដ្ឋ និងអង្គការអន្តរជាតិ។

[17] មាត្រា ៣, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

[18] នីតិព្រហ្មទណ្ឌទូទៅខ្មែរ, សាស្ត្រាចារ្យ កៅ សីហា, ឆ្នាំ២០១៣ ទំព័រ ១២១ ។

### ១.២.១.២. ផលវិបាកនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌ

ការអនុវត្តច្បាប់ព្រហ្មទណ្ឌវាក៏អាចមានផលវិបាកខ្លះដែរ គឺដោយសារតែនៅពេលដែលបទល្មើសដែលបានកើតឡើងនៅមុនពេលការចូលជាធរមាននៃច្បាប់ ហើយច្បាប់នោះទៀតសោតមិនមានអានុភាពប្រតិសកម្មចំពោះបទល្មើសដែលបានកើតឡើងមុនការចូលជាធរមាននៃច្បាប់ទេ។ ដូចនេះ បទល្មើសដែលបានកើតឡើងមុននោះមិនអាចចាត់ទុកជាបទល្មើសបានទេ។

ដើម្បីអនុវត្តច្បាប់ព្រហ្មទណ្ឌទៅលើបទល្មើសមួយបាន ចៅក្រមត្រូវបកស្រាយច្បាប់ឱ្យបានត្រឹមត្រូវស្របតាមស្មារតីរបស់អ្នកនិពន្ធ។ ចៅក្រមមិនអាចធ្វើការបកស្រាយតាមសទិសភាព ឬពង្រីកវិសាលភាពនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌបានទេ[19]។ ចំពោះការបកស្រាយតាមស្មារតីនៃអង្គប្រជុំរបស់រដ្ឋសភាវិញ គឺវាគ្រាន់តែជាការបកស្រាយមួយបែបដោយពឹងផ្អែកលើការពិភាក្សាដេញដោលរបស់វាគ្មិននៅពេលបញ្ចេញមតិក្នុងការអនុម័តសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នានាតែប៉ុណ្ណោះ។

ការបកស្រាយច្បាប់តាមសទិសភាពនេះ វាគឺជាការបកស្រាយដោយពន្លាតដំណោះស្រាយសម្រាប់ករណីប្រហាក់ប្រហែលណាមួយទៅលើករណីមួយផ្សេងទៀតដែលមិនមានចែងក្នុងច្បាប់ ដោយយោងលើមូលហេតុថាក្នុងសម្មតិកម្មទាំងពីនោះគឺមានហេតុផលដូចគ្នាដើម្បីឈានទៅដល់ដំណោះស្រាយដូចគ្នា។ រីឯការពង្រីកដែនអនុវត្តច្បាប់ គឺសំដៅទៅលើស្ថានភាពដែលចៅក្រមពង្រីកដែនអនុវត្តច្បាប់ ដូចជាករណី៖ ឧទាហរណ៍ នារីម្នាក់គាត់បានស្រឡាញ់គ្នាជាមួយបុរសម្នាក់ ហើយបុរសនោះគាត់បានសន្យាថានឹងរៀបការនឹងគ្នា។ ក្រោយមកនារីនោះបានប្រព្រឹត្តខុសប្រពៃណីជាមួយគ្នា ដោយសារមានការទុកចិត្តថាបុរសនោះជាអ្នកដែលស្មោះត្រង់ ហើយគង់តែរៀបអាពាហ៍ពិពាហ៍ជាមួយខ្លួននៅថ្ងៃណាមួយ។ មួយរយៈក្រោយមកទៀតស្រាប់តែបុរសនោះគាត់ដោះដៃចោលនារីនេះវិញដោយលើកហេតុផលផ្សេងៗ...។ ដូច្នេះ ក្នុងស្ថានភាពបែបនេះ សាធារណៈជនខ្លះគាត់អាចយល់ឃើញថា បុរសនោះក្បត់ទំនុកចិត្តហើយ ឬក៏ថាបុរសហ្នឹងបោកនារីនោះហើយ។ ប៉ុន្តែប្រសិនបើយើងពិនិត្យក្នុងគោលការណ៍ច្បាប់ គឺការឆបោក ក៏ដូចជាការរំលោភលើសេចក្តីទុកចិត្តត្រូវយកទៅអនុវត្តទាក់ទងជាមួយនឹងទ្រព្យសម្បត្តិប៉ុណ្ណោះ។ ក្នុងករណីបែបហ្នឹងខាងលើ ចៅក្រមអត់ត្រូវយកទៅបកស្រាយដោយពង្រីកវិសាលភាពនៃបទល្មើសឆបោក ឬបទល្មើសរំលោភទំនុកចិត្តទេ។

### ១.២.១.៣. ការអនុវត្តច្បាប់ព្រហ្មទណ្ឌ

ការអនុវត្តច្បាប់ព្រហ្មទណ្ឌ គឺជាការសម្តែងប្រតិកម្មរបស់សង្គមដែលឆ្លើយតបទៅនឹងជនល្មើស និងអំពើល្មើសក្នុងគោលដៅធានាឱ្យបាននូវស្ងប់សុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈជូនដល់សង្គមទាំង

[19] មាត្រា ៥, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

មូល។ ការអនុវត្តច្បាប់ព្រហ្មទណ្ឌនេះវាទាក់ទងទៅនឹងការបកស្រាយច្បាប់ព្រហ្មទណ្ឌ(**ក**)របស់ចៅក្រម,ការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងកាល(**ខ**) និងការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងដែនដី(**គ**)។

**ក. ការបកស្រាយច្បាប់ព្រហ្មទណ្ឌ**

ការបកស្រាយច្បាប់ព្រហ្មទណ្ឌនេះ វាគឺជាការបកស្រាយដើម្បីធានានូវការគោរពដល់គោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងគោលការណ៍នីត្យានុកូលភាពនៃទោស បានន័យថា ត្រូវមានបទបញ្ញត្តិច្បាប់ចែងទុកជាមុនថាអំពើនោះគឺជាបទល្មើស ទើបផ្តន្ទាទោសបានដើម្បីធានានូវការគោរព។ នៅក្នុងរឿងព្រហ្មទណ្ឌ ច្បាប់នេះមិនអនុញ្ញាតឱ្យចៅក្រមប្រើវិធីសាស្ត្រក្នុងការបកស្រាយតាមន័យជាការអនុវត្តបែបសទិសភាពដែរ ពោលគឺចៅក្រមត្រូវបកស្រាយក្រមព្រហ្មទណ្ឌ ឬច្បាប់ព្រហ្មទណ្ឌដែលជាបទបញ្ញត្តិមានចែងអំពីបទល្មើស និងទោសនេះក្នុងអត្ថន័យមួយយ៉ាងតឹងរឹង ដើម្បីកុំឱ្យឃ្លាតចាកពីគោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងនៃទោសផងដែរ។ ម្យ៉ាងទៀត ចៅក្រមមិនត្រូវយកច្បាប់មកអនុវត្តទេ ប្រសិនបើច្បាប់នោះចែងមិនច្បាស់លាស់។ វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។

**ខ. ការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងកាល**

- **គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ**

តាមគោលការណ៍នីត្យានុកូលភាព អំពើមួយមិនត្រូវបានចាត់ទុកជាបទល្មើសឡើយប្រសិនបើគ្មានច្បាប់ចែង ដែលនេះស្តែងឱ្យឃើញថា ច្បាប់ព្រហ្មទណ្ឌមិនមានលក្ខណៈប្រតិសកម្មឡើយ។ ជាទូទៅច្បាប់ព្រហ្មទណ្ឌអនុវត្តទោសតែចំពោះបទល្មើសណាដែលកើតក្រោយការចូលជាធរមានរបស់ច្បាប់តែប៉ុណ្ណោះ ហើយលែងមានអនុភាពគតិយុត្តរហូតដល់ពេលដែលច្បាប់ត្រូវបាននិរាករណ៍ កែប្រែ ឬជំនួសដោយច្បាប់ថ្មី។ នៅក្នុងរដ្ឋធម្មនុញ្ញក៏បានបង្ហាញឱ្យឃើញថា ច្បាប់ចូលជាធរមាននៅរាជធានីភ្នំពេញក្នុងរយៈពេល២០ថ្ងៃគត់ក្រោយពីថ្ងៃប្រកាសឱ្យប្រើ និងនៅទូទាំងប្រទេសក្នុងរយៈពេល២០ថ្ងៃគត់ក្រោយពីថ្ងៃប្រកាសឱ្យប្រើ[20]។ ក៏ប៉ុន្តែ ក្នុងករណីដែលច្បាប់ប្រកាសថាជាការប្រញាប់ ច្បាប់ត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេសក្រោយថ្ងៃប្រកាសឱ្យប្រើ។ ចំពោះបទបញ្ជារបស់អង្គការនីតិប្រតិបត្តិវិញ ជាគោលការណ៍ គឺជាលិខិតបទដ្ឋានដែលអាចយកទៅអនុវត្តបានភ្លាមក្រោយពេលដែលមន្ត្រីមានសមត្ថកិច្ចចុះហត្ថលេខាដោយមិនមានចិរវេលារង់ចាំដើម្បីឱ្យមានប្រសិទ្ធភាពអនុវត្តទេ។

គោលការណ៍ដែលគេឱ្យឈ្មោះថា គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ គឺវាមានអត្ថន័យថាច្បាប់ព្រហ្មទណ្ឌដែលចូលជាធរមាននៅថ្ងៃណាមួយជាកំណត់ជាទូទៅពុំមានអានុភាពគ្រប់គ្រងស្ថានភាពទាំងឡាយណាដែលបានកើតមុនពេលច្បាប់ចូលជាធរមានឡើយ ទោះបីជាថ្ងៃក្រោយមកទៀតស្រាប់តែមានច្បាប់កំណត់ថាអំពើដដែលជាបទល្មើសក៏ដោយក៏ចារីដែលបានប្រព្រឹត្តអំពើល្មើសពុំចាំបាច់ភ័យខ្លាចឡើយព្រោះថា

[20] មាត្រា ៩៣, រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ចុះថ្ងៃទី២៤ កញ្ញា ១៩៩៣ ។

ច្បាប់ដែលទើបតែបានចូលជាធរមានត្រូវមានអានុភាពអនុវត្តតែទៅលើសកម្មភាពដែលកើតឡើងចាប់ពីថ្ងៃដែលច្បាប់ចូលជាធរមានតែប៉ុណ្ណោះ[21]។

➢ **ករណីអញ្ញត្រកម្ម**

គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌមានអញ្ញត្រកម្ម(ករណីលើកលែង)ផងដែរប្រសិនបើអ្នកនីតិបញ្ញត្តិបានចែងយ៉ាងច្បាស់ទុកជាមុនថា ច្បាប់ដែលនឹងចូលជាធរមានត្រូវតែមានអានុភាពប្រតិសកម្ម បានន័យថា ច្បាប់ថ្មីត្រូវគ្រប់គ្រងទំនាក់ទំនងដែលបានកើតឡើងនៅមុនពេលច្បាប់ចូលជាធរមានទៅទៀត ឬក្នុងករណីដែលត្រូវយកមកអនុវត្តភ្លាមៗនោះគឺវាអាស្រ័យទាំងស្រុងថាតើច្បាប់នោះជាច្បាប់សារធាតុ[22] ឬមួយក៏ជាច្បាប់នីតិវិធី[23]។

គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ គឺអនុវត្តតែក្នុងករណីដែលច្បាប់ថ្មីចែងផ្តន្ទាទោសទៅលើបទល្មើសដែលស្រាលជាងច្បាប់ចាស់ប៉ុណ្ណោះ ដូចជា៖

- កែប្រែបទល្មើសពីឧក្រិដ្ឋមកជាមជ្ឈិម ឬពីបទមជ្ឈិមមកជាលហុជាដើម
- ជំនួសទោសគុកដោយទោសពិន័យ
- បន្ថយ ឬលុបចោលទោសគុក ឬពិន័យ
- បន្ថយ ឬលុបចោលទោសបន្ថែមដែលមានចែងកំណត់ដោយច្បាប់ចាស់
- លុបចោលបទល្មើសដែលកំណត់ដោយច្បាប់ចាស់។

គោលការណ៍មិនប្រតិសកម្មនេះគឺត្រូវយកមកអនុវត្តភ្លាមៗ ហើយការអនុវត្តបែបនេះអាចធ្វើទៅបានក្នុងករណីដែល៖

➢ ការអនុវត្តច្បាប់ដែលស្រាលជាង៖

- សំណុំរឿងនៃបទល្មើសត្រូវបានប្រព្រឹត្តមុនច្បាប់ថ្មីចូលជាធរមាន
- ពុំទាន់ត្រូវបានតុលាការសម្រេចផ្តន្ទាទោសតាមអំណាចសាលក្រម ឬសាលដីកាស្ថាពរនៅឡើយ ហើយប្រសិនបើការផ្តន្ទាទោសជាស្ថាពរហើយនោះទោះបីទោសដែលប្រកាសហើយនោះ

[21] នីតិព្រហ្មទណ្ឌទូទៅ, សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ(ឆ្នាំ ២០២២) ទំព័រ ១១៤ ។

[22] **ច្បាប់សារធាតុ ឬច្បាប់ព្រហ្មទណ្ឌគ្រឹះ** គឺជាច្បាប់ដែលកំណត់អំពីបទល្មើស និងពីទោសដែលត្រូវអនុវត្តលើបទល្មើស ព្រមទាំងលក្ខខណ្ឌនៃការទទួលខុសត្រូវរបស់ចារី។

[23] **ច្បាប់នីតិវិធី ឬច្បាប់ព្រហ្មទណ្ឌទម្រង់** គឺជាច្បាប់ដែលពាក់ព័ន្ធទៅនឹងការរៀបចំប្រព័ន្ធតុលាការ សមត្ថកិច្ចតុលាការ នីតិវិធីព្រហ្មទណ្ឌ ផ្លូវនៃបណ្តឹង ផ្លូវតវ៉ា ការអនុវត្តទោស អាជ្ញាយុកាលនៃបណ្តឹងអាជ្ញា និងអាជ្ញាយុកាលនៃទោស។

ធ្ងន់ធ្ងរយ៉ាងណាក៏ដោយក៏ត្រូវតែអនុវត្តដែរ។ បញ្ញត្តិថ្មីដែលចែងអំពីទោសធ្ងន់ជាងនឹងត្រូវអនុវត្តតែទៅលើអំពើដែលបានប្រព្រឹត្តក្រោយការចូលជាធរមាននៃបញ្ញត្តិនោះ[24]។

➢ ការអនុវត្តច្បាប់ដែលលុបចោលបទល្មើស

បទប្បញ្ញត្តិថ្មីដែលលុបចោលបទល្មើសណាមួយនោះត្រូវអនុវត្តភ្លាម។ អំពើដែលប្រព្រឹត្តនៅមុនបទប្បញ្ញត្តិនេះចូលជាធរមានមិនអាចត្រូវចោទប្រកាន់ទៀតឡើយ។ ការចោទប្រកាន់ដែលកំពុងប្រព្រឹត្តទៅនោះត្រូវបញ្ចប់ ប្រសិនបើការផ្តន្ទាទោសជាស្ថាពរត្រូវបានប្រកាសរួចហើយ ទោសដែលចេញអំពីការផ្តន្ទាទោសនេះមិនត្រូវអនុវត្តទេ ឬត្រូវតែឈប់អនុវត្ត[25]។

➢ ការអនុវត្តភ្លាមៗនៃច្បាប់នីតិវិធី

នៅពេលដែលមានច្បាប់នីតិវិធីចូលជាធរមានដែលទាក់ទងនឹងសមត្ថកិច្ចសាលាជម្រះក្តី ឬដំណើរការរឿងព្រហ្មទណ្ឌជាដើម ច្បាប់ប្រភេទនេះគឺត្រូវមានអានុភាពអនុវត្តភ្លាមចំពោះគ្រប់អំពើដែលកើតមុនហើយមិនទាន់ត្រូវបានជំនុំជម្រះតាមអំណាចសេចក្តីសម្រេចស្ថាពរនៅឡើយដែលគិតចាប់ពីថ្ងៃចូលជាធរមាន។ ប្រការដែលអនុវត្តបែបនេះ គឺច្បាប់ប្រភេទនេះពុំបានធ្វើឱ្យប៉ះពាល់ដល់អត្ថិភាពនៃបទល្មើសនោះទេ ហើយជាទូទៅច្បាប់ប្រភេទនេះគឺគ្រាន់តែមានបំណងស្វែងរកជនល្មើស និងស្វែងរកការពិតឱ្យបានឆាប់រហ័ស និងកាន់តែមានប្រសិទ្ធភាពតែប៉ុណ្ណោះ។ ហេតុនេះហើយ ទើបវាមិនបានធ្វើឱ្យប៉ះពាល់ដល់សុពលភាពនៃកិច្ចនីតិវិធីដែលធ្វើឡើងស្របតាមអំណាចច្បាប់ចាស់នោះទេ។ ការអនុវត្តភ្លាមនៃបទប្បញ្ញត្តិគឺគ្មានអានុភាពទៅលើសុពលភាពនៃកិច្ចនីតិវិធីដែលបានបំពេញសមស្របទៅតាមបទប្បញ្ញត្តិចាស់ឡើយ[26]។

**គ. ការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងដែនដី**

គោលការណ៍ដែនដីនៃច្បាប់ព្រហ្មទណ្ឌ គឺនៅក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសទាំងឡាយណាដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ដែនដីនៃព្រះរាជាណាចក្រកម្ពុជារួមបញ្ចូលទាំងលំហអាកាស និងសមុទ្ទដែលមានចំណងចងភ្ជាប់នឹងដែនដីនៃព្រះរាជាណាចក្រកម្ពុជា[27]។ បទល្មើសត្រូវបានចាត់ទុកថាប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា នៅពេលដែលអំពើណាមួយនៃបទល្មើសនោះបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា[28]។

[24] មាត្រា ១០ កថាខណ្ឌទី២, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។
[25] មាត្រា ៩ កថាខណ្ឌទី២, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។
[26] មាត្រា ១១, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។
[27] មាត្រា ១២, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។
[28] មាត្រា ១៣, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

ចំពោះបទល្មើសដែលបានប្រព្រឹត្តនៅក្នុងនាវាកម្ពុជា គឺច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្នុងនាវាដែលមានសញ្ជាតិខ្មែរ បើទោះបីជានាវានោះស្ថិតនៅទីណាក៏ដោយ[29]។ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្នុងនាវាបរទេសដែលអាជ្ញាធរកម្ពុជាបានទទួលការអនុញ្ញាតឱ្យពិនិត្យមើល ឬឱ្យចាប់នាវាតាមអំណាចនៃកិច្ចព្រមព្រៀងអន្តរជាតិ[30]។

ចំណែកបទល្មើសដែលបានប្រព្រឹត្តនៅអាកាសយានកម្ពុជា ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្នុងអាកាសយានដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា បើទោះបីជាអាកាសយានស្ថិតនៅទីណាក៏ដោយ[31]។ ម្យ៉ាងវិញទៀត ច្បាប់កម្ពុជាក៏ត្រូវអនុវត្តទៅលើបុគ្គលគ្រប់រូបដែលជាអ្នកផ្តើមគំនិត ឬអ្នកសមគំនិតនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលប្រព្រឹត្តនៅឯបរទេស ប្រសិនបើលក្ខខណ្ឌទាំងពីរត្រូវបានបំពេញដូចជា បទល្មើសត្រូវផ្តន្ទាទោសតាមច្បាប់កម្ពុជា និងតាមច្បាប់បរទេស និងអត្ថិភាពនៃបទល្មើសដែលត្រូវបានបញ្ជាក់ដោយសេចក្តីសម្រេចជាស្ថាពររបស់តុលាការបរទេស។

រីឯសមត្ថកិច្ចដោយឡែកចំពោះបទឧក្រិដ្ឋដោយឡែក គឺច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ហើយបទល្មើសនោះជា[32]៖

- បទល្មើសដែលប្រឆាំងនឹងសុវត្ថិភាពនៃព្រះរាជាណាចក្រកម្ពុជា
- បទល្មើសក្លែងត្រាផ្លូវការនៃព្រះរាជាណាចក្រកម្ពុជា
- បទល្មើសក្លែងរូបិយវត្ថុ និងធនបត្រជាតិដែលមានតម្លៃស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា
- បទល្មើសប្រឆាំងនឹងភ្នាក់ងារទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា
- បទល្មើសប្រឆាំងនឹងទីតាំងទូត ឬកុងស៊ុលនៃប្រះរាជាណាចក្រកម្ពុជា។

ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើគ្រប់បទឧក្រិដ្ឋដែលប្រព្រឹត្តដោយពលរដ្ឋខ្មែរនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទមជ្ឈិមដែលប្រព្រឹត្តដោយពលរដ្ឋខ្មែរនៅក្នុងប្រទេសក្រៅណាមួយ ប្រសិនបើអំពើនោះត្រូវផ្តន្ទាទោសតាមច្បាប់នៃប្រទេសនោះ បើទោះបីជាជនជាប់ចោទនោះបានទទួលសញ្ជាតិខ្មែរក្រោយអំពើដែចោទប្រកាន់នេះក៏ដោយ[33]។

---

29 មាត្រា ១៤, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

30 មាត្រា ១៥, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

31 មាត្រា ១៦, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

32 មាត្រា ២២, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

33 មាត្រា ១៩, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

ច្បាប់កម្ពុជាត្រូវបានអនុវត្តទៅលើគ្រប់បទឧក្រិដ្ឋដែលប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដោយពលរដ្ឋខ្មែរ ឬដោយជនបរទេសទៅលើជនរងគ្រោះដែលមានសញ្ជាតិខ្មែរនៅក្នុងពេលដែលបទល្មើសនោះត្រូវបានប្រព្រឹត្ត[34]។

**១.២.២. ធាតុសត្យានុម័ត ឬធាតុសម្ភារៈ**

ធាតុសត្យានុម័ត ឬអាចហៅម្យ៉ាងទៀតថាធាតុសម្ភារៈ គឺជាការប្រព្រឹត្តអំពើល្មើសនឹងច្បាប់ និងមានផលវិបាក ឬលទ្ធផលដែលកើតឡើងពីអំពើល្មើសនោះពិតប្រាកដ[35]។ មានន័យថា ជាសកម្មភាពមួយ ឬកាយវិការរបស់ជនល្មើសដែលស្តែងឡើងក្រោមរូបភាពសកម្មក្តី អកម្មក្តី ហើយសកម្មភាពទាំងនោះវាបានបង្កើតឱ្យមានជាព្យសនៈដែលស្តែងចេញមកខាងក្រៅ។ ឧទាហរណ៍ ជនល្មើសបានប្រើកាំភ្លើងបាញ់ទៅលើជនរងគ្រោះ ដូច្នេះស្លាកស្នាមនៅលើដងខ្លួនជនរងគ្រោះគឺត្រូវតែជាស្នាមធ្លុះដោយសារគ្រាប់កាំភ្លើង មិនមែនស្នាមប៉ូវថៅ ឬកាំបិតនោះទេ ។

**១.២.២.១. អំពើ**

នៅក្នុងអំពើជាសត្យានុម័តនេះ វាគឺសំដៅលើអំពើទាំងឡាយដែលប្រព្រឹត្តក្រោមរូបភាពជាអំពើជាសកម្ម **(ក)** ឬអំពើអកម្ម**(ខ)** ដែលមានចរិតលក្ខណៈគ្រោះថ្នាក់ដល់សង្គម[36]។

**ក. អំពើសកម្ម**

អំពើសកម្ម គឺជាអំពើដែលស្តែងចេញពីសកម្មភាពនៃកាយវិការរបស់ចារី មានន័យថា ចារីបានប្រព្រឹត្តអំពើចេញជាក់ស្តែងដែលអ្នកណាក៏មើលឃើញថាបុគ្គលនោះបានប្រព្រឹត្តដែរ។

ឧទាហរណ៍ៈ ករណីអំពើមនុស្សឃាត ឬបទឃាតកម្ម[37] គឺនៅពេលដែលជនរងគ្រោះម្នាក់ទៅផ្តាច់ជីវិតរបស់ជនម្នាក់ទៀត ដែលនេះគឺវាបានបង្ហាញនូវសកម្មភាពជាសត្យានុម័តមកខាងក្រៅបញ្ជាក់ថាជននោះបានប្រព្រឹត្តអំពើ។

ខុសពីអំពើសកម្ម អំពើអកម្មជាប្រភេទមួយផ្សេងទៀតដែលចាត់ទុកថាជាអំពើមួយរបស់ចារីដែលច្បាប់បានកំណត់។

**ខ. អំពើអកម្ម**

អំពើអកម្ម គឺជាអំពើដែលជនម្នាក់មិនធ្វើទៅតាមការកំណត់ជាកាតព្វកិច្ចដែលច្បាប់តម្រូវឱ្យធ្វើ។ អំពើនេះគឺទាល់តែច្បាប់មានចែងជាក់លាក់ថាកាតព្វកិច្ចណាខ្លះដែលបុគ្គលគ្រប់រូបក្នុងសង្គម ឬក៏បុគ្គលណាខ្លះត្រូវ

[34] មាត្រា ២០, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

[35] វចនានុក្រមពាក្យច្បាប់ សាស្ត្រាចារ្យ ហ៊ីង ធីរិទ្ធិ។

[36] នីតិព្រហ្មទណ្ឌពិសេស, សាស្ត្រាចារ្យ ជួន ប៊ុនធី (ឆ្នាំ ២០២១)។

[37] មាត្រា ១៩៩, ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

បំពេញ ហើយនៅពេលដែលមិនបំពេញតាមច្បាប់កំណត់ទេ បុគ្គលនេះត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌ មានន័យថា ត្រូវតែទទួលខុសត្រូវពីអំពើដែលជាបទល្មើសនេះ។

ឧទាហរណ៍៖ បទបដិសេធការផ្តល់ចម្លើយ[38]នៅក្នុងក្រមព្រហ្មទណ្ឌ ត្រង់នេះគឺជាអំពើអកម្មដែលយើងបញ្ជាក់ថា ជនម្នាក់នោះបានដឹង ឬបានស្គាល់អ្នកដែលប្រព្រឹត្តបទល្មើស ហើយចៅក្រមបានហៅមកសួរ តែប្រកែកមិនព្រមឆ្លើយនឹងសំណួរដែលចៅក្រមបានសួរពីរឿងនោះដល់ខ្លួន ករណីនេះ គឺច្បាប់បានចែងកំណត់ថាអ្នកដែលបដិសេធការផ្តល់ចម្លើយហ្នឹង ត្រូវមានកាតព្វកិច្ចឆ្លើយទៅតាមសំណួររបស់ចៅក្រម បើគាត់ប្រកែកមិនព្រមឆ្លើយអ៊ីចឹងទេនោះគឺត្រូវមានទោសដាក់ពន្ធនាគារ និងពិន័យជាប្រាក់ទៅតាមបញ្ញត្តិនៃក្រមព្រហ្មទណ្ឌ។

រាល់អំពើដែលចារីបានប្រព្រឹត្តរួចទៅ វាបានធ្វើឱ្យមានការអន្តរាយ ឬការខូចខាតដែលកើតមានឡើងដោយសារតែអំពើនោះ មិនថាជាទ្រព្យសម្បត្តិ ឬលើរូបរាងកាយឡើយ។

**១.២.២.២. ព្យសនកម្ម**

ព្យសនកម្ម គឺជាការខូចខាត ឬសេចក្តីវិនាសអន្តរាយដល់រូបកាយក្តី ដល់សម្ភារៈក្តី ដល់ផ្លូវចិត្តក្តីដែលបណ្តាលមកពីអំពើរបស់អ្នកដទៃ[39]។

ឧទាហរណ៍៖ បុគ្គល **ក** បានដាល់មុខបុគ្គល **ខ** មួយដៃចំភ្នែក។ ដូចនេះស្នាមខៀវភ្នែកបុគ្គល **ខ** គឺជាព្យសនកម្មនេះឯងដែលបណ្តាលមកពីបុគ្គល **ក** ដាល់ចំ។

អ្វីដែលកើតឡើងខាងលើនេះវាត្រូវតែមានទំនាក់ទំនងគ្នាទើបអាចចាត់ទុកថាមានការអន្តរាយកើតឡើងមួយគឺវាបានចេញពីការធ្វើអំពើមួយពិតប្រាកដមែន ឬអាចនិយាយថាមានហេតុទើបមានផល។

**១.២.២.៣. ទំនាក់ទំនងរវាងអំពើ និងព្យសនកម្ម ឬចំណងហេតុ និងផល**

ដើម្បីកំណត់អំពើណាមួយថាជាបទល្មើសបានវាទាល់តែអំពើនោះវាបានស្តែងចេញឱ្យឃើញថាបានបង្កទៅជាការខូចខាត ឬព្យសនកម្មមួយដែលស៊ីសង្វាក់នឹងគ្នា។

ឧទាហរណ៍៖ បុគ្គលម្នាក់គ្រាន់តែគិតក្នុងចិត្តថាចង់ប្រព្រឹត្តអំពើណាមួយដែលជាបទល្មើសព្រហ្មទណ្ឌដែលច្បាប់ហាមឃាត់ក៏ដោយ ក៏មិនអាចឱ្យជននោះទទួលខុសត្រូវព្រហ្មទណ្ឌ ឬដាក់ទណ្ឌកម្មទៅលើជននោះបានឡើយ វាទាល់តែមានអំពើជាសត្យានុម័តដែលធ្វើឡើតដោយបុគ្គលនោះ។ ទាក់ទងជាមួយនឹងអំពើនេះដែរ បើទោះជាមានអំពើក៏ពិតមែន ប្រសិនជាមិនមានព្យសនកម្មទេ ក៏មិនអាចធ្វើការដាក់ទណ្ឌកម្មដល់ជននោះដែរ។ ដូចនេះ ត្រូវតែមានព្យសនកម្ម ហើយព្យសនកម្មនេះវាស្តែងចេញពីអំពើដែលធ្វើឱ្យដល់សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គម។

---

[38] មាត្រា ៥៣៧, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

[39] វចនានុក្រមពាក្យច្បាប់ សាស្ត្រាចារ្យ ហ៊ីង ធីរិទ្ធិ (ទំព័រ ២៧៨)។

មួយវិញទៀត គឺត្រូវមានចំណងទាក់ទងរវាងការខូចខាត ឬក៏រវាងព្យសនកម្មជាមួយនឹងអំពើ ប្រសិនជាអំពើមួយផ្សេង និងការខូចខាតមួយកើតចេញផ្សេងក្រៅពីអំពើនោះ ក៏យើងមិនអាចយកអំពើរបស់បុគ្គលម្នាក់ដែលមិនបានធ្វើឱ្យមានការខូចខាតនេះមកដាក់ទណ្ឌកម្ម ឬក៏ទទួលខុសត្រូវព្រហ្មទណ្ឌដែរ។ អ៊ីចឹងទាក់ទងជាមួយនឹងព្យសនកម្មដែលត្រូវតែមានចំណងទំនាក់ទំនងជាមួយអំពើនេះគឺចង់បញ្ជាក់ថា ហេតុដែលកើតចេញមកនេះវាត្រូវតែកើតចេញពីអំពើណាមួយ ឬក៏ផលដែលកើតចេញត្រូវតែបណ្តាលមកពីអំពើណាមួយដែលបានប្រព្រឹត្តឡើងដោយបុគ្គលណាម្នាក់។

ឧទាហរណ៍៖ **ក** បានចាក់ **ខ** មួយកាំបិតបណ្តាលឱ្យ **ខ** ស្លាប់។ ដូចនេះ ចំណងទាក់ទងហេតុ និងផលនៅទីនេះគឺ៖

- ហេតុ៖ **ក** យកកាំបិតទៅចាក់ **ខ**។
- ព្យសនកម្ម៖ **ខ** ត្រូវបាន **ក** ចាក់មួយកាំបិទស្លាប់។
- ចំណងទាក់ទងហេតុ និងផលគឺ **ខ** ស្លាប់ដោយសារ **ក** ចាក់មួយកាំបិត។

### ១.២.២.៤. ដំណាក់កាលនៃការប្រព្រឹត្តបទល្មើស

ការប្រព្រឹត្តបទល្មើសមួយមានច្រើនដំណាក់កាល ដែលវាត្រូវរៀបតាមលំដាប់ចាប់ពីដំបូងមករហូតដល់ដំណាក់កាលចុងក្រោយមួយដែលឈានទៅរកគោលបំណងរបស់ចារី ដែលគេចែកជា ៤ ដំណាក់កាល រួមមានដំណាក់កាលនៃការគិត និងការសម្រេចចិត្តប្រព្រឹត្តបទល្មើស(**ក**) ដំណាក់កាលនៃការត្រៀមរៀបចំប្រព្រឹត្តបទល្មើស(**ខ**) ដំណាក់កាលនៃការចាប់ផ្តើមប្រព្រឹត្តបទល្មើស(**គ**) និងចុងក្រោយគឺដំណាក់កាលនៃការសម្រេចនូវបទល្មើស ឬបើបទល្មើសមិនបានសម្រេចក្លាយទៅជាការប៉ុនប៉ង(បទល្មើសប៉ុនប៉ង) (**ឃ**)។

#### ក. ដំណាក់កាលនៃការគិត និងការសម្រេចចិត្តប្រព្រឹត្តបទល្មើស

នៅដំណាក់កាលនេះ គេហៅថាជាដំណាក់កាលដំបូង ព្រោះថាវាជាដំណាក់កាលដែលអាចឈានទៅរកការប្រព្រឹត្តបទល្មើស ឬប៉ុនប៉ងប្រព្រឹត្តបទល្មើសបាន។

ជាទូទៅ ការគិតពិចារណារបស់មនុស្ស ទោះបីជាការគិតនោះគឺជាការគិតនៅក្នុងន័យប្រព្រឹត្តបទល្មើសក៏ដោយ ហើយមានគំនិតទុច្ចរិតក៏ពិតមែន និងបានគិតអំពីស្ថានភាពថាត្រូវប្រព្រឹត្តបទល្មើសក៏ពិតមែន ប៉ុន្តែច្បាប់មិនទាន់ផ្តន្ទាទោសចំពោះស្ថានភាពនៃការគិតនោះទេ ពោលគឺលុះត្រាតែបទល្មើសហ្នឹងស្តែងចេញជារូបរាងមកខាងក្រៅ ហើយបង្កឱ្យមានព្យសនកម្មទើបបានច្បាប់ត្រូវផ្តន្ទាទោស។

ឧទាហរណ៍៖ នៅក្នុងភូមិមានគេរាំធុងបាស។ **ក** បានរាំជាន់ជើង **ខ** ។ ភ្លាមនោះ **ខ** បានវ៉ៃទៅលើ **ក** បែកក្បាល។ **ក** បានខឹងនឹង **ខ** ហើយក៏គិតចង់សងសឹកនឹង **ខ** វិញគាត់បានគិតហើយសម្រេចចិត្តថាគាត់នឹងយកដំបងសំពងក្បាល **ខ** វិញឱ្យបាននៅថ្ងៃណាមួយ។ ដូច្នេះ ក្នុងដំណាក់កាលនេះគាត់មានការសម្រេចចិត្តប្រព្រឹត្ត

បទល្មើស ក៏ប៉ុន្តែនៅក្នុងស្ថានភាពនៃដំណាក់កាលយ៉ាងដូច្នេះ ច្បាប់មិនទាន់ចែងផ្តន្ទាទោសចំពោះអ្នកដែលគិត និងសម្រេចចិត្តប្រព្រឹត្តបទល្មើសត្រឹមប៉ុណ្ណេះទេគឺដោយសារតែ **ទី១**បទល្មើសនេះពុំទាន់មានរូបរាងច្បាស់លាស់ចេញមកខាងក្រៅ និង**ទី២**សង្គមពុំទាន់បានទទួលរងព្យសនកម្ម។

បើគ្រាន់តែការគិតមិនទាន់អាចបង្កើតបានជាបទល្មើសផ្តន្ទាទោសបានទេ តើដំណាក់កាលបន្ទាប់អាចនឹងកំណត់ជាបទល្មើសបានឬអត់?

### ខ. ដំណាក់កាលនៃការត្រៀមរៀបចំប្រព្រឹត្តបទល្មើស

ដំណាក់កាលនេះគឺជាដំណាក់កាលទីពីរ។ នៅក្នុងដំណាក់កាលនេះយើងឃើញថា បុគ្គលដែលគាត់បានគិត និងសម្រេចចិត្តថានឹងប្រព្រឹត្តបទល្មើសទៅហើយនោះ គាត់នឹងមានការត្រៀមរៀបចំក្នុងការប្រព្រឹត្តបទល្មើសទុកជាមុន។ ជាក់ស្តែង(ដូចឧទាហរណ៍ដែលរៀបរាប់ខាងលើ) **ក** គាត់គិតថាគាត់នឹងសងសឹកវិញឱ្យបាន តែដោយសារគាត់មាឌតូចជាងគេ គាត់ក៏ទៅរកដំបង រួចទៅពិនិត្យស្ថានភាពនៃការចេញចូលរបស់ **ខ** ថាគាត់យប់ឡើងចូលផ្ទះម៉ោងប៉ុន្មាន? ចេញចូលផ្លូវណាខ្លះ? ដើរលេងកន្លែងណាខ្លះ?...។ ដូច្នេះឃើញថា សកម្មភាពបែបនេះគឺជាការត្រៀមរៀបចំប្រព្រឹត្តបទល្មើស ព្រោះគាត់បានត្រៀមទាំងដំបងដើម្បីនឹងវាយទៅលើ **ក** នោះវិញទៀត។ ផ្ទុយទៅវិញ ប្រសិនបើជាគ្រាន់តែយកដំបងមកដាក់ក្នុងផ្ទះ ហើយស៊ើបដឹងពីដំណើរការទៅមករបស់ **ខ** នោះថាទៅណាខ្លះ និងទៅដើរលេងជាមួយអ្នកណា។ល។ ដូច្នេះច្បាប់បានចាត់ទុកថា ដំណាក់កាលនេះគឺពុំទាន់បង្កើតបានជាបទល្មើសដែលត្រូវផ្តន្ទាទោសនៅឡើយទេ ដោយសារតែគ្មានជនរងគ្រោះដែលត្រូវទទួលរងព្យសនកម្ម(ការខូចខាត)។ ម្យ៉ាងវិញទៀត នៅក្នុងស្ថានភាពប្រភេទនេះ រូបរាងចេញមកខាងក្រៅក៏មិនទាន់ច្បាស់ រីឯការសម្រេចចិត្តវិញថ្វីត្បិតតែមាន ក៏ប៉ុន្តែ **ក** អាចសម្រេចផ្លាស់ប្តូរនូវការប្រព្រឹត្តបទល្មើសរបស់ខ្លួនផងដែរ ពីព្រោះអាចថាគាត់យកដំបងមកផ្ទះហើយតែគាត់មិនយកដំបងនោះទៅប្រព្រឹត្តបទល្មើសទេ បែរជាយកមកធ្វើឧសដុតវិញក៏ថាបាន។

ទាំងពីរដំណាក់កាលនេះបានចាប់ផ្តើមមានទៅហើយតែនៅតែមិនទាន់អាចចាត់ចូលជាបទល្មើសផ្តន្ទាទោសណាមួយបាននៅឡើយ គឺត្រូវពិនិត្យលើដំណាក់កាលបន្តទៀតដែលជាដំណាក់កាលនៃការចាប់ផ្តើមប្រព្រឹត្តបទល្មើស។

### គ. ដំណាក់កាលនៃការចាប់ផ្តើមប្រព្រឹត្តបទល្មើស

ដំណាក់កាលនៃការចាប់ផ្តើមនេះវាគឺជាដំណាក់កាលទីបី។ នៅពេលដែលជនល្មើសចាប់ផ្តើមធ្វើសកម្មភាពបានន័យថាគាត់ដឹងអស់រលីងហើយ គាត់ក៏រៀបចំដើម្បីធ្វើសកម្មភាពដោយគាត់យកដំបងទៅចាំពួនស្ទាក់ដើម្បីធ្វើការវាយប្រហារទៅលើបុគ្គលដែលគាត់ចង់សងសឹក។ តាមឧទាហរណ៍ខាងលើដដែល **ក** គាត់បានយកដំបងទៅចាំពួនស្ទាក់ដើម្បីវាយ **ខ** ។ ការដែលយកដំបងហើយធ្វើការរង់ចាំវាយប្រហារនៅក្នុងស្ថានភាពនេះ គឺគេ

ចាប់ផ្ដើមគិតពិចារណាថាបានឈានចូលទៅក្នុងដំណាក់កាលថ្មីមួយទៀតដែលតាមទ្រឹស្ដីគេឱ្យឈ្មោះថាជាដំណាក់កាលនៃការចាប់ផ្ដើមប្រព្រឹត្តបទល្មើស បានន័យថា នៅពេលដែលជនរងគ្រោះដែលជាបុគ្គល **ខ** នេះបានជិះម៉ូតូទៅដល់កន្លែងដែល **ក** ពួនស្ទាក់ ហើយពេលនោះ **ក** គាត់ក៏យកដំបងមកវាយប្រហារទៅលើ **ខ** នោះភ្លាមតែម្ដង។

មានការចាប់ផ្ដើមប្រព្រឹត្តទៅហើយយើងគ្រាន់តែដឹងថាវាជាបទល្មើស តែមិនទាន់បានដឹងថាអ្វីដែលគាត់បានប្រព្រឹត្តនោះវាបានសម្រេច ឬមិនបានសម្រេចនៅឡើយទេ។

**ឃ. ដំណាក់កាលនៃការសម្រេចនូវបទល្មើស ឬបទល្មើសមិនបានសម្រេច(ប៉ុនប៉ង)**

ដំណាក់កាលចុងក្រោយនេះវាជាដំណាក់កាលទីបួន បានសេចក្ដីថា យោងតាមអង្គហេតុខាងលើដែលបានលើកឡើង នៅពេលដែលយើងពិនិត្យទៅលើស្ថានភាពបែបនេះឃើញថា **ក** គាត់បានវាយប្រហារទៅលើជនរងគ្រោះ **ខ** បណ្ដាលឱ្យគាត់ស្លាប់ យើងថាវាជាបទល្មើសបានសម្រេច។ ផ្ទុយទៅវិញប្រសិនបើ **ក** គាត់បានវាយ **ខ** រួចទៅហើយ ស្រាប់តែ **ខ** អត់ស្លាប់ទេ អ៊ីចឹងបទល្មើសនេះជាការប៉ុនប៉ងឃាតកម្ម។ ការប៉ុនប៉ងនេះគឺវាកើតមានក្រោយពេលមានការចាប់ផ្ដើមប្រព្រឹត្តបទល្មើស ហើយបទល្មើសនេះមិនបានសម្រេចឡើយ។

អាចចាត់ទុកបទល្មើសមួយថាជាបទល្មើសប៉ុនប៉ងបានវាទាល់តែមានលក្ខខណ្ឌពីរយ៉ាងៈ

- **លក្ខខណ្ឌទី១** ៖ ចារីបានចាប់ផ្ដើមបទល្មើសរបស់ខ្លួន ពោលគឺចារីបានប្រព្រឹត្តអំពើដែលមានគោលបំណងដោយផ្ទាល់ដើម្បីប្រព្រឹត្តបទល្មើស។
- **លក្ខខណ្ឌទី២** ៖ ចារីមិនបានបញ្ឈប់អំពើរបស់ខ្លួនទៅវិញដោយស្ម័គ្រចិត្តឡើយ តែត្រូវបានរាំងស្ទះ ឬមួយក៏អាក់ខានដោយឥទ្ធិពលនៃកាលៈទេសៈក្រៅឆន្ទៈរបស់ខ្លួន។

ឧទាហរណ៍ដូចជា ចារីគាត់បានត្រៀមលក្ខណៈនោះរួច និងបានទៅពួនស្ទាក់រួចរាល់ទៅហើយ ម្យ៉ាងទៀតគាត់បានយកដំបងទៅតាមខ្លួនសម្រាប់ទុកវាយប្រហារលើជនរងគ្រោះហើយ បែរជាគាត់បានបញ្ឈប់អំពើរបស់គាត់ដោយស្ថានភាពក្រៅឆន្ទៈរបស់គាត់ ឬមួយត្រូវបានអាក់ខានដោយសារមានកាលៈទេសៈពីខាងក្រៅបានទៅបង្អាក់មិនឱ្យគាត់បានធ្វើសកម្មភាពកើត ដូចជានៅពេលដែលគាត់ត្រៀមនោះស្រាប់តែមានលេចមុខនគរបាលយុត្តិធម៌ដើរល្បាតក្បែរនោះ គាត់ក៏ដកឃ្លាទៅវិញ។ ការដកឃ្លាទៅវិញលែងប្រព្រឹត្តបទល្មើសនេះ មិនមែនជាការដកឃ្លានៅក្នុងស្ថានភាពនៃការបញ្ឈប់ទៅវិញដោយស្ម័គ្រចិត្តទេ មានន័យថាអាក់ខានទៅវិញដោយកាលៈទេសៈក្រៅឆន្ទៈរបស់គាត់។ អ៊ីចឹងការអាក់ខានក្នុងការសម្រេចបទល្មើសប្រភេទនេះក៏ជាការអាក់ខានក្រៅឆន្ទៈដែរ ដូច្នេះគាត់ត្រូវទទួលខុសត្រូវពីការប៉ុនប៉ង។ ក៏ប៉ុន្តែ ចំពោះអំពើដែលគាត់បានបញ្ឈប់ទៅវិញដោយស្ម័គ្រចិត្ត ច្បាប់មិនធ្វើការផ្ដន្ទាទោសលើជននោះទេ ដូចជា នៅពេលដែលគាត់កំពុងចាំពួនស្ទាក់វាយប្រហារលើជនរងគ្រោះនោះ ចាំយូរពេកគាត់អាចនឹងគិតឡើងវិញ ហើយអាចនឹងបញ្ឈប់សកម្មភាពរបស់ខ្លួនវិញដោយស្ម័គ្រចិត្ត ដោយសារគាត់គិត

ថា ប្រសិនបើគាត់សម្លាប់មនុស្សនឹងត្រូវទទួលទោសធ្ងន់ពេលគេចាប់គាត់បាន ឬគាត់គិតថាការសម្លាប់អ្នកដទៃគឺជាអំពើបាបនាំឱ្យកើតជាតិក្រោយមានកម្មពារ។ល។ ធ្វើឱ្យគាត់អាចសម្រេចចិត្តដកឃ្លាមកវិញ ហើយក៏បញ្ឈប់ការប្រព្រឹត្តបទល្មើសទៅជនរងគ្រោះ។ ដូច្នេះក្នុងស្ថានភាពដែលគាត់បានបញ្ឈប់សកម្មភាពដោយស្ម័គ្រចិត្តបែបនេះ គឺច្បាប់កំណត់ថាមិនធ្វើការផ្តន្ទាទោសដល់ជននោះទេ។

➢កំណត់សម្គាល់អំពី **ការប៉ុនប៉ង**

នេះគឺពាក់ព័ន្ធជាមួយនឹងដំណាក់កាលនៃការប្រព្រឹត្តបទល្មើស ហើយសូមបញ្ជាក់ជូនផងដែរថានៅក្នុងការប៉ុនប៉ងដែលអាចមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌគឺចំពោះ បទឧក្រិដ្ឋ គ្រប់រាល់ការប៉ុនប៉ងទាំងអស់ត្រូវតែមានទោស ឬត្រូវតែផ្តន្ទាទោស។ ក៏ប៉ុន្តែចំពោះការប៉ុនប៉ងក្នុងបទល្មើស មជ្ឈិម វិញ ដើម្បីអាចផ្តន្ទាទោសលើករណីប៉ុនប៉ងលើបទមជ្ឈិមបានលុះត្រាតែមានច្បាប់ចែងចង្អុលច្បាស់លាស់ថា ការប៉ុនប៉ងនោះ គឺត្រូវផ្តន្ទាទោសយ៉ាងច្បាស់។ ឧទាហរណ៍ នៅក្នុង បទល្មើសលួច[40] ដោយសារតែបទល្មើសលួចគឺជាប្រភេទបទល្មើសមជ្ឈិម[41] ដូច្នេះហើយដើម្បីអាចឱ្យការប៉ុនប៉ងត្រូវបានផ្តន្ទាទោសទៅតាមមាត្រាទាំងពីរនេះបានអំពីការប៉ុនប៉ងប្រព្រឹត្តអំពើលួច គឺលុះត្រាតែមានច្បាប់ចែងចង្អុលដែលនៅក្នុងក្រមព្រហ្មទណ្ឌ។ ក្នុងក្រមព្រហ្មទណ្ឌចែងចង្អុលយ៉ាងច្បាស់ថា" *ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងនៅក្នុងផ្នែកនេះត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ* "[42] មានន័យថា ត្រូវតែមានច្បាប់ចែងចង្អុលថា ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមត្រូវតែមានទោសទើបនៅក្នុងករណីនេះការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមអាចត្រូវផ្តន្ទាទោសបាន។ ចំណែកចុងក្រោយនោះគឺ ចំពោះការប៉ុនប៉ងប្រព្រឹត្តបទលហុ គ្មានទោសទេ[43]។

### ១.២.៣. ធាតុអត្តនោម័ត ឬធាតុចិត្តសាស្ត្រ

ធាតុផ្សំអត្តនោម័តគឺជាកិរិយាផ្លូវចិត្តរបស់ជនល្មើសចំពោះអំពើបង្កគ្រោះថ្នាក់ដល់សង្គមដែលគេបានប្រព្រឹត្ត និងចំពោះបច្ច័យដែលកើតឡើងពីអំពើនោះ។ មែនទែនទៅ អំពើជាធាតុផ្សំសត្យានុម័តតែមួយវាគឺពុំមានលក្ខណៈគ្រប់គ្រាន់ដើម្បីបង្កើតឱ្យបានជាបទល្មើសទេ។ ការកំណត់បទល្មើសតែងតែផ្អែកលើកំហុសដែលកើតចេញពីទឹកចិត្តរបស់ចារី។ នៅត្រង់នេះហៅថា ធាតុផ្សំអត្តនោម័តនៃបទល្មើសដែលជាផ្នែកខាងក្នុងនៃបទល្មើស ដូច្នេះ បទល្មើសមួយវាត្រូវតែពាក់ព័ន្ធទៅនឹងកំហុសដែលជាកិរិយាផ្លូវចិត្តរបស់ចារី[44]។

---

[40] មាត្រា ៣៥៣, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

[41] មាត្រា ៣៥៦, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

[42] មាត្រា ៣៦១, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

[43] មាត្រា ២៧, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ចែងក្នុងកថាខណ្ឌចុងក្រោយនៃមាត្រានេះថា " ការប៉ុនប៉ងក្នុងបទលហុពុំទទួលការផ្តន្ទាទោសទេ " ។

[44] នីតិព្រហ្មទណ្ឌទូទៅខ្មែរ, សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ(ឆ្នាំ ២០២២) ទំព័រ ១៣៧ ។

នៅចំណុចនេះយើងនឹងបានដឹងថាតើអ្វីទៅដែលជាកំហុសនោះ?ហើយតើកំហុសនោះមានអ្វីខ្លះ?

**១.២.៣.១. កំហុស**

កំហុសនៅទីនេះចង់សំដៅលើកិរិយានៃការគិតមុននឹងប្រព្រឹត្តបទល្មើសណាមួយរបស់ចារី ហើយវាផ្អែកលើឆន្ទៈរបស់ចារីផងដែរ ពោលគឺដើម្បីបង្កើតឱ្យបានជាបទល្មើស ចារីត្រូវតែប្រព្រឹត្តអំពើដោយមានកំហុស។

ជាដំបូងកំហុសអាចផ្អែកលើឆន្ទៈដែលមានគោលដៅច្បាស់លាស់ដោយសំដៅទៅរកគោលដៅខុសច្បាប់ណាមួយ ពោលគឺចារីពិតជាមានឆន្ទៈ និងដឹងពីលទ្ធផលខុសច្បាប់នៃអំពើរបស់ខ្លួនដែលគេហៅថា កំហុសចេតនា(**ក**) ហើយនៅក្នុងករណីខ្លះទៀតកំហុសសំដៅទៅលើស្ថានភាពដែលមិនមានឆន្ទៈគ្រប់គ្រាន់ ឬការមិនប្រុងប្រយ័ត្នគ្រប់គ្រាន់ដើម្បីជៀសវាងនូវលទ្ធផលខុសច្បាប់ដែលត្រង់នេះគេហៅថា កំហុសអចេតនា(**ខ**)។

**ក. កំហុសចេតនា**

នៅក្នុងការប្រព្រឹត្តអំពើរបស់បុគ្គលម្នាក់ត្រូវតែមានការបញ្ជាក់អំពីឆន្ទៈរបស់បុគ្គលនោះផងដែរថាគាត់ចង់ប្រព្រឹត្តអំពើនោះ ហើយគាត់បានដឹងថាអំពើនោះគឺជាអំពើមួយដែលបង្កគ្រោះថ្នាក់ដល់សង្គមដែលច្បាប់បានហាមឃាត់។ អ៊ីចឹងទាក់ទងជាមួយនឹងបញ្ហានេះ គឺគាត់បានដឹងទុកជាមុនថាអំពើហ្នឹងពិតជាច្បាប់បានហាមឃាត់រួចហើយ តែគាត់នៅតែមានចេតនាប្រព្រឹត្តទៀត ឬទោះបីគាត់មិនបានមើល គាត់មិនបានអាន គាត់មិនបានដឹង ឬមិនបានសិក្សាច្បាប់ហ្នឹងក៏ដោយគឺច្បាប់បានសន្មត់ទុកតែម្តងថាគាត់ត្រូវតែបានដឹង ព្រោះគាត់ជាអ្នករស់នៅក្នុងសង្គមមួយដែរ[45]។

ក្រមព្រហ្មទណ្ឌចែងថា ពុំមានបទល្មើសទេប្រសិនបើគ្មានចេតនាប្រព្រឹត្ត[46]។ ហេតុនេះ ចេតនា គឺជាធាតុផ្សំអត្តនោម័តនៃបទល្មើសដោយចេតនា។ ចេតនាប្រព្រឹត្តបទល្មើសត្រូវរួមផ្សំដោយ៖

**-ចេតនាសម្រេចបទល្មើស** គឺជាចេតនារបស់បុគ្គលម្នាក់ដែលខ្លួនមានសេរីភាព និងមនសិការគ្រប់គ្រាន់ក្នុងការស្វែងរកលទ្ធផលដែលច្បាប់ព្រហ្មទណ្ឌហាមឃាត់ ឬនិយាយម្យ៉ាងទៀតថា ជាចេតនាចង់រំលោភបំពានច្បាប់ព្រហ្មទណ្ឌតែម្តង។ ហេតុដូច្នេះ ចេតនាត្រូវផ្តើមចេញពីបុគ្គលម្នាក់ដែលមានសេរីភាពពេញលេញ និងមានមនសិការគ្រប់គ្រាន់ដឹងខុសត្រូវថាអំពើណាជាអំពើខុសច្បាប់ព្រហ្មទណ្ឌ ហើយនៅតែមានបំណងប្រព្រឹត្តអំពើខុសច្បាប់នោះថែមទៀត។

**-ចេតនាប្រព្រឹត្តអំពើ** គឺចារីត្រូវប្រព្រឹត្តអំពើដោយចេតនា បានន័យថាដឹងច្បាស់ពីអំពើរបស់ខ្លួន។

45 នីតិព្រហ្មទណ្ឌទូទៅខ្មែរ, សាស្ត្រាចារ្យ កៅ សីហា(ឆ្នាំ ២០១៣) ទំព័រ ១៣៩ ។

46 មាត្រា ៤ កថាខណ្ឌទី១, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

ឧទាហរណ៍៖ បុគ្គលម្នាក់បានសម្លាប់មនុស្សដោយចេតនា។ ធាតុផ្សំអត្តនោម័តគឺ ចារីយល់ច្បាស់ថាទង្វើរបស់ខ្លួនគឺជាអំពើខុសច្បាប់(ចារីមិនមែនជាមនុស្សឆ្កួត ឬមិនដឹងខុសត្រូវឡើយ) ប៉ុន្តែចារីនៅតែមានបំណងប្រព្រឹត្តអំពើ ហើយបានធ្វើឱ្យជនរងគ្រោះស្លាប់បាត់បង់ជីវិតដោយចេតនា។

នៅក្នុងចេតនាប្រព្រឹត្តបទល្មើសរបស់ចារី គេសង្កេតឃើញមានចេតនា២ប្រភេទទៀតដែលតែងតែកើតមានឡើងនៅពេលដែលកើតមាននូវបទល្មើសដែលប្រភេទទីមួយនោះគឺជាចេតនាចំពោះ(**ក.១**) និងមួយប្រភេទទៀតគឺចេតនាមិនចំពោះ(**ក.២**)របស់ជនល្មើស។

**ក.១. កំហុសចេតនាចំពោះ**

ចេតនាចំពោះ គឺជាកំហុសរបស់បុគ្គលម្នាក់ ដោយសារក្នុងពេលប្រព្រឹត្តអំពើដែលបង្កគ្រោះថ្នាក់ដល់សង្គម ជននេះបានដឹងជាក់ច្បាស់ថាអំពើរបស់ខ្លួនមានចរិតគ្រោះថ្នាក់ ហើយមើលឃើញច្បាស់ពិតប្រាកដនូវបច្ច័យគ្រោះថ្នាក់នៃអំពើរបស់ខ្លួន ហើយចារីនៅតែចង់ឱ្យបច្ច័យនោះកើតឡើងទៀត។ ឧទាហរណ៍៖ ចារីបានឈ្លោះគ្នាជាមួយជនរងគ្រោះដោយសារតែមានទំនាស់ពាក្យសម្ដីជាមួយគ្នា ក្រោយមកចារីក៏ទៅលួចដុតឃ្លាំងលក់ឈើរបស់ជនរងគ្រោះចោល។ ករណីនេះចារីមានចេតនាទុច្ចរិតចំពោះ[47]។

មានពេលខ្លះចារីមិនមានបំណងចង់ឱ្យបច្ច័យណាមួយកើតឡើង តែអំពើរបស់គាត់អាចធ្វើឱ្យកើតឡើងនូវបច្ច័យណាមួយឡើង។

**ក.២ កំហុសចេតនាមិនចំពោះ**

ចេតនាមិនចំពោះ សំដៅដល់កំហុសរបស់បុគ្គលម្នាក់ ដោយក្នុងពេលប្រព្រឹត្តបទល្មើស ជននេះបានយល់ដឹងពីចរិតគ្រោះថ្នាក់ដល់សង្គមនៃអំពើរបស់ខ្លួនដែរ តែខ្លួនពុំប៉ងប្រាថ្នាឱ្យបច្ច័យនោះកើតឡើងទេ ក៏ប៉ុន្តែអំពើនោះបានធ្វើឱ្យបច្ច័យណាមួយកើតឡើងទៅវិញ[48]។ សម្រាប់ជនល្មើស ចំពោះលទ្ធផលនៃអំពើល្មើសមានលក្ខណៈបន្ទាប់បន្សំតែប៉ុណ្ណោះ ពីព្រោះថាអំពើរបស់ខ្លួនមានគោលដៅផ្សេងទៅវិញ។ ដោយសារតែព្រឹត្តិការណ៍ណាមួយនោះ ជនល្មើសបានធ្វើឱ្យកើតឡើងនូវព្យសនកម្មលើសពីអ្វីដែលខ្លួនបានគ្រោងទុកទៅទៀត[49]។ ឧទាហរណ៍៖ តាមអង្គហេតុនៃករណីខាងលើ នៅមុនពេលដែលចារីបានទៅលួចដុតឃ្លាំងលក់ឈើរបស់ជនរងគ្រោះនោះគាត់បានដឹងថានៅក្នុងឃ្លាំងនោះមានកម្មករជាច្រើននាក់ទៀតកំពុងតែដេកលង់លក់ក្នុងឃ្លាំងនោះ តែគាត់មិនអាចដាស់ពួកគេឱ្យងើបបានទេដើម្បីសម្រេចបំណងគាត់ដែលចង់កម្ទេចឃ្លាំងនោះចោល គាត់គិតថាបើឃ្លាំងឆេះទៅកម្មករនោះយ៉ាងម៉េចស្រេចតែវាសនាពួកគេចុះ។ ក្រោយមកអំពើនោះបានធ្វើឱ្យឆេះឃ្លាំង និងបានធ្វើឱ្យកម្មករទាំងប៉ុន្មាននៅក្នុងឃ្លាំងនោះស្លាប់ទៀតផង។ នៅត្រង់នេះចារីគ្រាន់តែមានបំណងដុតឃ្លាំងជនរងគ្រោះឱ្យឆេះ ក៏

[47] នីតិព្រហ្មទណ្ឌទូទៅខ្មែរ, សាស្ត្រាចារ្យ កៅ សីហា(ឆ្នាំ ២០១៣) ទំព័រ ១៤៩ ។
[48] នីតិព្រហ្មទណ្ឌពិសេស, សាស្ត្រាចារ្យ ជួន ប៊ុនធី(ឆ្នាំ ២០២១)។
[49] នីតិព្រហ្មទណ្ឌទូទៅខ្មែរ, សាស្ត្រាចារ្យ កៅ សីហា(ឆ្នាំ ២០១៣) ទំព័រ ១៤៩ ។

ប៉ុន្តែអំពើដែលគាត់ធ្វើនោះវាលើសពីបំណងរបស់គាត់ទៅទៀត មិនត្រឹមតែឆេះឃ្លាំងលក់ឈើទេបែរជាធ្វើឱ្យកម្មករក្នុងឃ្លាំងនោះគ្រោះស្លាប់បាត់បង់ជីវិតថែមទៀតដោយសារតែអំពើរបស់គាត់នោះ។ ដូច្នេះចារីនឹងត្រូវទទួលរងនូវការផ្តន្ទាទោសពី **បទមនុស្សឃាតដោយអចេតនា**[50] ។

ខុសពីកំហុសចេតនាខាងលើ ចំពោះកំហុសអចេតនាវិញគឺវាអាចកើតឡើងទាក់ទងនឹងការគ្រប់គ្រងឆន្ទៈរបស់ចារី។

**ខ. កំហុសអចេតនា**

កំហុសអចេតនា វាគឺជាកំហុសដែលកើតឡើងពីការមិនអាចគ្រប់គ្រងនូវឆន្ទៈរបស់ខ្លួនឯងបាន មានន័យថា ចារីមានបំណងធ្វើសកម្មភាពរបស់ខ្លួនក៏ប៉ុន្តែចារីពិតជាពុំមានឆន្ទៈ ឬពុំបានដឹងពីផលវិបាកដែលកើតចេញពីអំពើរបស់ខ្លួនឡើយ[51]។ ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត ប៉ុន្តែក្នុងករណីដែលច្បាប់បានចែងទុកមុន បទល្មើសមួយអាចកើតចេញពីការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ[52]។

ដូច្នេះ កំហុសអចេតនានេះ ត្រូវបានចែកចេញជាពីរគឺ កំហុសអចេតនាដោយធ្វេសប្រហែស(**ខ.១**) និងកំហុសអចេតនាដោយមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ(**ខ.២**)។

**ខ.១ កំហុសអចេតនាដោយធ្វេសប្រហែស**

កំហុសអចេតនាដោយធ្វេសប្រហែសកើតចេញពីៈ

- **ការមិនប្រុងប្រយ័ត្ន**

ការមិនប្រុងប្រយ័ត្ន សំដៅដល់អំពើទាំងឡាយណាដែលបណ្តាលមកពីសកម្មភាពមួយចំនួន ដូចជាការមិនបានប្រុងប្រៀបស្មារតីដោយការរាយមាយជាដើម[53]។ ឧទាហរណ៍ៈ ពេលកំពុងបើកបរយានយន្តគិតតែរវើរវាយរឿងផ្សេង មិនផ្តោតអារម្មណ៍លើការបើកបរ គឺជាការខ្វះការប្រុងប្រយ័ត្ន។

- **ការខ្ជីខ្ជា**

ការខ្ជីខ្ជា សំដៅលើការធ្វើការ ឬនិយាយអ្វីមិនម៉ត់ចត់[54]។ ឧទាហរណ៍ៈ កម្មករសំណង់ម្នាក់កំពុងតែយោងដែកថែបឡើងលើអគារតែមិនបានចងចំណាងឱ្យជាប់ល្អមុននឹងយោងយកទៅលើទេ។ ខណៈនោះដែកមួយដើមបានធ្លាក់មកក្រោមបណ្តាលឱ្យចំអ្នកធ្វើដំណើរក្បែរនោះស្លាប់បាត់បង់ជីវិត។

---

[50] មាត្រា ២០៧, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

[51] នីតិព្រហ្មទណ្ឌទូទៅខ្មែរ, សាស្ត្រាចារ្យ កៅ សីហា(២០១៣) ទំព័រ ១៥៤ ។

[52] មាត្រា ៤ កថាខណ្ឌ ២, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

[53] តាមវចនានុក្រមរបស់សម្តេចព្រះសង្ឃរាជ **ជួន ណាត** ពាក្យ **ប្រុង** ជាកិរិយាស័ព្ទ មានន័យថា **បម្រុងទុក ប្រយ័ត្នទុកមុន**(ទំព័រ ៦៨២)។ ចំណែកពាក្យ **ប្រយ័ត្ន** ជានាមស័ព្ទ មានន័យថា **ព្យាយាម ការខំប្រឹង ការថែទាំ ការប្រុងដោយមិនធ្វេសប្រហែស**(ទំព័រ ៦៦៣)។ ហេតុនេះការប្រុងប្រយ័ត្នសំដៅទៅលើ ការប្រយ័ត្នទុកជាមុន។

[54] តាមវចនានុក្រមរបស់ព្រះសង្ឃរាជ **ជួន ណាត** ទំព័រ ១០៤។

➢ **ការធ្វេសប្រហែស**

ការធ្វេសប្រហែស គឺជាការភ្លេចភ្លាំង ការបណ្ដែតបណ្ដោយ ការមាក់ងាយដោយជនល្មើស[55]។ ឧទាហរណ៍ ការធ្វេសប្រហែសដោយមិនបានត្រួតពិនិត្យហ្វ្រាំងរថយន្តមុនចេញដំណើរ, ការមិនបានជួសជុលផ្ទះរបស់ខ្លួនដែលពុកផុយទៅហើយជាដើម។ល។ ដែលធ្វើឱ្យកើតមានបញ្ហានៅពេលក្រោយ។

**ខ.២ កំហុសអចេតនាដោយមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ**

សម្រាប់បទល្មើសអចេតនាដោយមិនគោរពតាមកាតព្វកិច្ចដោយឡែកណាមួយនេះ ធាតុផ្សំអត្តនោម័តគឺសំដៅទៅលើកំហុសអចេតនាដែលពុំមែនជាចេតនាប្រព្រឹត្តបទល្មើសទេ តែចារីបានប្រព្រឹត្តខុសទៅនឹងវិធានណាមួយដែលគ្រប់គ្រាន់បង្កើតបានជាបទល្មើស។

ការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ គឺជាការមិនប្រតិបត្តិតាមកាតព្វកិច្ចដែលច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តតម្រូវឱ្យមាន។ ហេតុនេះចាំបាច់ត្រូវមានច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តណាមួយដែលជាមូលដ្ឋានឱ្យចារីបំពេញកាតព្វកិច្ចណាមួយ បើទោះបីជាកាតព្វកិច្ចនោះពុំមានលក្ខណៈជាកាតព្វកិច្ចព្រហ្មទណ្ឌក៏ដោយ ដូចជាការមិនគោរពតាមក្បួនច្បាប់វេជ្ជសាស្ត្រ ឬមិនគោរពតាមច្បាប់ចរាចរណ៍ជាដើម[56]។ ឧទាហរណ៍៖ ការមិនគោរពច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក ដូចជាការប្រើទូរស័ព្ទនៅពេលកំពុងបើកបរយានយន្ត[57], ការមិនបើកបរប្រកាន់ស្ដាំ[58]...។

**១.២.៣.២. គំនិតផ្ដួចផ្ដើម ឬមូលហេតុក្នុងការប្រព្រឹត្តបទល្មើស**

មូលហេតុ វាគឺជាពន្លកនៃគំនិត ជាពន្លកនៃបទល្មើសដែលថ្លក់បទល្មើសពីធាតុអត្តនោម័ត ទៅធាតុសត្យានុម័ត[59]។ ឧទាហរណ៍៖ ក្នុងករណីរំលោភមួយវាអាចកើតឡើងដោយសារ មកពីបានឃើញនារីម្នាក់នោះស្អាត ឬមកពីតណ្ហា...ទាំងនេះវាគឺជាមូលហេតុដែលនាំឱ្យកើតមានបទល្មើសរំលោភ។ ក្នុងករណីលួចវិញ ដូចជាឃើញគេទុកទូរស័ព្ទប្រហែសទំនងគួរឱ្យមានចិត្តចង់លួច...នេះហើយវាជាពន្លកនៃបទល្មើស(គំនិតផ្ដួចផ្ដើមចង់លួច)។

គំនិតផ្ដួចផ្ដើមប្រព្រឹត្តបទល្មើសមានតែករណីបទល្មើសដោយចេតនាតែប៉ុណ្ណោះ។ ចំពោះបទល្មើសដោយអចេតនា ជនល្មើសពុំមានបំណងប្រព្រឹត្តបទល្មើស មិនបានដឹងអំពើរបស់ខ្លួនដែលកើតឡើងដោយសារធ្វេសប្រហែស។ ហេតុនេះនៅក្នុងបទល្មើសអចេតនា ពេលធ្វើសកម្មភាព ផ្នែកផ្លូវចិត្តខាងក្នុងរបស់ជនល្មើស ពុំមានគំនិតផ្ដួចផ្ដើមជំរុញឱ្យជននោះប្រព្រឹត្តឡើយ។

---

[55] តាមវចនានុក្រមរបស់ព្រះសង្ឃរាជ **ជួន ណាត** ពាក្យ **ធ្វេស** ជាកិរិយាស័ព្ទ មានន័យថា **ធ្លោយ ប្រហែស**(ទំព័រ ៤៩០)។ ចំណែកពាក្យ **ប្រហែស** ជាកិរិយាស័ព្ទ មានន័យថា **ធ្វេសស្មារតី មិនសូវប្រយ័ត្ន បណ្ដែតបណ្ដោយ**(ទំព័រ ៦៧២)។

[56] នីតិព្រហ្មទណ្ឌទូទៅខ្មែរ, សាស្ត្រាចារ្យ កៅ សីហា (២០១៣) ទំព័រ ១៥៦ ។

[57] មាត្រា ៨ ចំណុចទី ៦, ច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក, លេខ នស/រកម/០១១៥/០០១, ០៩ មករា ២០១៥ ។

[58] មាត្រា ១០, ច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោក, លេខ នស/រកម/០១១៥/០០១, ០៩ មករា ២០១៥ ។

[59] នីតិព្រហ្មទណ្ឌពិសេស, សាស្ត្រាចារ្យ ជួន ប៊ុនធី(ឆ្នាំ ២០២១)។

រាល់គំនិតផ្តួចផ្តើម ឬមូលហេតុក្នុងការប្រព្រឹត្តបទល្មើសនីមួយៗសុទ្ធតែមានគោលដៅដែលជនល្មើសចង់បាន។

**១.២.៣.៣. គោលដៅនៃការប្រព្រឹត្តបទល្មើស**

គោលដៅនៃការប្រព្រឹត្តបទល្មើស វាគឺជាបំណងដែលជនល្មើសចង់បានដោយឆ្លងកាត់ការប្រព្រឹត្តរបស់ជននោះ។ នៅក្នុងការគិតរបស់ជនល្មើសបានផ្តុំឡើងនូវសញ្ញាណមួយដែលជាគោលដៅរបស់ជនល្មើសចង់បាន មានន័យថា គោលដៅនៃបទល្មើសមាននៅក្នុងគំនិត ក្នុងអារម្មណ៍របស់ជនល្មើសតាំងពីពេលដែលជននោះគិតថាប្រព្រឹត្តបទល្មើសមកម្ល៉េះ។ គោលដៅនៃការប្រព្រឹត្តបទល្មើសនេះមានតែទៅលើបទល្មើសដោយចេតនាទេ ដែលជននេះបានដឹងមុនចំពោះទង្វើរបស់ខ្លួន ហើយមានបំណងប្រាថ្នាឱ្យអំពើនោះកើតឡើង។

# ជំពូកទី ២
# ចំណាត់ថ្នាក់នៃបទល្មើស

# ជំពូកទី២

# ចំណាត់ថ្នាក់នៃបទល្មើស

បទល្មើសដែលកើតមានឡើងមានច្រើនប្រភេទណាស់ ហើយវាក៏មានទម្ងន់ស្រាល ឬធ្ងន់អាស្រ័យលើអំពើប្រព្រឹត្តប្រព្រឹត្តរបស់ជនល្មើស។ ហេតុនេះគេនឹងធ្វើចំណាត់ថ្នាក់នៃបទល្មើសដើម្បីឱ្យដឹងថា បទល្មើសណាមួយចូលទៅក្នុងចំណាត់ថ្នាក់បទល្មើសមួយណា ដែលជាការងាយស្រួលមួយសម្រាប់ធ្វើការចាត់ថ្នាក់នៃបទល្មើសដែលកើតមានឡើង។

ដើម្បីឱ្យស្គាល់បានច្បាស់អំពីប្រភេទនៃបទល្មើសនីមួយៗ គឺជាការចាំបាច់ដែលត្រូវតែធ្វើចំណាត់ថ្នាក់នៃបទល្មើសទាំងអស់ ក្នុងគោលដៅសម្រួលដល់ការកំណត់ និងស្គាល់នូវរបបគតិយុត្តដែលអនុវត្តចំពោះបទល្មើសណាមួយ។ ដោយសារវាមានសារៈសំខាន់បែបនេះ ទើបគេធ្វើការបែងចែកបទល្មើសតាមចំណាត់ថ្នាក់ជា ៣ ប្រភេទគឺ បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ។

## ២.១. ការបែងចែករវាងបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ

បទល្មើសត្រូវបានបែងចែកស្របទៅតាមភាពធ្ងន់ធ្ងរនៃបទល្មើសនីមួយៗ។ នៅក្នុងន័យនេះ ក្រមព្រហ្មទណ្ឌបានចែងចាត់ថ្នាក់បទល្មើសថា បទល្មើសត្រូវចាត់ថ្នាក់ជាបទឧក្រិដ្ឋ បទមជ្ឈិម បទលហុ ទៅតាមទម្ងន់នៃបទល្មើស[60]។

ការបែងចែកបទល្មើសជាបីប្រភេទដោយយោងទៅតាមទម្ងន់នៃបទល្មើសមានសារៈសំខាន់ណាស់នៅក្នុងនីតិព្រហ្មទណ្ឌ ពីព្រោះថា ការបែងចែកនេះបាននាំមកនូវផលប្រយោជន៍ទាក់ទងទៅនឹងរបបគតិយុត្តដែលច្បាប់រមែងផ្សារភ្ជាប់ទៅនឹងប្រភេទនីមួយៗនៃបទល្មើសយ៉ាងជាក់ច្បាស់។ ការធ្វើការបែងចែកនេះ ធ្វើទៅតាមលក្ខណៈវិនិច្ឆ័យច្បាស់លាស់មួយដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ។

### ២.១.១. លក្ខណៈវិនិច្ឆ័យនៃការបែងចែក

គួរកត់សម្គាល់ថា ក្រមព្រហ្មទណ្ឌបានកំណត់យកអតិបរមានៃទោសដែលច្បាប់តម្រូវឱ្យផ្តន្ទាទោសយកមកធ្វើជាមូលដ្ឋាននៃការវិនិច្ឆ័យ។ អតិបរមានៃទោសដែលច្បាប់កំណត់ទាំងនោះចែកជាបីរួមមាន៖ បទល្មើសជាបទឧក្រិដ្ឋ(**២.១.១.១**) បទល្មើសជាបទមជ្ឈិម(**២.១.១.២**) និងបទល្មើសជាបទលហុ(**២.១.១.៣**)។

#### ២.១.១.១. បទល្មើសជាបទឧក្រិដ្ឋ

នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារត្រូវទទួលរងជា៖

→ ទោសដាក់ពន្ធនាគារអស់មួយជីវិត។

[60] មាត្រា ២ វាក្យខណ្ឌ២, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

→ ទោសដាក់ពន្ធនាគារមានរយៈពេលលើសពី ៥ឆ្នាំ និងក្រោម ឬស្មើនឹង ៣០ឆ្នាំ។ ទោសដាក់ពន្ធនាគារអាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ[61]។

ឧទាហរណ៍៖

-បទឃាតកម្មគិតទុកជាមុន[62] ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។

-បទរំលោភសេពសន្ថវៈ[63] ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ។

**២.១.១.២. បទល្មើសជាបទមជ្ឈិម**

នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារដែលត្រូវរងមានរយៈពេលលើសពី ៦ថ្ងៃ និងក្រោម ឬស្មើនឹង ៥ឆ្នាំ។ ទោសដាក់ពន្ធនាគារអាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ[64]។

ឧទាហរណ៍៖

-អំពើលួច[65] ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ខែ ទៅ ៣ឆ្នាំ និងពិន័យជាប្រាក់ពី ១លានរៀល ទៅ ៤លានរៀល។

-បទបន្លំ[66] ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ថ្ងៃ ទៅ ៣ខែ និងត្រូវពិន័យជាប្រាក់ពី ១សែនរៀល ទៅ ៥សែនរៀល។

**២.១.១.៣. បទល្មើសជាបទលហុ**

នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារមានរយៈពេលក្រោម ឬស្មើនឹង ៦ថ្ងៃ ដោយទោសដាក់ពន្ធនាគារអាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។ មួយវិញទៀត បទល្មើសជាបទលហុ កាលបើបទល្មើសនោះត្រូវផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់ប៉ុណ្ណោះ[67]។

ឧទាហរណ៍៖

-បទហិង្សាស្រាល[68] ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥ពាន់រៀល ទៅ ១សែនរៀល។

-បទបរិហារកេរ្តិ៍ជាសាធារណៈ[69] ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី  ១សែនរៀល ទៅ ១០លានរៀល។

[61] មាត្រា ៤៦, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។
[62] មាត្រា ២០០, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។
[63] មាត្រា ២៣៩, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។
[64] មាត្រា ៤៧, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។
[65] មាត្រា ៣៥៣, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។
[66] មាត្រា ៣៨៤, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។
[67] មាត្រា ៤៨, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។
[68] មាត្រា ២២៨, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។
[69] មាត្រា ៣០៥, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

ការធ្វើបំណែងចែកនៃបទល្មើសស្របទៅតាមទម្ងន់នៃបទល្មើសបានផ្តល់នូវផលប្រយោជន៍ជាច្រើន ពាក់ព័ន្ធនឹងវិធានច្បាប់ដែលត្រូវយកមកអនុវត្តទៅលើបទល្មើសនីមួយៗអាស្រ័យទៅតាមប្រភេទនៃបទល្មើសនោះ។ មិនត្រឹមតែប៉ុណ្ណោះ បទប្បញ្ញត្តិខាងលើបានធ្វើឱ្យមានភាពងាយស្រួលដើម្បីធ្វើការកំណត់ថា បទល្មើសណាមួយជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុថែមទៀតផង។

រាល់ការធ្វើការបែងចែកទាំងនេះគឺវាមានផលប្រយោជន៍សំខាន់ជាច្រើនទាក់ទងនឹងផ្នែកមួយចំនួនទៀត។

## ២.១.២. ផលប្រយោជន៍នៃការបែងចែក

ការបែងចែកបទល្មើសជាបីប្រភេទខាងលើ មានផលប្រយោជន៍ជាច្រើនដែលច្បាប់បានកំណត់យក។ ផលប្រយោជន៍សំខាន់ៗទាំងនោះមានដូចជា ទាក់ទងនឹងអាជ្ញាយុកាល(**២.១.២.១**) ទាក់ទងនឹងការអនុវត្តនីតិវិធី(**២.១.២.២**) ការប៉ុនប៉ង(**២.១.២.៣**) ការផ្តើមគំនិត និងសមគំនិត(**២.១.២.៤**)ជាដើម។

### ២.១.២.១. ផលប្រយោជន៍ទាក់ទងនឹងអាជ្ញាយុកាល

អាជ្ញាយុកាល គឺជារយៈពេលមួយកំណត់ដោយច្បាប់ ដែលផុតរយៈពេលនេះ បុគ្គលម្នាក់អាចបាត់បង់សិទ្ធិណាមួយរបស់ខ្លួន ឬអាចទាមទារសិទ្ធិណាមួយជាប្រយោជន៍ផ្ទាល់របស់ខ្លួនបាន[70]។

នៅក្នុងច្បាប់ព្រហ្មទណ្ឌ អាជ្ញាយុកាលត្រូវបានបែងចែងជាពីរ គឺអាជ្ញាយុកាលនៃបទល្មើស(**ក**) និងអាជ្ញាយុកាលនៃទោស(**ខ**)។

#### ក. អាជ្ញាយុកាលនៃបទល្មើស

អាជ្ញាយុកាលនៃបទល្មើស ឬអាជ្ញាយុកាលនៃបណ្តឹងអាជ្ញា គឺជារយៈពេលមួយកំណត់ដោយច្បាប់ដែលនៅពេលផុតចិរវេលានេះ ព្រះរាជអាជ្ញាពុំអាចនឹងធ្វើការចោទប្រកាន់បានទេ ឬនិយាយម្យ៉ាងទៀតថា ព្រះរាជអាជ្ញាពុំអាចដាក់បណ្តឹងអាជ្ញាឱ្យមានចលនាបានឡើយ។ ចំពោះចិរវេលានៃអាជ្ញាយុកាលនេះដែរ វាប្រែប្រួលទៅតាមប្រភេទនីមួយៗនៃបទល្មើស[71]។

ចិរវេលានៃអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាមានដូចតទៅៈ

-១៥ឆ្នាំ ចំពោះបទឧក្រិដ្ឋ

-៥ឆ្នាំ ចំពោះបទមជ្ឈិម

-១ឆ្នាំ ចំពោះបទលហុ[72]។

[70] នីតិព្រហ្មទណ្ឌទូទៅ, សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ (ឆ្នាំ២០២២) ទំព័រ ៤១ ។

[71] នីតិព្រហ្មទណ្ឌទូទៅ, សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ (ឆ្នាំ២០២២) ទំព័រ ៤១ ។

[72] មាត្រា ១០, ក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧ ។ យោងតាមមាត្រា ៣០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ កញ្ញា ១៩៩២ ដែលត្រូវបាននិរាករណ៍ដោយក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់រយៈពេលអាជ្ញាយុកាលខ្លីជាងក្រមនីតិវិធីព្រហ្មទណ្ឌ ពោលគឺអាជ្ញាយុកាលនៃបទល្មើសសម្រាប់បទមជ្ឈិមមានរយៈពេល ៣ឆ្នាំ រីឯអាជ្ញាយុកាលសម្រាប់បទឧក្រិដ្ឋមានរយៈពេល ១០ឆ្នាំតែប៉ុណ្ណោះ។

ជាគោលការណ៍ អាជ្ញាយុកាលលនៃបទល្មើស ចិរវេលានៃអាជ្ញាយុកាលចាប់ផ្តើមរាប់ពីពេលប្រព្រឹត្តបទល្មើសតទៅ[73]។

**ខ. អាជ្ញាយុកាលនៃទោស**

អាជ្ញាយុកាលនៃទោស គឺជារយៈពេលមួយកំណត់ដោយច្បាប់ដែលផុតរយៈពេលនេះ ទោសពុំអាចអនុវត្តបានទៀតទេ[74]។

ក្រមព្រហ្មទណ្ឌបានកំណត់ចិរវេលានៃអាជ្ញាយុកាលនៃទោសដូចតទៅៈ

-ទោសដែលប្រកាសពីបទឧក្រិដ្ឋមានអាជ្ញាយុកាល ២០ឆ្នាំ

-ទោសដែលប្រកាសពីបទមជ្ឈិមមានអាជ្ញាយុកាល ៥ឆ្នាំ

-ទោសដែលប្រកាសពីបទលហុមានអាជ្ញាយុកាល ១ឆ្នាំ[75]។

ចិរវេលាខាងលើនេះ ត្រូវចាប់ផ្តើមគិតពីថ្ងៃដែលសេចក្តីសម្រេចផ្តន្ទាទោសបានចូលជាស្ថាពរ[76]។

**២.១.២.២. ផលប្រយោជន៍ទាក់ទងនឹងការអនុវត្តនីតិវិធី**

ក្នុងការអនុវត្តនីតិវិធីព្រហ្មទណ្ឌ អ្នកនីតិបញ្ញត្តិខ្មែរកំណត់គោលការណ៍មួយចំនួនដោយផ្អែកទៅលើប្រភេទនៃបទល្មើសថាជាបទឧក្រិដ្ឋ ឬជាបទមជ្ឈិម ឬក៏ជាបទលហុ។

ឧទាហរណ៍ៈ ក្នុងករណីជាបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរដោយធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[77]។ ចំពោះបទមជ្ឈិមវិញ ព្រះរាជអាជ្ញាមានសិទ្ធិជ្រើសរើសក្នុងការបើកការស៊ើបសួរ ឬបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬក៏ប្រើប្រាស់នីតិវិធីនៃការបង្ហាញខ្លួនភ្លាមបាន កាលបើលក្ខខណ្ឌដែលបានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ[78]ត្រូវបានបំពេញយ៉ាងគ្រប់គ្រាន់។ បើជាបទលហុ ព្រះរាជអាជ្ញាត្រូវកោះហៅជនជាប់ចោទឱ្យចូលខ្លួនទៅមុខតុលាការជំនុំជម្រះដោយផ្ទាល់[79]។

**២.១.២.៣. ផលប្រយោជន៍ទាក់ទងនឹងការប៉ុនប៉ង**

ការប៉ុនប៉ងក្នុងបទឧក្រិដ្ឋទាំងអស់ត្រូវតែមានទោសកាលបើលក្ខខណ្ឌដែលបានចែងត្រូវបានបំពេញគ្រប់គ្រាន់។ ការប៉ុនប៉ងក្នុងបទឧក្រិដ្ឋ ឬក្នុងករណីដែលច្បាប់បានចែងទុកក្នុងបទមជ្ឈិមគឺអាចត្រូវផ្តន្ទាទោសបាន

---

[73] មាត្រា ១១, ក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧ ។

[74] នីតិព្រហ្មទណ្ឌទូទៅ, សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ (ឆ្នាំ២០២២) ទំព័រ ៤២ ។

[75] មាត្រា ១៤៤, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

[76] មាត្រា ១៤៥, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។ មាត្រា ១១៧ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ៨ មីនា ១៩៩៣ ដែលត្រូវបាននិរាករណ៍ដោយក្រមព្រហ្មទណ្ឌ បានកំណត់រយៈពេលអាជ្ញាយុកាលនសទោសចំនួន ៣ឆ្នាំ សម្រាប់បទមជ្ឈិម និង ១០ឆ្នាំ សម្រាប់បទល្មើសឧក្រិដ្ឋ។

[77] មាត្រា ៤៤, ក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧ ។

[78] មាត្រា ៤៧, ក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧ ។

[79] មាត្រា ៤៩, ក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧ ។

កាលណាបើលក្ខខណ្ឌត្រូវបានបំពេញដូចខាងក្រោម៖

-ចារីបានចាប់ផ្ដើមអនុវត្តបទល្មើស មានន័យថាចារីបានប្រព្រឹត្តអំពើដែលមានគោលបំណងដោយផ្ទាល់ដើម្បីប្រព្រឹត្តបទល្មើស។

-ចារីមិនបានបញ្ឈប់អំពើរបស់ខ្លួនទៅវិញដោយស្ម័គ្រចិត្ត តែត្រូវបានរាំងស្ទះ ឬអាក់ខានដោយឥទ្ធិពលនៃកាលៈទេសៈក្រៅឆន្ទៈរបស់ខ្លួន។ អំពើត្រៀមបម្រុងដែលមានគោលបំណងដោយផ្ទាល់ដើម្បីប្រព្រឹត្តបទល្មើសមិនមែនជាការចាប់ផ្ដើមអនុវត្តទេ។ ការប៉ុនប៉ងក្នុងបទលហុពុំត្រូវទទួលការផ្ដន្ទាទោសទេ[80]។

ហេតុនេះ ការប៉ុនប៉ងក្នុងបទមជ្ឈិមត្រូវមានទោសក្នុងករណីដែលច្បាប់បានចែងទុកជាមុនតែប៉ុណ្ណោះ។ ឧទាហរណ៍ជាក់ស្ដែងដូចជា បទប្រទូស្ដកេរខ្មាស[81] បទបង្ហាញកេរភេទ[82] និងបទរុកកួនខាងផ្លូវភេទ[83] ការបំពានខាងផ្លូវភេទដទៃទៀត គឺជាបទមជ្ឈិម រីឯការប៉ុនប៉ងក្នុងបទលហុវិញ ពុំត្រូវទទួលការផ្ដន្ទាទោសឡើយ។

**២.១.២.៤. ផលប្រយោជន៍ទាក់ទងនឹងការផ្ដើមគំនិត និងការសមគំនិត**

ការផ្ដើមគំនិត និងការសមគំនិតដែលបំពេញលក្ខខណ្ឌច្បាប់កំណត់ក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមសុទ្ធសឹងតែមានទោសទាំងអស់ ។ ក៏ប៉ុន្ដែក្រមព្រហ្មទណ្ឌពុំបានចែងពីការផ្ដើមគំនិត ឬការសមគំនិតនៅក្នុងបទលហុទេ ដូច្នេះបានសេចក្ដីថា ការផ្ដើមគំនិត និងការសមគំនិតនៅក្នុងបទលហុមិនត្រូវទទួលការផ្ដន្ទាទោសនោះឡើយ។

ត្រូវចាត់ទុកជាអ្នកផ្ដើមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិមចំពោះបុគ្គលណាដែល៖

-ជំរុញឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬមជ្ឈិមនោះតាមការណែនាំ ឬការបញ្ជា

-បង្កឱ្យមានបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ដោយផ្ដល់អំណោយ ដោយការសន្យា ឬការគំរាមកំហែង ការញុះញង់ ការលួងលោម ឬក៏ដោយការរំលោភអាជ្ញា ឬអំណាចរបស់ខ្លួន។ អ្នកផ្ដើមគំនិតនឹងអាចត្រូវផ្ដន្ទាទោសបាន លុះត្រាតែបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវបានសម្រេច ឬបានប៉ុនប៉ង។ អ្នកផ្ដើមគំនិតនៃបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវផ្ដន្ទាទោសដូចគ្នានឹងចារីដែរ[84]។

ត្រូវចាត់ទុកជាអ្នកសមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម ចំពោះបុគ្គលណាដែលជួយសម្រួលដោយចេតនាដល់ការប៉ុនប៉ង ឬការសម្រេចបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ដោយផ្ដល់ជំនួយ ឬការឧបត្ថម្ភរបស់ខ្លួន។ អ្នកសម

[80] មាត្រា ២៧, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។
[81] មាត្រា ២៤៦, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។
[82] មាត្រា ២៤៩, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។
[83] មាត្រា ២៥០, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។
[84] មាត្រា ២៨, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

គំនិតនឹងអាចត្រូវផ្តន្ទាទោសបានលុះត្រាតែបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវបានសម្រេច ឬបានប៉ុនប៉ង។ អ្នកសមគំនិតនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវផ្តន្ទាទោសដូចចារីដែរ[85]។

## ២.២. ចំណាត់ថ្នាក់ដោយផ្អែកលើប្រភេទនៃបទល្មើស

ការធ្វើចំណាត់ថ្នាក់ដោយផ្អែកលើប្រភេទនៃបទល្មើសនេះ គឺគេធ្វើការបែងចែកប្រភេទបទល្មើស(**២.២.១**) នីមួយៗថាវាជាប្រភេទបទល្មើសអ្វីខ្លះ រួចគេនឹងពិនិត្យមើលទៅលើផលប្រយោជន៍នៃការបែងចែងនោះទាក់ទងនឹងសមត្ថកិច្ចនីមួយៗ(**២.២.២**)។

### ២.២.១. ការបែងចែកប្រភេទនៃបទល្មើស

ការធ្វើការបែងចែកប្រភេទនៃបទល្មើសនេះ គឺគេបែងចែងរវាងបទល្មើសនយោបាយ(**២.២.១.១**) បទល្មើសយោធា(**២.២.១.២**) និងបទល្មើសភារវកម្ម(**៣.២.១.៣**)។

#### ២.២.១.១. បទល្មើសនយោបាយ

មែនទែនទៅ គឺគ្មានបទល្មើសនយោបាយទេ មានតែបទល្មើសដែលមានចរិតជានយោបាយ។ បទល្មើសនយោបាយនេះ គឺវាមានន័យថា ជាកម្មវត្ថុនៃបទល្មើសដែលទាក់ទងនឹងបញ្ហានយោបាយ ពោលគឺបទល្មើសដែលធ្វើឱ្យប៉ះពាល់ដល់ការរៀបចំ និងការប្រព្រឹត្តទៅជាប្រក្រតីនៃអំណាចសាធារណៈ។ បើនិយាយឱ្យខ្លីទៅ វាគឺជាបទល្មើសដែលកើតឡើងដោយហេតុផលនយោបាយ ហើយនៅក្នុងក្រមព្រហ្មទណ្ឌគឺពុំបានចែងពីបទល្មើសនយោបាយទេ។

#### ២.២.១.២. បទល្មើសយោធា

បទល្មើសយោធា គឺជាបទល្មើសដែលប្រព្រឹត្តដោយយោធិននៅក្នុងជួរកងទ័ព ឬប៉ះពាល់ដល់ទ្រព្យសម្បត្តិកងកម្លាំងប្រដាប់អាវុធ ពោលគឺទាក់ទងនឹងយោធិន ទាំងយោធិនជាប់កិច្ចសន្យា ទាំងយោធិនកំណែន ទាំងការពាក់ព័ន្ធដល់បទពិន័យយោធា ឬការខូចខាតទ្រព្យសម្បត្តិយោធា[86]។

យ៉ាងណាមិញ ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ គឺពុំបានបញ្ជាក់ថាតើ បទល្មើសដែលមានចែងក្នុងក្រមនេះទោះបីជាប្រព្រឹត្តដោយយោធិនក៏ពុំមែនសុទ្ធតែអាចបង្កើតជាបទល្មើសយោធាដែរ។ ករណីដែលយោធិនប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌសាមញ្ញត្រូវតុលាការខេត្ត-ក្រុងជំនុំជម្រះ។ មួយវិញទៀត បទល្មើសយោធាស្ថិតនៅក្រោមសមត្ថកិច្ចតុលាការយោធា ហើយក្រៅពីបទពិន័យយោធា ឬការខូចខាតទ្រព្យសម្បត្តិយោធា(ការបំពានច្បាប់ជាបទល្មើស តែបើពិនិត្យវិស័យនៃការបំពានវិញវាពិតជាមានឥទ្ធិពលលើការកំណត់ប្រភេទនៃបទល្មើស) ជាសមត្ថកិច្ចរបស់តុលាការនៃនីតិរួម[87]។

---

[85] មាត្រា ២៩, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

[86] មាត្រា ១១, ច្បាប់ព្រហ្មទណ្ឌអន្តរកាល, ១០ កញ្ញា ១៩៩២ ។

[87] នីតិព្រហ្មទណ្ឌទូទៅ, សាស្ត្រាចារ្យ សែ វ៉េង(ភ្នំពេញ ២០១៣)។

#### ២.២.១.៣. បទល្មើសភេរវកម្ម

អំពើភេរវកម្ម គឺជាប្រភេទបទល្មើសថ្មីនាសតវត្សទី២១នេះ ហើយក៏ជាប្រភេទនៃបទល្មើសដែលមតិភាគច្រើនបានយល់ស្របគ្នាថា ជាបទល្មើសដ៏សែនគ្រោះថ្នាក់បំផុតចំពោះមនុស្សជាតិ មិនត្រឹមតែសម្រាប់ជាតិណាមួយនោះទេ តែចំពោះសហគមន៍អន្តរជាតិទាំងមូល។ អំពើភេរវកម្មគឺជាអំពើហិង្សាទាំងឡាយណាដែលប្រព្រឹត្តដោយជនម្នាក់ ឬច្រើននាក់ ឬជនមួយក្រុមបានបង្កើតការភិតភ័យតក់ស្លុតក្នុងចំណោមប្រជាជន ក្នុងគោលដៅធ្វើឱ្យច្របូកច្របល់យ៉ាងខ្លាំងដល់សណ្តាប់ធ្នាប់ និងសន្តិសុខជាសាធារណៈ និងធ្វើឱ្យប៉ះពាល់ដល់ស្ថិរភាពនយោបាយ។ ច្បាប់នេះបានអនុវត្តលើអំពើភេរវកម្ម ការចាប់ជម្រិត និងបង្ខាំងមនុស្សខុសច្បាប់ ក្នុងគោលដៅធ្វើវិច្ឆេទកម្ម ទារប្រាក់ សងសឹក ធ្វើជាចាប់ចំណាប់ខ្មាំងយកទៅលក់... ហើយត្រូវផ្តន្ទាទោសចាប់ពី ១០ឆ្នាំ ឬ២០ឆ្នាំ ឬអស់មួយជីវិត។ ច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្មឆ្នាំ២០០៧ ត្រូវបានរៀបចំឡើងដើម្បីឱ្យកម្ពុជាមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទប់ស្កាត់អំពើភេរវកម្ម ជាពិសេសសក្តានុពលនៃអំពើភេរវកម្មអាចកើតឡើងនៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលា។ ច្បាប់នេះកំណត់បទល្មើសទាំងឡាយណាដែលចាំបាច់ និងដែលចែងពីលទ្ធភាព និងការរឹបអូសទ្រព្យបម្រើឱ្យភេរកម្ម ព្រមទាំងធ្វើបត្យាប័ន ជួយគ្នាទៅវិញទៅមកជាអន្តរជាតិ។

### ២.២.២. សមត្ថកិច្ចទាក់ទងនឹងការបែងចែកបទល្មើស

ការបែងចែកបទល្មើសនេះគឺទាក់ទងនឹងសមត្ថកិច្ច ៣ ដែលរួមមានដូចជា៖

- **សមត្ថកិច្ចតាមបទល្មើស**៖ គឺជាសមត្ថកិច្ចមួយដែលគេកំណត់តាមប្រភេទបទល្មើស។
- **សមត្ថកិច្ចតាមជនល្មើស**៖ គឺជាសមត្ថកិច្ចមួយដែលគេជំនុំជម្រះ តាមប្រភេទអ្នកប្រព្រឹត្តបទល្មើស។
- **សមត្ថកិច្ចតាមដែនដី**៖ គឺត្រូវបានបែងចែកជា ៣ ប្រភេទទៀតគឺ៖

-ជួនកាលជាកន្លែងបទល្មើសកើតឡើង មានន័យថា បទល្មើសកើតឡើងនៅទីណា សមត្ថកិច្ចរបស់តុលាការនៅទីនោះ។

-ជួនកាលជាទីកន្លែងស្នាក់នៅបណ្តោះអាសន្ន មានន័យថា ជនល្មើសពួននៅទីណាគឺសមត្ថកិច្ចរបស់តុលាការនៅកន្លែងនោះ។

-ជួនកាលកន្លែងដែលគេចាប់ខ្លួន មានន័យថា គេដេញតាមបានជនល្មើសបាននៅកន្លែងណា ជាសមត្ថកិច្ចរបស់តុលាការនៅកន្លែងនោះ។

# ជំពូកទី៣
# ការទទួលខុសត្រូវព្រហ្មទណ្ឌ
# និង
# ការមិនទទួលខុសព្រហ្មទណ្ឌ

# ជំពូកទី៣

# ការទទួលខុសត្រូវព្រហ្មទណ្ឌ និងការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

## ៣.១. ការទទួលខុសត្រូវព្រហ្មទណ្ឌ

ជាធម្មតា នៅពេលដែលបទល្មើសមួយបានកើតឡើងចាំបាច់ត្រូវតែមានអ្នកទទួលខុសត្រូវចំពោះបទល្មើសនោះ។ ជាការពិត បុគ្គលម្នាក់ៗទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់របស់ខ្លួនតែប៉ុណ្ណោះ[88] ដែលនេះគឺជាគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ។ មានតែក្នុងរឿងរដ្ឋប្បវេណីទេ ទើបច្បាប់អាចអនុញ្ញាតឱ្យមានការទទួលខុសត្រូវរដ្ឋប្បវេណីចំពោះអំពើរបស់អ្នកដទៃដូចជា ការទទួលខុសត្រូវរបស់ឪពុកម្ដាយចំពោះអំពើរបស់កូនដែលជាអនីតិជន និងការទទួលខុសត្រូវរបស់និយោជកពីអំពើរបស់និយោជិត[89]ជាដើម។

ជាទូទៅ បុគ្គលម្នាក់អាចទទួលខុសត្រូវព្រហ្មទណ្ឌក្នុងឋានៈជាចារី ជាសហចារី ជាអ្នកផ្ដើមគំនិត ឬជាអ្នកសមគំនិតនៃបទល្មើសណាមួយទៅតាមអំពើប្រព្រឹត្តរបស់ខ្លួន។ កាលបើធាតុផ្សំនៃបទល្មើសមានភាពគ្រប់គ្រាន់ហើយ បុគ្គលដែលជាអ្នកប្រព្រឹត្តអំពើត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌទៅតាមច្បាប់កំណត់ ទោះបីជាបុគ្គលនោះជារូបវន្តបុគ្គលក្ដី(**៣.១.១**) ឬក៏ជានីតិបុគ្គលក្ដី(**៣.១.២**)។

### ៣.១.១. ការទទួលខុសត្រូវរបស់រូបវន្តបុគ្គល

រូបវន្តបុគ្គល គឺសំដៅលើមនុស្សដែលកើតមកហើយមានជីវិតរស់ ហើយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច[90]។ ការទទួលខុសត្រូវរបស់រូបវន្តបុគ្គល គឺជាអំពើដែលបានប្រព្រឹត្តដោយផ្ទាល់ ដោយបុគ្គលណាមួយ ហើយបុគ្គលនោះត្រូវទទួលខុសត្រូវនូវរាល់អំពើដែលខ្លួនបានប្រព្រឹត្ត។

ជាទូទៅ នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ច្បាប់បានកំណត់យកត្រឹមអាយុ ១៨ឆ្នាំ[91]។ រាល់បុគ្គលដែលបានចូលរួមក្នុងការប្រព្រឹត្តបទល្មើសដោយផ្ទាល់ ឬដោយប្រយោលក៏ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌផងដែរ មិនថាស្ថិតក្នុងឋានៈជាចារី សហចារី អ្នកសមគំនិត ឬអ្នកផ្ដើមគំនិតនោះទេ ហើយប្រសិនបើបទល្មើសនោះបានដូចបំណងដែលជនល្មើសចង់បាន គេហៅថាបទល្មើសនេះជាបទល្មើសបានសម្រេច។

យ៉ាងណាមិញ ទោះបីនីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌបានកំណត់ត្រឹមអាយុ១៨ឆ្នាំក៏ពិតមែន ក៏ប៉ុន្តែនីតិជនក៏ត្រូវទទួលខុសត្រូវផងដែរ ពោលគឺវាមានទាំងការទទួលខុសត្រូវរបស់នីតិជន(**៣.១.១.១**) ហើយក៏មានទាំងការទទួលខុសត្រូវរបស់អនីតិជន(**៣.១.១.២**)លើអំពើណាមួយដែលគេបានប្រព្រឹត្ត។

[88] មាត្រា ២៤, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

[89] មាត្រា ៧៤៦ និងមាត្រា ៧៤៧, ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧ ។

[90] នីតិព្រហ្មទណ្ឌទូទៅ, សាស្ត្រាចារ្យ ឃឹម ហ៊ុយលីម (ឆ្នាំ ២០២០)។

[91] មាត្រា ៣៨, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

### ៣.១.១.១. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិជន

ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិជន មានន័យថា ជនដែលមានអាយុចាប់ពី ១៨ឆ្នាំឡើងទៅជននោះនឹងត្រូវទទួលខុសត្រូវនូវអំពើដែលខ្លួនបានប្រព្រឹត្តនៅចំពោះមុខច្បាប់ដោយគ្មានការយោគយល់ និងលើកលែងនោះឡើយ។ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិជនស្តែងឡើងតាមរូបភាពខាងក្រោម៖

➢ **ចារី** ៖ គឺសំដៅលើបុគ្គលដែលជាអ្នកប្រព្រឹត្តបទល្មើស ហើយដែលត្រូវបានចោទប្រកាន់។ ត្រូវចាត់ទុកជាចារីផងដែរ ចំពោះបុគ្គលណាដែលប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬក្នុងករណីដែលច្បាប់បានចែងទុកចំពោះបទមជ្ឈិម[92]។ តាមរយៈនេះបានបញ្ជាក់ឱ្យឃើញពីសញ្ញាណនៃចារី គឺជាបុគ្គលដែលសម្រេចបំណងរបស់ខ្លួនដោយការប្រព្រឹត្តបទល្មើសមួយបានសម្រេចព្រមទាំងបុគ្គលដែលប៉ុនប៉ងប្រព្រឹត្តបទល្មើសដែលជាករណីនៃការប៉ុនប៉ង, ចារីនៃការប៉ុនប៉ងត្រូវបានគេប្រដូចទៅនឹងចារីនៃបទល្មើសបានសម្រេចដែរ ប៉ុន្តែសម្រាប់ចារីនៃការប៉ុនប៉ងក្នុងបទមជ្ឈិមគឺទាល់តែមានច្បាប់ចែងយ៉ាងជាក់ច្បាស់ទើបអាចផ្តន្ទាទោសដូចជាចារីនៃបទមជ្ឈិមបានសម្រេចដែរ។

➢ **សហចារី** ៖ គឺសំដៅលើបុគ្គលច្រើននាក់បានព្រមព្រៀងគ្នាប្រព្រឹត្តបទល្មើសរួមគ្នាដោយផ្ទាល់។ ត្រូវចាត់ទុកជាសហចារីផងដែរ កាលណាមានមនុស្សច្រើននាក់បានព្រមព្រៀងប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយផ្ទាល់ក្នុងករណីដែលច្បាប់បានចែងទុក[93]។ សញ្ញាណនៃសហចារីនេះ គឺយោងទៅដល់ការចូលអន្តរាគមន៍របស់រូបវន្តបុគ្គលជាច្រើនរូបនៅក្នុងក្របខណ្ឌនៃការប្រព្រឹត្តបទល្មើស ដោយបុគ្គលទាំងនោះបានចូលរួមអន្តរាគមន៍ជាមួយនឹងកម្រិតនៃការទទួលខុសត្រូវដូចគ្នានៅក្នុងសកម្មភាព។ ក្រៅពីចារី និងសហចារី ក៏អាចមានបុគ្គលផ្សេងទៀតចូលរួមក្នុងការប្រព្រឹត្តបទល្មើសផងដែរ។

➢**អ្នកផ្តើមគំនិត** ៖ សំដៅដល់បុគ្គលដែលជំរុញឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមតាមការណែនាំ ឬបញ្ជារបស់ខ្លួន ឬបុគ្គលដែលបង្កឱ្យមានបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយផ្តល់អំណោយ ដោយការសន្យា ឬការគំរាមកំហែង ឬការញុះញង់ ឬការលួងលោម ឬដោយការរំលោភអាជ្ញា ឬអំណាចរបស់ខ្លួន។ ទាល់តែបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលចារីប្រព្រឹត្តបានសម្រេច ឬបានប៉ុនប៉ង ទើបអ្នកផ្តើមគំនិតត្រូវផ្តន្ទាទោសដូចគ្នានឹងចារីប្រព្រឹត្តបទល្មើស[94]។

➢**អ្នកសមគំនិត** ៖ សំដៅលើបុគ្គលដែលជួយសម្រួលដោយចេតនា ដល់ការប៉ុនប៉ង ឬការសម្រេចបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយផ្តល់ជំនួយ ឬការឧបត្ថម្ភរបស់ខ្លួន។ អ្នកសមគំនិតក៏មានសញ្ញាណដូចគ្នានឹងអ្នកផ្តើមគំនិតដែរ មានន័យថា ទាល់តែចារីបានប្រព្រឹត្តបទឧក្រិដ្ឋ ឬមជ្ឈិមបានសម្រេច ឬប៉ុនប៉ង[95]។

---

[92] មាត្រា ២៥, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

[93] មាត្រា ២៦, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

[94] មាត្រា ២៨, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

[95] មាត្រា ២៩, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

ខុសពីការទទួលខុសត្រូវរបស់នីតិជន ចំពោះការទទួលខុសត្រូវរបស់អនីតិជនវិញ ការទទួលខុសត្រូវអាចមានលក្ខណៈស្រាលជាង។

**៣.១.១.២. ការទទួលខុសត្រូវរបស់អនីតិជន**

អនីតិជន គេសំដៅដល់ជនដែលមានអាយុក្រោម ១៨ឆ្នាំ។ ជាគោលការណ៍ គេមិនអាចឱ្យជនដែលមិនដឹងខុសត្រូវពីភាពធ្ងន់ធ្ងរនៃអំពើរបស់ខ្លួនឱ្យទទួលខុសត្រូវព្រហ្មទណ្ឌទេ។ ការយល់ដឹងខុសត្រូវ គឺជាកត្តាមួយដែលនាំឱ្យបុគ្គលម្នាក់ៗត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។ ប្រសិនបើក្មេងអាយុ ៥ឆ្នាំម្នាក់បានចាក់សម្លាប់ក្មេងម្នាក់ទៀត ក្មេងដែលបានប្រព្រឹត្តអំពើល្មើសមិនអាចទទួលខុសត្រូវព្រហ្មទណ្ឌបានទេ ដោយសារតែក្មេងអាយុ ៥ឆ្នាំនោះមិនមានសមត្ថភាពដឹងខុសត្រូវពីអំពើរបស់ខ្លួនឡើយ។ ដោយឡែក ចំពោះអនីតិជនដែលមានអាយុ ១៥ឆ្នាំវិញ ការអះអាងថា អនីតិជននោះមិនដឹងខុសត្រូវទាល់តែសោះនោះ គឺជាអំណះអំណាងមួយដែលពិបាកនឹងទទួលយកបានណាស់។ យ៉ាងណាមិញ ក្រមព្រហ្មទណ្ឌបានកំណត់នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ គឺនៅត្រឹមអាយុ ១៨ឆ្នាំ បានន័យថា អនីតិជនដែលមានអាយុតិចជាង ១៨ឆ្នាំ មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ[96]។

ថ្វីត្បិតតែអនីតិជនមិនទទួលខុសត្រូវព្រហ្មទណ្ឌ ក៏ប៉ុន្តែទន្ទឹមនឹងនោះ ក្រមព្រហ្មទណ្ឌតម្រូវឱ្យមានវិធានការក្រៅពីទោស(**ក**) ដូចជាវិធានតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ សម្រាប់អនីតិជនដែលប្រព្រឹត្តបទល្មើស។ ហេតុដូច្នេះប្រសិនបើអនីតិជនបានប្រព្រឹត្តបទល្មើស ជាគោលការណ៍ ត្រូវប្រើវិធានការតាមដាន អប់រំ ការពារ និងឧបត្ថម្ភចំពោះអនីតិជននោះព្រមទាំងវិធានការផ្សេងទៀតដែលមិនមែនជាការផ្តន្ទាទោស។ មិនត្រឹមតែប៉ុណ្ណោះ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ ក្រមព្រហ្មទណ្ឌអនុញ្ញាតឱ្យតុលាការប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជន(**ខ**)ដែលមានអាយុចាប់ពី ១៤ឆ្នាំឡើងទៅបាន ដោយអនីតិជនត្រូវតែទទួលការផ្តន្ទាទោសតាមវិធានដោយឡែក។

**ក. វិធានការអនុវត្តចំពោះអនីតិជនក្រៅពីទោស**

ក្រមព្រហ្មទណ្ឌបានរៀបរាប់ពីវិធានការដែលអនុវត្តចំពោះអនីតិជនក្រៅពីទោសមាន វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ[97]ដែលជាធម្មតាត្រូវយកមកអនុវត្តលើអនីតិជនដែលបានប្រព្រឹត្តបទល្មើស។ វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភទាំងអស់នោះមានដូច

[96] មាត្រា ៩១ នៃក្រមព្រហ្មទណ្ឌចាស់ចែងថា មនុស្សជាប់ចោទដែលគេជឿច្បាស់ថា វាជាពិរុទ្ធជន(ពិរុទ្ធជន ឬជនមានកំហុស) ហើយ តែមានអាយុតិចជាង ១៨ឆ្នាំ(នីតិភាពនៅអាយុ ២១ឆ្នាំ) ក្នុងខណៈដែលវាប្រព្រឹត្តបទល្មើសនោះ តុលាការត្រូវប្រមាណថា វាមិនទាន់ដឹងខុសត្រូវ និងមិនត្រូវឱ្យវាទទួលខុសត្រូវទេ។ ជននេះត្រូវបានរួចផុតពីការចោទប្រកាន់ ផុតពីទោសពៃទាំងអស់ ប៉ុន្តែតុលាការត្រូវសម្រេចថា ឱ្យជននោះនៅក្រោមការឧបត្ថម្ភ ការសង្គ្រោះ ការត្រួតត្រា ការអប់រំ ឬការកែខ្លួនណាមួយក្នុងចិរវេលាមានកំណត់។ មាត្រា ៩២ នៃក្រមព្រហ្មទណ្ឌចាស់ដដែលបានបន្ថែមថា អនីតិជនអាយុពី ១៥ឆ្នាំ ដល់ ១៧ឆ្នាំ ដែលបានប្រព្រឹត្តបទល្មើសឧក្រិដ្ឋកម្ម ឬមជ្ឈិមកម្ម នោះមិនត្រូវប្រមាណឱ្យផុតពីការទទួលខុសត្រូវក្នុងបទព្រហ្មទណ្ឌទេ កាលណាបើកាលៈទេសៈ ឬបុគ្គលភាពនៃអនីតិជននោះតម្រូវឱ្យទទួលខុសត្រូវ។

[97] មាត្រា ៣៩, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

តទៅ[98]៖

១. ការប្រគល់អនីតិជនឱ្យទៅឪពុកម្ដាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្ដិសមនឹងទំនុកចិត្ត។

២. ការប្រគល់អនីតិជនឱ្យទៅសេវាសាធារណៈដែលសម្រាប់ទទួលបន្ទុកអនីតិជន។

៣. ការប្រគល់អនីតិជនឱ្យទៅអង្គការឯកជនដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន។

៤. ការប្រគល់អនីតិជនឱ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស។

៥. ការដាក់អនីតិជនឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ។

ក្នុងករណីដែលអនីតិជនបានប្រព្រឹត្តបទល្មើស ហើយត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ តុលាការចាត់តាំងបុគ្គលមួយរូបឱ្យទទួលភារៈធ្វើការតាមដានអនីតិជនរូបនោះ។ បុគ្គលរូបនេះមានភារកិច្ចត្រូវតែធ្វើរបាយការណ៍ស្តីពីកិរិយាមារយាទរបស់អនីតិជនឱ្យបានជាទៀងទាត់ជូនដល់ព្រះរាជអាជ្ញា។ បុគ្គលនេះត្រូវផ្ដល់ព័ត៌មានដល់ព្រះរាជអាជ្ញាពីព្រឹត្តិការណ៍ទាំងអស់ដែលអាចនាំឱ្យមានការកែប្រែនូវវិធានការនេះ[99]។

**ខ. ទណ្ឌកម្មព្រហ្មទណ្ឌលើអនីតិជន**

មុននឹងប្រកាសទណ្ឌកម្មព្រហ្មទណ្ឌលើអនីតិជន តុលាការត្រូវកំណត់ពីអាយុរបស់អនីតិជនឱ្យបានច្បាស់លាស់។ អាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជនត្រូវកំណត់យកអាយុនៅពេលដែលអនីតិជននោះប្រព្រឹត្តបទល្មើស។ នៅក្នុងករណីមានការសង្ស័យអំពីអាយុរបស់អនីតិជន វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់អនីតិជននោះ។ ក្រមព្រហ្មទណ្ឌក៏ដូចជាច្បាប់ស្តីពីយុត្តិធម៌អនីតិជន បានកំណត់អាយុចាប់ពី ១៤ឆ្នាំ រហូតដល់ក្រោម ១៨ឆ្នាំ ដើម្បីអាចឱ្យតុលាការប្រកាសទណ្ឌកម្មព្រហ្មទណ្ឌបាន[100]។ ទណ្ឌកម្មព្រហ្មទណ្ឌដែលក្រមព្រហ្មទណ្ឌសំដៅដល់នោះគឺ **ទោស** នេះតែម្ដង។ ជាក់ស្ដែង ការកំណត់យកអាយុ ១៤ឆ្នាំ សម្រាប់លទ្ធភាពនៃការប្រកាសទណ្ឌកម្មព្រហ្មទណ្ឌ គឺមានភាពសមស្របទៅនឹងបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលអនុញ្ញាតឱ្យឃុំខ្លួនជាបណ្ដោះអាសន្នចំពោះអនីតិជនអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ក្នុងលក្ខខណ្ឌកំណត់ដោយច្បាប់ និងក្នុងថិរវេលាមួយតិចជាងការឃុំខ្លួនបណ្ដោះអាសន្នលើនីតិជន[101]។ ចំណែកឯអនីតិជនអាយុក្រោម ១៤ឆ្នាំ

[98] មាត្រា ៤០, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

[99] មាត្រា ៤១, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

[100] មាត្រា ៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនចែងថា នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបានកំណត់ចាប់ពីអាយុ ១៨ឆ្នាំ ឡើងទៅ។ ប៉ុន្តែតុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌលើអនីតិជនអាយុចាប់ពី ១៤ឆ្នាំ ឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ លើកលែងតែករណីមានចែងពិសេសនៅក្នុងច្បាប់ផ្សេងទៀត។

[101] មាត្រា ២១៣ និងមាត្រា ២១៤, ក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧ ។

វិញ មិនអាចត្រូវទទួលរងនូវការផ្តន្ទាទោសណាមួយឡើយ បើទោះបីជាអនីតិជននោះបានប្រព្រឹត្តបទល្មើសប្រភេទណាក៏ដោយ[102] ក៏ប៉ុន្តែតុលាការអាចចាត់នូវវិធានការណាមួយបានស្របតាមខ្លឹមសារនៃក្រមព្រហ្មទណ្ឌ។

ការប្រកាសទោសទៅលើអនីតិជនអាចធ្វើទៅបានលុះត្រាកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ។ ក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីយុត្តិធម៌អនីតិជនពុំបានកំណត់និយមន័យ ឬផ្តល់នូវលក្ខណៈវិនិច្ឆ័យនៃពាក្យ កាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជន ដែលជាលក្ខខណ្ឌនៃការប្រកាសទោសទៅលើអនីតិជននោះឡើយ។ ក្នុងន័យនេះ តុលាការធ្វើការវិនិច្ឆ័យទៅតាមរឿងក្តីនីមួយៗថាតើមានលក្ខខណ្ឌតម្រូវឱ្យប្រកាសទោសទៅលើអនីតិជនដែរឬទេ។

ក្នុងករណីដែលអនីតិជនមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ បានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ មានភាពកាចសាហាវ ដូចជាករណីប្រព្រឹត្តបទឃាតកម្មជាដើម កាលៈទេសៈនៃការប្រព្រឹត្តបទល្មើសនេះអាចជាមូលហេតុឱ្យតុលាការប្រកាសទណ្ឌកម្មព្រហ្មទណ្ឌលើអនីតិជនបាន។ ផ្ទុយទៅវិញ ចុះប្រសិនបើក្នុងករណីដែលអនីតិជនអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ បានលួចស្បែកជើងមួយគូ តើកាលៈទេសៈនៃការប្រព្រឹត្តបទល្មើសនេះតម្រូវឱ្យតុលាការប្រកាសទោសលើអនីតិជនបានដែរ ឬទេ? គឺតុលាការគាត់នឹងធ្វើការពិចារណាលើអំពើនោះដែលអំពើនោះវាមិនមែនជាមូលហេតុដែលកាលៈទេសៈនៃការប្រព្រឹត្តនាំឱ្យតុលាការប្រកាសទណ្ឌកម្មលើអនីតិជននោះបានទេ។

កាលណាតុលាការសម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជន ហើយមូលទោសលើបទល្មើសចោទប្រកាន់ដែលត្រូវយកមកអនុវត្តលើអនីតិជនត្រូវតែបន្ថយនៅក្នុងលក្ខខណ្ឌដូចមានកំណត់ខាងក្រោម[103]៖

-អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល។

-ប្រសិនបើអតិបរមានៃទោសដាក់ពន្ធនាគារគឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារត្រឹម **២០ឆ្នាំ**។

-អប្បបរមានៃទោសដាក់ពន្ធនាគារត្រូវ**បន្ថយពាក់កណ្តាល** ប្រសិនបើអប្បបរមានេះលើសពី ១ថ្ងៃ។

-អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល។

ឧទាហរណ៍៖ បទរំលោភសេពសន្ថវៈ[104]ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ១០ឆ្នាំ ។ ប្រសិនបើជនល្មើសជាអនីតិជនអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ តម្រូវឱ្យបន្ថយមូលទោសលើបទល្មើសដែលត្រូវចោទប្រកាន់ ពោលគឺអតិបរមានៃទោស (១០ឆ្នាំ) ត្រូវបន្ថយពាក់កណ្តាលមកនៅត្រឹម **៥ឆ្នាំ** ចំណែកឯអប្បបរមានៃ

---

[102] មាត្រា ២១២, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ៖ អនីតិជនអាយុក្រោម ១៤ឆ្នាំ មិនអាចត្រូវឃុំខ្លួនបណ្តោះអាសន្នបានឡើយ។

[103] មាត្រា ១៦០, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

[104] មាត្រា ២៣៩, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

ទោសវិញគឺ(**៥ឆ្នាំ មានន័យថាលើសពី ១ថ្ងៃ**) ក៏ត្រូវបន្ថយពាក់កណ្ដាលដែរ មកនៅត្រឹម ២ឆ្នាំ និង៦ខែ។ ដូច្នេះ មានន័យថា នៅពេលដែលជនល្មើសគឺជាអនីតិជន ទោសដែលត្រូវផ្ដន្ទា គឺជាការដាក់ពន្ធនាគារចាប់ពី **២ឆ្នាំ** និង **៦ខែ** ទៅ **៥ឆ្នាំ** សម្រាប់បទរំលោភសេពសន្ថវៈដែលអនុវត្តលើអនីតិជន។ ហេតុដូច្នេះ តុលាការមិនអាចប្រកាសដាក់ទោសឱ្យជនជាប់ចោទជាអនីតិជនជាប់ពន្ធនាគារលើសពី ៥ឆ្នាំ បានឡើយ ពីព្រោះថា នេះគឺជាអតិបរមានៃទោសដែលច្បាប់បានកំណត់សម្រាប់ជនជាប់ចោទជាអនីតិជន។

ក្នុងករណីខាងលើ ថ្វីត្បិតតែមូលទោសត្រូវបានបន្ថយក៏ដោយ ក៏បទរំលោភសេពសន្ថវៈប្រព្រឹត្តដោយអនីតិជននៅតែត្រូវចាត់ទុកថាជាបទឧក្រិដ្ឋដដែល ពុំមែនក្លាយមកជាបទមជ្ឈិមឡើយ។

### ៣.១.២. ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលគឺជាក្រុមមនុស្ស ឬមូលនិធិដែលមានបុគ្គលភាពគតិយុត្ត ហើយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច[105]។ ជាទូទៅ នីតិបុគ្គលមានពីរប្រភេទគឺ នីតិបុគ្គលសាធារណៈ និងនីតិបុគ្គលនៃនីតិឯកជន។ នីតិបុគ្គលសារធារណៈសំដៅដល់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ (រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)[106], គ្រឹះស្ថានសាធារណៈ[107]។ រីឯនីតិបុគ្គលនៃនីតិឯកជន សំដៅលើក្រុមហ៊ុន សមាគមជាដើម។

បើយោងតាមក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា នីតិបុគ្គលមានពីរប្រភេទគឺ នីតិបុគ្គលសាជីវកម្ម និងនីតិបុគ្គលមូលនិធិ។ នីតិបុគ្គលសាជីវកម្ម គឺជាក្រុមដែលមានសមាជិក ហើយត្រូវបានប្រគល់នូវឋានៈជាប្រធានសិទ្ធិ និងកាតព្វកិច្ចដោយឯករាជ្យ ឧទាហរណ៍ដូចជា ក្រុមហ៊ុន ឬសមាគមជាដើម, រីឯនីតិបុគ្គមូលនិធិ គឺជាទ្រព្យសម្បត្តិវិភាគទានដែលត្រូវបានប្រគល់នូវឋានៈជាប្រធានសិទ្ធិ និងកាតព្វកិច្ចដោយឯករាជ្យដូចជា មូលនិធិដើម្បីជួយដល់កុមារពិការ ឬជួយឧបត្ថម្ភដល់ការសិក្សាស្រាវជ្រាវណាមួយជាដើម[108]។

ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល មិនលើកលែងនូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គលក្នុងអំពើដដែលនោះទេ។ កាលបើលក្ខខណ្ឌកំណត់ដោយច្បាប់មានគ្រប់គ្រាន់ហើយ នីតិបុគ្គលអាចត្រូវប្រកាសថាទទួលខុសត្រូវព្រហ្មទណ្ឌបាន។ ព្រមជាមួយគ្នានេះ ដោយសារតែលក្ខណៈពិសេសរបស់នីតិបុគ្គល ទោសដែលអាចប្រកាសបានទៅលើនីតិបុគ្គលវាមានភាពខុសប្លែកពីទោសដែលអាចប្រកាសបានទៅលើរូបវន្តបុគ្គល។ តាមការរៀបរាប់ខាងលើ ដើម្បីអាចប្រកាសពីការទទួលខុសត្រូវព្រហ្មទណ្ឌលើនីតិបុគ្គលបានវាទាល់តែ

105 សន្ទានុក្រមផ្នែករដ្ឋប្បវេណី, រៀបចំដោយគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់, ពាក្យលេខរៀងទី៧១។

106 មាត្រា ៩, ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខ នស/រកម/០៥០៨/០១៧, ២២ ឧសភា ២០០៨ ចែងថា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌជានីតិបុគ្គលនៃនីតិសាធារណៈ។

107 គ្រឹះស្ថានសាធារណៈ គឺជានីតិបុគ្គលនៃនីតិសាធារណៈក្រៅពីរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានតួនាទីភារកិច្ចគ្រប់គ្រងសេវាសារធារណៈណាមួយ។ ឧទាហរណ៍៖ សាកលវិទ្យាល័យ។

108 មាត្រា ៤៦, ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧ ។

មានលក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល(៣.១.២.១)នោះ ហើយបន្ទាប់ពីមានលក្ខខណ្ឌគ្រប់គ្រាន់ហើយ នោះនឹងមានការដាក់ទណ្ឌកម្មលើនីតិបុគ្គល(៣.១.២.២)នោះតែម្តង។

### ៣.១.២.១. លក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវប្រកាសថាទទួលខុសត្រូវព្រហ្មទណ្ឌបានល្គឹកណាមានច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតចែងទុកជាមុន(ក) ហើយបទល្មើសត្រូវបានប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់នីតិបុគ្គល(ខ) ដើម្បីជាប្រយោជន៍ដល់នីតិបុគ្គលនោះ(គ) ។

#### ក. អត្ថិភាពនៃច្បាប់ ឬលិខិតបទដ្ឋានគតិយុត្ត

នីតិបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌកាលបើច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតបានចែងយ៉ាងជាក់លាក់ថា នីតិបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទល្មើសណាមួយជាកំណត់។ ហេតុដូច្នេះ ចំពោះបទល្មើសបទឃាតកម្ម[109] ក្រមព្រហ្មទណ្ឌពុំបានចែងបញ្ជាក់បន្ថែមពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលនោះទេ បានសេចក្តីថា នីតិបុគ្គលមិនអាចត្រូវបានប្រកាសថាទទួលខុសត្រូវព្រហ្មទណ្ឌពី **បទឃាតកម្ម** បានឡើយ។ ឧទាហរណ៍៖ ប្រធានក្រុមហ៊ុន **ក** បានធ្វើឃាតប្រធានក្រុមហ៊ុន **ខ** ព្រោះតែការប្រកួតប្រជែងគ្នាផ្នែកពាណិជ្ជកម្ម។ តុលាការបានសម្រេចផ្តន្ទាទោសប្រធានក្រុមហ៊ុន **ក** ពីបទឃាតកម្ម ក្នុងនាមជារូបវន្តបុគ្គល ក៏ប៉ុន្តែតុលាការមិនអាចដាក់ទោសក្រុមហ៊ុន **ក** ពីបទឃាតកម្មឡើយ ពីព្រោះតែពុំមានច្បាប់ចែងថា នីតិបុគ្គលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពី បទឃាតកម្ម នោះទេ។

#### ខ. បទល្មើសប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងនីតិបុគ្គល

នីតិបុគ្គល គឺជាបុគ្គលដែលកើតឡើងពីការសន្មតរបស់ច្បាប់។ នីតិបុគ្គលមែងមានអង្គការតំណាងក្រោមរូបភាពជាក្រុមប្រឹក្សា ឬអ្នកតំណាងជារូបវន្តបុគ្គលដែលធ្វើសកម្មភាពតំណាងឱ្យនីតិបុគ្គលជានិច្ច។

#### គ. ការប្រព្រឹត្តដើម្បីជាប្រយោជន៍ដល់នីតិបុគ្គល

ជាធម្មតា មានតែការប្រព្រឹត្តបទល្មើសដើម្បីជាប្រយោជន៍ដល់នីតិបុគ្គលតែប៉ុណ្ណោះដែលជាកត្តាធ្វើឱ្យនីតិបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌបាន ពីព្រោះថាបុគ្គលដែលទទួលប្រយោជន៍ពីការប្រព្រឹត្តបទល្មើសគប្បីត្រូវទទួលយកផលវិបាកនៃបទល្មើសនេះផងដែរ។ ត្រង់ចំណុចនេះ ប្រយោជន៍គឺចង់សំដៅលើផលប្រយោជន៍ខាងសេដ្ឋកិច្ចដែលមានលក្ខណៈច្បាស់លាស់ ឬគ្រាន់តែជាយថាហេតុក៏បានដែរ។

ឧទាហរណ៍៖ អភិបាលរបស់ក្រុមហ៊ុនមួយមិនបានចាត់នូវវិធានការសន្តិសុខឱ្យបានគ្រប់គ្រាន់តាមច្បាប់ដើម្បីធានានូវសុវត្ថិភាពដល់កម្មករនិយោជិតរបស់ក្រុមហ៊ុនទេ ពីព្រោះតែគាត់មិនចង់ឱ្យក្រុមហ៊ុនចំណាយប្រាក់ច្រើន ដែលអំពើនេះគឺធ្វើឡើងដើម្បីផលប្រយោជន៍របស់នីតិបុគ្គលហើយ។ ហេតុនេះ ប្រសិនបើការមិនបានចាត់

[109] មាត្រា ១៩៩, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

វិធានការនោះជាមូលហេតុធ្វើឱ្យកម្មករមានគ្រោះថ្នាក់ដោយប្រការណាមួយ នោះក្រុមហ៊ុនត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌ។

នៅពេលដែលនីតិបុគ្គលត្រូវបានគេរកឃើញថាត្រូវមានការទទួលខុសត្រូវព្រហ្មទណ្ឌ នោះនឹងមានការដាក់ទណ្ឌកម្មលើនីតិបុគ្គលនោះ។

**៣.១.២.២. ការដាក់ទណ្ឌកម្មលើនីតិបុគ្គល**

ទោសទាំងឡាយសម្រាប់នីតិបុគ្គលរួមមាន[110]៖

- ទោសពិន័យក្នុងឋានៈជាមូលទោស។
- ទោសបន្ថែម[111] ។

ចំពោះទោសបន្ថែមសម្រាប់នីតិបុគ្គលអាចត្រូវប្រកាសដោយតុលាការ ប្រសិនបើទោសនោះត្រូវបានចែងយ៉ាងជាក់ច្បាស់ចំពោះបទល្មើសដែលចោទប្រកាន់។ ទោសបន្ថែមជារួមដែលអាចអនុវត្តទៅលើនីតិបុគ្គលមានចំនួន ១៤ ប្រភេទ និងដែលត្រូវបានកំណត់ដូចរៀបរាប់ខាងក្រោម៖

១. ការរំលាយចោល។

២. ការដាក់ឱ្យនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ។

៣. ការហាមឃាត់ចំពោះការអនុវត្តសកម្មភាពមួយ ឬច្រើន។

៤. ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ។

៥. ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃ។

៦.ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរបានក្រៅពីឧបករណ៍អាចជួញដូរបានដែលកំណត់ដោយធនាគារ។

៧. ការហាមឃាត់ចំពោះការប្រើបណ្ណទូទាត់។

៨. ការបិទគ្រឹះស្ថានដែលប្រើសម្រាប់ធ្វើការរៀបចំ ឬប្រព្រឹត្តបទល្មើស។

៩. ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហរដល់សាធារណជន ឬដែលបានប្រើប្រាស់ដោយសាធារណជន។

១០. ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស។

១១. ការរឹបអូសនូវវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស។

[110] មាត្រា ១៦៧, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

[111] មាត្រា ១៦៨, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

១២. ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស។

១៣. ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ និងចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសបានប្រព្រឹត្ត។

១៤. ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍។

ឧទាហរណ៍៖ នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ[112] ចំពោះបទល្មើសដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ[113]ដូចជា អំពើលក់ ធ្វើអនុប្បទាន ឬឱ្យចំណី ឬក៏ភេសជ្ជៈ ដោយដឹងថាចំណី ឬក៏ភេសជ្ជៈនោះមានសារជាតិពុលនាំឱ្យខូចសុខភាពនោះត្រូវចាត់ទុកជាអំពើហិង្សាដោយចេតនា[114] និងអំពើប្រព្រឹត្តឡើងដោយចេតនាដោយដាក់បញ្ចូលនូវសារជាតិពុលនាំឱ្យខូចសុខភាពទៅក្នុងទឹកសម្រាប់ហូបជាសាធារណៈ ត្រូវចាត់ទុកជាអំពើហិង្សាដោយចេតនានៃក្រមនេះ[115]។ នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០លានរៀល ទៅ ៥០លានរៀល[116]។

### ៣.២. ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ឬការសម្រាលការទទួលខុសត្រូវព្រហ្មទណ្ឌនាំទៅដល់ការរួចផុតពីការមិនទទួលទណ្ឌកម្មព្រហ្មទណ្ឌ ឬក៏សម្រាលទណ្ឌកម្មព្រហ្មទណ្ឌ[117]។ បុគ្គលម្នាក់ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌកាលបើបុគ្គលនោះបានប្រព្រឹត្តអំពើដែលបង្កគ្រោះថ្នាក់ដល់សង្គម ក៏ប៉ុន្តែនៅក្នុងករណីខ្លះការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌអាចបណ្តាលមកពីមូលហេតុណាមួយដែលច្បាប់ព្រហ្មទណ្ឌចាត់ទុកថាជាមូលហេតុត្រឹមត្រូវ។ ដូច្នេះច្បាប់មិនតម្រូវឱ្យអ្នកប្រព្រឹត្តអំពើនោះទទួលខុសត្រូវព្រហ្មទណ្ឌទេ។

មូលហេតុដែលអាចឱ្យជនល្មើស ឬអ្នកប្រព្រឹត្តបទល្មើសរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានមានពីរ គឺ មូលហេតុទីមួយទាក់ទងផ្ទាល់ទៅនឹងបុគ្គលនៃចារី ឬអ្នកប្រព្រឹត្តបទល្មើស(**៣.២.១**) និងមូលហេតុទីពីរជាមូលហេតុដែលនៅក្រៅពីបុគ្គលនៃចារី(**៣.២.២**) ហើយដែលធ្វើឱ្យចារីរួចផុតពីការទទួលខុសត្រូវ ហើយនាំឱ្យអ្នកផ្តើមគំនិត អ្នកសមគំនិតរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌដែរ។

[112] មាត្រា ២៣០, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

[113]មាត្រា ៤២, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

[114] មាត្រា ២២៦, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

[115] មាត្រា ២២៧, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

[116] មាត្រា ២៣០ កថាខណ្ឌទី២, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

[117] ប្រសាសន៍របស់ឯកឧត្តម ផូវ សំភី អគ្គនាយកនៃអគ្គនាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍លើវិស័យយុត្តិធម៌, អគ្គលេខាធិការរងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី "ក្រមព្រហ្មទណ្ឌ" ដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌សហការណ៍ជាមួយក្រសួងព័ត៌មានតាមរយៈទូរទស្សន៍ជាតិកម្ពុជាឆ្នាំ២០១០។

### ៣.២.១. មូលហេតុដែលទាក់ទងផ្ទាល់ទៅនឹងបុគ្គលនៃចារី ឬអ្នកប្រព្រឹត្តបទល្មើស

មូលហេតុដែលទាក់ទងផ្ទាល់ទៅនឹងបុគ្គលនៃចារី ឬអ្នកប្រព្រឹត្តបទល្មើស មានន័យថាវាប៉ះពាល់ផ្ទាល់ទៅនឹងសតិបញ្ញាស្មារតីរបស់អ្នកប្រព្រឹត្តបទល្មើស ឬក៏វាប៉ះពាល់ដល់ការសម្រេចចិត្តដោយឯករាជ្យរបស់ចារីនៃបទល្មើស។ មូលហេតុនេះគេហៅថាមូលហេតុដែលមិនអាចទម្លាក់កំហុសបាន ហើយនាំឱ្យចារីរួចផុតពីការទទួលខុសត្រូវ ឬសម្រាលការទទួលខុសត្រូវព្រហ្មទណ្ឌ[118]។ វាជាមូលហេតុទាក់ទងផ្ទាល់នឹងចារី ប៉ុន្តែប្រសិនជាមានអ្នកផ្តើមគំនិត អ្នកសមគំនិត ផ្សេងទៀត អ្នកនោះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល។ តាមស្មារតីនៃក្រមព្រហ្មទណ្ឌមានមូលហេតុ២ដែលទាក់ទងផ្ទាល់ទៅនឹងបុគ្គលនៃចារីគឺ ទាក់ទងជាមួយសតិបញ្ញារបស់ចារីនៃបទល្មើសដែលច្បាប់បានហៅថាជា មូលហេតុវិបល្លាសស្មារតី(**៣.២.១.១**) និងទាក់ទងជាមួយនឹងអានុភាពនៃកម្លាំងបង្ខំ(**៣.២.១.២**)។

#### ៣.២.១.១. វិបល្លាសស្មារតី

ទាក់ទងជាមួយសតិបញ្ញារបស់ចារីនៃបទល្មើស ច្បាប់ហៅថាមូលហេតុវិបល្លាសស្មារតី សំដៅថាដែលធ្វើឱ្យមានស្មារតីមិនប្រក្រតី ដែលយើងហៅថាជាជនវិកលចរិត[119]។ វិបល្លាសស្មារតីសំដៅដល់វិបត្តិដែលធ្វើឱ្យមានភាពវឹកវរដល់សកម្មភាពនៃសរសៃប្រសាទរបស់មនុស្ស។ ជាក់ស្តែងវិបល្លាសស្មារតីអាចមានប្រភពមកពីជរាភាពគ្រោះថ្នាក់ ឬមកពីជំងឺណាមួយជាដើម ហើយដោយសារតែប្រព័ន្ធប្រសាទមានសកម្មភាពមិនប្រក្រតី ធ្វើឱ្យចារីបានបាត់បង់នូវលទ្ធភាពយល់ដឹងពីពិភពខាងក្រៅជុំវិញខ្លួន និងពុំអាចត្រួតត្រាលើសកម្មភាពរបស់ខ្លួនបានទេ។

កាលបើបុគ្គលម្នាក់ប្រព្រឹត្តបទល្មើសនៅពេលដែលជននោះកើតវិបល្លាសស្មារតីដែលធ្វើឱ្យបាត់បង់នូវការដឹងខុសត្រូវរបស់ខ្លួនជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ[120]។ ហេតុនេះស្ថានភាពស្មារតី ប្រសិនបើជនវិកលចរិតដែលបាត់បង់នូវការយល់ដឹងខុសត្រូវទាំងស្រុងហើយប្រព្រឹត្តបទល្មើស ជននោះរួចផុតពីការទទួលខុសត្រូវ។

ប៉ុន្តែ ក្នុងករណីដែលជនប្រព្រឹត្តតែបាត់បង់ការដឹងខុសត្រូវតែមួយផ្នែក ជននោះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល។ នៅពេលដែលតុលាការសម្រេចទោសគាត់ពិនិត្យអំពីស្ថានភាពថាគាត់ប្រព្រឹត្តបទល្មើសដោយសារគាត់បាត់បង់ការយល់ដឹងខុសត្រូវមួយផ្នែក ដូចជាមនុស្សឆ្កួតជ្រូក ពេលខ្លះបាត់បង់ស្មារតីទទួលខុសត្រូវទាំងស្រុងនៅពេលប្រព្រឹត្តបទល្មើស តែនៅពេលខ្លះគាត់មិនបាត់បង់ការយល់ដឹងទាំងស្រុងទេ គ្រាន់តែបន្ថយការ

---

118 ប្រសាសន៍របស់ឯកឧត្តម ផូវ សំភី អគ្គនាយកនៃអគ្គនាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍លើវិស័យយុត្តិធម៌, អគ្គលេខាធិការរងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី "ក្រមព្រហ្មទណ្ឌ" ដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌សហការណ៍ជាមួយក្រសួងព័ត៌មានតាមរយៈទូរទស្សន៍ជាតិកម្ពុជាឆ្នាំ២០១០។

119 ប្រសាសន៍របស់ឯកឧត្តម ផូវ សំភី អគ្គនាយកនៃអគ្គនាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍លើវិស័យយុត្តិធម៌, អគ្គលេខាធិការរងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី "ក្រមព្រហ្មទណ្ឌ" ដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌សហការណ៍ជាមួយក្រសួងព័ត៌មានតាមរយៈទូរទស្សន៍ជាតិកម្ពុជាឆ្នាំ២០១០។

120 មាត្រា ៣១, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

យល់ដឹងប៉ុណ្ណោះ នោះគាត់នៅតែទទួលខុសត្រូវ ក៏ប៉ុន្តែស្ថានភាពបែបនេះអាចក្លាយជាស្ថានសម្រាលទោសសម្រាប់ចារីបាន[121]។

ក្រៅពីនេះក៏ច្បាប់បានកំណត់ជៀសវាងថា មានករណីខ្លះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌ ទោះបីវិបល្លាសស្មារតីកើតឡើងជាពិសេសអ្នកដែលប្រើប្រាស់គ្រឿងញៀន គ្រឿងស្រវឹង ឬសារធាតុដែលច្បាប់ហាមឃាត់មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ដូច្នេះអ្នកដែលប្រើប្រាស់គ្រឿងញៀន ឬផឹកស្រាស្រវឹងហើយទៅប្រព្រឹត្តបទល្មើសហើយយកលេសថាវិបល្លាសស្មារតីដើម្បីរួចពីការទទួលខុសត្រូវនោះច្បាប់មិនទទួលស្គាល់សកម្មភាពនេះនោះទេ[122] ដែលជាទូទៅ ភស្តុតាងនៃវិបល្លាសស្មារតីត្រូវបញ្ជាក់ដោយវេជ្ជបណ្ឌិតជំនាញ។ ក៏ប៉ុន្តែយោបល់ទាំងនោះពុំមានអានុភាពចងជាកាតព្វកិច្ចឱ្យចៅក្រមត្រូវតែជឿតាមនោះទេ ពោលគឺចៅក្រមអាចជឿក៏បាន មិនជឿក៏បានដែរ។

**៣.២.១.២. អានុភាពនៃកម្លាំងបង្ខំ**

បុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬការបង្ខំដែលមិនអាចទប់ទល់បានបុគ្គលនោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ មានន័យថា ដើម្បីរួចផុតពីការទទួលខុសត្រូវលុះត្រាតែកម្លាំង ឬការបង្ខំនោះមិនអាចទប់ទល់បាន ហើយកម្លាំងឬការបង្ខំនោះគឺជាព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់ចារី មិនអាចមើលឃើញជាមុន ហើយនិងមិនអាចជៀសវាងបាន[123]។

មូលហេតុដែលទាក់ទងជាមួយនឹងអានុភាពនៃកម្លាំងបង្ខំ អាចមានជាកម្លាំងទៅលើរូបកាយ(**ក**) ឬទៅលើផ្លូវចិត្តរបស់ចារីនៃបទល្មើស(**ខ**)។

**ក. អានុភាពកម្លាំងលើរូបរាងកាយ**

អានុភាពកម្លាំងលើរូបរាងកាយ សំដៅទៅលើវត្តមាននៃកម្លាំងណាមួយលើរូបកាយរបស់ចារី ដែលជាហេតុធ្វើឱ្យចារីត្រូវតែប្រព្រឹត្តអំពើ ដោយខ្លួនពុំអាចឃាត់ឃាំងអំពើនោះបាន[124]។ កម្លាំងបង្ខំទាំងនោះអាចជាកម្លាំងបង្ខំមកពីខាងក្រៅ ឬមកពីស្ថានភាពខាងក្នុងផ្ទាល់របស់ចារីដែរ។

➢**កម្លាំងបង្ខំមកពីខាងក្រៅ៖** ដូចជាករណីមានកម្លាំងបង្ខំមកពីព្រឹត្តិការណ៍ធម្មជាតិ មកពីសត្វ ឬមកពីតតិយជនណាមួយ។ ឧទាហរណ៍ជាក់ស្តែង ទាក់ទងទៅនឹងកម្លាំងពេលអនុវត្តទៅលើរូបរាងកាយ គឺមានច្រើនដូចជា ករណីមានខ្យល់ព្យុះ ហើយអ្នកបើកបររថយន្តទប់ចង្កូតមិនឈ្នះ បណ្តាលឱ្យបុកអ្នកថ្មើរជើងស្លាប់ វាគឺជា

[121] ប្រសាសន៍របស់ឯកឧត្តម ផូវ សំភី អគ្គនាយកនៃអគ្គនាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍លើវិស័យយុត្តិធម៌, អគ្គលេខាធិការរងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី "ក្រមព្រហ្មទណ្ឌ" ដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌សហការណ៍ជាមួយក្រសួងព័ត៌មានតាមរយៈទូរទស្សន៍ជាតិកម្ពុជាឆ្នាំ២០១០។

[122] មាត្រា ៣១ ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

[123] មាត្រា ៣៦, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

[124] នីតិព្រហ្មទណ្ឌទូទៅ, សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ(ឆ្នាំ ២០២២) ទំព័រ ៣២០ ។

ស្ថានភាពមួយដែលអានុភាពកម្លាំងទៅលើរូបកាយរបស់អ្នកបើកបរ មានន័យថាគាត់មិនអាចជៀសវាងទប់ទល់នឹងស្ថានភាពនោះបានទេ ព្រោះគាត់កំពុងបើកបរហើយមិនអាចទប់ទល់បាន មិនដឹងជាមុនដោយសារជាគ្រោះធម្មជាតិ។

➢**កម្លាំងបង្ខំមកពីស្ថានភាពខាងក្នុងផ្ទាល់របស់ចារី៖** ឧទាហរណ៍ ខណៈពេលកំពុងបើកបរ ស្រាប់តែអ្នកបើកបររថយន្តទៅជាត្រជាក់ដៃជើង បណ្តាលឱ្យរមួលសរសៃជើងជាន់ទៅលើឈ្នាន់ល្បឿនបណ្តាលឱ្យមានគ្រោះថ្នាក់ស្លាប់ជនរងគ្រោះ។ ក្នុងករណីបែបនេះក៏អ្នកបើកបរមិនគួរត្រូវផ្តន្ទាទោសពី បទបើកបរបណ្តាលឱ្យស្លាប់អ្នកដទៃដោយអចេតនាឡើយ។

**ខ. អានុភាពកម្លាំងទៅលើផ្លូវចិត្ត**

អានុភាពកម្លាំងលើផ្លូវចិត្ត សំដៅទៅលើកម្លាំងដែលបង្ខំឆន្ទៈរបស់ចារី។ ការបង្ខំផ្លូវចិត្តក៏អាចជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌបានដែរ តែអាចនៅក្នុងករណីដែលការបង្ខំនោះមានប្រភពមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់ចារីប៉ុណ្ណោះ មិនអាចមើលឃើញជាមុនបាន និងមិនអាចជៀសវាងបាន[125] ពោលគឺជាការគាបសង្កត់ខាងក្រៅដែលជំរុញឱ្យចារីមិនអាចបញ្ចៀសបានពីការប្រព្រឹត្តបទល្មើសឡើយ[126]។ ទាក់ទងនឹងការគំរាមកំហែង គឺអានុភាពកម្លាំងទៅលើផ្លូវចិត្ត ជាពិសេសការគំរាមកំហែងដែលទាក់ទងផ្ទាល់ទៅលើចិត្តរបស់ចារី ឧទាហរណ៍ថា គំរាមកំហែងថានឹងសម្លាប់ចារី ឬសម្លាប់គ្រួសាររបស់ចារី ដើម្បីឱ្យចារីប្រព្រឹត្តបទល្មើស ដូចជាចោរបានចូលលួចក្នុងផ្ទះមួយ ហើយបានយកកាំភ្លើងមកភ្ជង់គំរាមអ្នកជួយលាក់អីវ៉ាន់របស់គាត់ ដូច្នេះអ្នកត្រូវគេភ្ជង់គាត់ស្ថិតក្រោមអានុភាពនៃកម្លាំង គឺប្រសិនបើមិនជួយលាក់អីវ៉ាន់ចោរទេ ម្ចាស់ផ្ទះនឹងត្រូវគេសម្លាប់ ។ ហេតុនេះអ្នកដែលជួយលាក់អីវ៉ាន់ចោរនោះ មិនទទួលខុសត្រូវអំពីការលាក់បំបាំងជាមួយជនល្មើស ឬទទួលផលចោរកម្មទេ ដែលនេះគឺជាអានុភាពនៃកម្លាំងដែលអនុវត្តទៅលើផ្លូវចិត្តរបស់ចារី។

ហេតុដូច្នេះ នៅក្នុងក្រមព្រហ្មទណ្ឌបានកំណត់យ៉ាងច្បាស់អំពីលក្ខខណ្ឌអនុភាពនៃកម្លាំងគឺបុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬការបង្ខំដែលមិនអាចទប់ទល់បានបុគ្គលនោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ មានន័យថា ដើម្បីរួចផុតពីការទទួលខុសត្រូវលុះត្រាតែកម្លាំង ឬការបង្ខំនោះមិនអាចទប់ទល់បានហើយកម្លាំងឬការបង្ខំនោះគឺជាព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់ចារី មិនអាចមើលឃើញជាមុន ហើយនិងមិនអាចជៀសវាងបាន។ ដូច្នេះបើប្រៀបធៀបនឹងលក្ខណៈនៃកម្លាំងបង្ខំដែលមិនអាចទប់ទល់បាន ជាព្រឹត្តិការណ៍ក្រៅឆន្ទៈដែលមិនអាចដឹងមុន និងមិនអាចជៀសវាងបាននោះ គឺវាប្រហាក់ប្រហែលនឹងសញ្ញាណនៃប្រធានសក្តិនៅក្នុងនីតិរដ្ឋប្បវេណី ដែលធ្វើឱ្យរួចផុតពីការទទួលខុសត្រូវនៅក្នុងនីតិរដ្ឋប្បវេណីករណីប្រធានសក្តិនេះហើយនៅក្នុង

[125] មាត្រា ៣៦, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

[126] នីតិព្រហ្មទណ្ឌទូទៅ, សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធិ(ឆ្នាំ ២០២២) ទំព័រ ៣២២ ។

ក្រមព្រហ្មទណ្ឌគេហៅថា **អានុភាពនៃកម្លាំងបង្ខំ**។ ចរិតលក្ខណៈនៃកម្លាំងមានលក្ខខណ្ឌ ៤ គឺ**មិនអាចទប់ទល់បាន ក្រៅឆន្ទៈ មិនអាចមើលឃើញ** និង**មិនអាចជៀសវាងបាន**។

តាមការរៀបរាប់ខាងលើនេះសុទ្ធតែជាមូលហេតុដែលទាក់ទងផ្ទាល់ទៅនឹងបុគ្គលនៃចារី ឬអ្នកប្រព្រឹត្តបទល្មើស។ យ៉ាងណាមិញ នៅមានមូលហេតុមួយទៀតដែលនាំឱ្យចារី ឬអ្នកប្រព្រឹត្តបទល្មើសអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានដែរនោះគឺ មូលហេតុខាងក្រៅបុគ្គលនៃចារី ឬអ្នកប្រព្រឹត្តបទល្មើស។

### ៣.២.២. មូលហេតុខាងក្រៅបុគ្គលនៃចារី ឬអ្នកប្រព្រឹត្តបទល្មើស

មូលហេតុខាងក្រៅបុគ្គលនៃចារីនេះ ជាមូលហេតុដែលគេចាត់ចេញក្រៅពីបុគ្គលនៃចារី ហើយដែលធ្វើឱ្យចារីរួចផុតពីការទទួលខុសត្រូវ ហើយនាំឱ្យអ្នកផ្តើមគំនិត អ្នកសមគំនិតរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌដែរ ដែលនៅក្នុងក្រមព្រហ្មទណ្ឌគេហៅថាជា អំពើយុត្តិកម្ម[127]។ មូលហេតុខាងក្រៅនេះមាន ៣ ប្រភេទ ទី១ គឺអនុញ្ញាតដោយច្បាប់ឬដោយអាជ្ញាធរធម្មានុរូប(**៣.២.២.១**) ទី២គឺការការពារស្របច្បាប់(**៣.២.២.២**) និងទី៣គឺស្ថានភាពចាំបាច់(**៣.២.២.៣**)។

#### ៣.២.២.១. ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ

ការអនុញ្ញាតដោយច្បាប់(**ក**) ឬដោយអាជ្ញាធរ(**ខ**) បានកំណត់យ៉ាងច្បាស់នៅក្នុងក្រមព្រហ្មទណ្ឌ គឺបុគ្គលណាដែលប្រព្រឹត្តអំពើដែលបញ្ញត្ត ឬអនុញ្ញាតដោយច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ[128] មានន័យថាជាសកម្មភាពស្របច្បាប់។

##### ក. ការអនុញ្ញាតដោយច្បាប់

ការអនុញ្ញាតដោយច្បាប់យើងអាចមើលឃើញក្នុងក្រមព្រហ្មទណ្ឌ ដែលច្បាប់បានអនុញ្ញាតឱ្យក្នុងករណីបទល្មើសជាក់ស្តែងប្រជាពលរដ្ឋមានសិទ្ធិចាប់ខ្លួនជនល្មើសប្រគល់ជូននគរបាលយុត្តិធម៌ជិតបំផុត[129] ព្រោះថាប្រសិនបើគ្មានច្បាប់ចែងយ៉ាងនេះទេ ការចាប់ជនល្មើសបែបនេះបានន័យថាជាការចាប់បង្ខាំងមនុស្សដោយខុសច្បាប់។

ក្នុងករណីដែលច្បាប់បញ្ញត្ត ឬអនុញ្ញាតឱ្យប្រព្រឹត្តអំពើណាមួយហើយ ច្បាប់មិនអាចបញ្ញត្តឱ្យផ្តន្ទាទោសលើអំពើដែលកើតចេញពីការបំពេញកាតព្វកិច្ចតម្រូវដោយច្បាប់ ឬជាការអនុវត្តសិទ្ធិដែលច្បាប់បានអនុញ្ញាតនោះឡើយ[130]។

---

[127] ប្រសាសន៍របស់ឯកឧត្តម ផូវ សំភី អគ្គនាយកនៃអគ្គនាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍លើវិស័យយុត្តិធម៌, អគ្គលេខាធិការរងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី "ក្រមព្រហ្មទណ្ឌ" ដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌សហការណ៍ជាមួយក្រសួងព័ត៌មានតាមរយៈទូរទស្សន៍ជាតិកម្ពុជាឆ្នាំ២០១០។

[128] មាត្រា ៣២, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

[129] មាត្រា ៨៧, ក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧ ។

[130] និតិព្រហ្មទណ្ឌទូទៅ, សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ(ឆ្នាំ ២០២២) ទំព័រ ៣២៧ ។

### ខ. ការអនុញ្ញាតដោយអាជ្ញាធរ

ការអនុញ្ញាតដោយអាជ្ញាធរមានពីរ[131]គឺ ការបញ្ជារបស់អាជ្ញាធរស្របច្បាប់ដែលហៅថាជាបញ្ជាស្របច្បាប់(ខ.១)និងអាជ្ញាធរស្របច្បាប់(ខ.២)។

#### ខ.១. អាជ្ញាធរស្របច្បាប់

អាជ្ញាធរស្របច្បាប់ សំដៅអាជ្ញាធរសាធារណៈដែលតំណាងឱ្យអំណាចសាធារណៈ ហើយជាអាជ្ញាធរដែលមានសមត្ថកិច្ច។ ម្យ៉ាងវិញទៀតទាក់ទងនឹងករណីការបញ្ជារបស់អាជ្ញាធរស្របច្បាប់ដដែលនេះបានកំណត់ថា បុគ្គលដែលប្រព្រឹត្តតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ លើកលែងតែអំពើនេះជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់ មានន័យថាវាមានលក្ខខណ្ឌមួយ ព្រោះថាជាគោលការណ៍មិនប្រព្រឹត្តបទល្មើសទេ។ ដូច្នេះ ប្រសិនជាអាជ្ញាធរសាធារណៈដែរ ផ្តល់បញ្ជាទៅ តែអាជ្ញាធរនោះអសមត្ថកិច្ចក្នុងកិច្ចការនោះបញ្ជាទៅមន្ត្រីម្នាក់ដែលគាត់យល់ឃើញថាអាជ្ញាធរនោះមិនមានសមត្ថកិច្ចហើយគាត់អនុវត្ត នោះមិនហៅថាការទទួលបញ្ជាពីអាជ្ញាធរស្របច្បាប់ទេ។ ដូចគ្នានេះ ប្រសិនបើនិយោជិតម្នាក់អនុវត្តតាមបញ្ជារបស់និយោជករបស់ខ្លួនដើម្បីប្រព្រឹត្តបទល្មើសខុសច្បាប់ក៏មិនមែនជាបញ្ជារបស់អាជ្ញាធរស្របច្បាប់ដែរ ព្រោះថាមិនមែនជាអាជ្ញាធរសាធារណៈ វាជាបញ្ជាថ្នាក់លើឯកជនរបស់ខ្លួនទោះបីជានិយោជិតនោះគាត់ខ្លាចគេបញ្ឈប់ការងារខ្លួនហើយប្រព្រឹត្តបទល្មើសទៅតាមការបញ្ជារបស់និយោជកក៏មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានដែរ[132]។ ហេតុនេះ មិនត្រូវចាត់ទុកជាអាជ្ញាធរស្របច្បាប់ឡើយចំពោះ៖

- ឪពុកម្តាយ(ក្នុងករណីដែលឪពុកម្តាយបានបញ្ជាឱ្យកូនរបស់ខ្លួនធ្វើអ្វីមួយដែលផ្ទុយនឹងច្បាប់)
- និយោជកនៃក្រុមហ៊ុនមួយ(ក្នុងករណីដែលនិយោជកនោះបានបញ្ជាឱ្យនិយោជិតធ្វើអ្វីមួយដែលខុសច្បាប់)។

#### ខ.២. បញ្ជាស្របច្បាប់

ក្រមព្រហ្មទណ្ឌមិនអនុញ្ញាតឱ្យជនដែលបានប្រព្រឹត្តបទល្មើសតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់រួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ប្រសិនបើអំពើនោះជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់។ ចំពោះពាក្យថា អំពើខុសច្បាប់យ៉ាងជាក់ច្បាស់នេះ ទាមទារឱ្យមានការវាយតម្លៃទៅតាមករណីនីមួយៗដោយត្រូវពិនិត្យទៅលើស្ថានភាព និងកាលៈទេសៈជាក់ស្តែងរបស់អ្នកទទួលបញ្ជា ដូចជាសមត្ថភាព បទពិសោធន៍ និងឋានៈជាដើម ហេតុនេះ មន្ត្រីរាជការថ្នាក់ខ្ពស់មានសមត្ថភាពអាចធ្វើការវាយតម្លៃកំណត់អំពីភាពស្របច្បាប់ ឬមិនស្របច្បាប់នៃបញ្ជា

[131] មាត្រា ៣២ កថាខណ្ឌទី៣, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

[132] ប្រសាសន៍របស់ឯកឧត្តម ផូវ សំភី អគ្គនាយកនៃអគ្គនាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍លើវិស័យយុត្តិធម៌, អគ្គលេខាធិការរងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី "ក្រមព្រហ្មទណ្ឌ" ដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌សហការណ៍ជាមួយក្រសួងព័ត៌មានតាមរយៈទូរទស្សន៍ជាតិកម្ពុជាឆ្នាំ២០១០។

ណាមួយរបស់ថ្នាក់លើខ្លួនបានច្រើនជាងមន្ត្រីធម្មតា ឬជនសាមញ្ញដែលត្រូវបានអាជ្ញាធរបញ្ជាឱ្យធ្វើអ្វីមួយ។ ការប្រើពាក្យថា អំពើខុសច្បាប់យ៉ាងជាក់ច្បាស់ នាំឱ្យសន្និដ្ឋានបានថា ប្រសិនបើអំពើដែលប្រព្រឹត្តគ្រាន់តែជាអំពើខុសច្បាប់ ប៉ុន្តែមិនមែនជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់ទេ អ្នកប្រព្រឹត្តតាមបញ្ជាអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបាន។ ឧទាហរណ៍ នៅពេលស្តាប់ចម្លើយជនសង្ស័យដែលត្រូវបានឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ម្នាក់បានបញ្ជាឱ្យមន្ត្រីក្រោមឱវាទរបស់ខ្លួន វាយតប់ និងធ្វើទារុណកម្មលើជនសង្ស័យដើម្បីទទួលបានចម្លើយសារភាព។ នៅត្រង់នេះថ្វីត្បិតតែមន្ត្រីនគរបាលអាចឃាត់ខ្លួនអ្នកដទៃបានក៏ពិតមែន ក៏ប៉ុន្តែច្បាប់បានហាមឃាត់យ៉ាងច្បាស់លាស់ពីការប្រើអំពើហិង្សា។ ដូច្នេះ អំពើបែបនេះគឺជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់។

**៣.២.២.២. ការការពារស្របច្បាប់**

ការការពារស្របច្បាប់មានន័យថាបានប្រព្រឹត្តបទល្មើស ប៉ុន្តែមិនទទួលខុសត្រូវព្រហ្មទណ្ឌ ហើយមិនទទួលទណ្ឌកម្មព្រហ្មទណ្ឌទោះមានបទល្មើស[133]។ ដើម្បីអាចរួចផុតពីការទទួលខុសត្រូវបានដោយប្រើមូលហេតុការការពារស្របច្បាប់នេះទាល់តែបានបំពេញទាំងទងទៅនឹង លក្ខខណ្ឌនៃការការពារស្របច្បាប់(**ក**) នៅពេលដែលមានការឈ្លានពាន(**ខ**) និងទាក់ទងនឹងការការពារការឈ្លានពាន(**គ**)ផងដែរ។

**ក. លក្ខខណ្ឌនៃការការពារស្របច្បាប់**

ត្រង់នេះការការពារស្របច្បាប់មានលក្ខខណ្ឌយ៉ាងច្បាស់លាស់ គឺមានលក្ខខណ្ឌដែលលក្ខខណ្ឌនេះត្រូវតែផ្គុំគ្នាឬត្រូវបំពេញទាំងអស់។ ការការពារស្របច្បាប់ត្រូវមានលក្ខខណ្ឌដូចជា៖

- បទល្មើសត្រូវចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ការពារទ្រព្យសម្បត្តិដើម្បីប្រឈមមុខទៅនឹងការឈ្លានពានមួយដែលមិនត្រឹមត្រូវ។
- បទល្មើស និងការឈ្លានពានត្រូវតែកើតឡើងនៅពេលជាមួយគ្នា។
- គ្មានវិសមាមាត្ររវាងមធ្យោបាយការពារប្រើប្រាស់ និងទម្ងន់នៃការបំពាន[134]។

ហេតុដូចនេះ ដើម្បីឱ្យបានរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌដោយផ្អែកលើការការពារស្របច្បាប់ ជនដែលបានប្រព្រឹត្តបទល្មើសត្រូវតែបង្ហាញឱ្យឃើញអំពីលក្ខខណ្ឌនៃការការពារស្របច្បាប់ដែលកំណត់ដោយក្រមព្រហ្មទណ្ឌ។

លក្ខខណ្ឌខាងលើគឺវាមានទំនាក់ទំនងគ្នាជាមួយនឹងការឈ្លានពានដើម្បីធ្វើការបង្ហាញថាលក្ខខណ្ឌត្រូវបានបំពេញ។

[133] ប្រសាសន៍របស់ឯកឧត្តម ផូវ សំភី អគ្គនាយកនៃអគ្គនាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍លើវិស័យយុត្តិធម៌, អគ្គលេខាធិការរងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី "ក្រមព្រហ្មទណ្ឌ" ដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌សហការណ៍ជាមួយក្រសួងព័ត៌មានតាមរយៈទូរទស្សន៍ជាតិកម្ពុជាឆ្នាំ២០១០។
[134] មាត្រា ៣៣, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

### ខ. ការឈ្លានពាន

ការឈ្លានពានត្រូវកើតឡើងមុនពេលមានការការពារ ពីព្រោះថាអំពើការពារធ្វើឡើងដោយសារមានការចាំបាច់ដើម្បីការពារប្រឈមមុខនឹងការឈ្លានពានណាមួយ។ ហេតុដូច្នេះ ការឈ្លានពានជាមុនគឺជាធាតុផ្សំចាំបាច់នៃការការពារស្របច្បាប់។ ការឈ្លានពានអាចប្រព្រឹត្តទៅលើទ្រព្យសម្បត្តិ ឬរូបកាយរបស់អ្នកការពារផ្ទាល់ ឬទៅលើតតិយជន។

ការឈ្លានពានស្តែងឡើងតាមរយៈគ្រោះថ្នាក់ណាមួយដែលបានគំរាមកំហែងបុគ្គលណាម្នាក់ ទោះបីជាគ្រោះថ្នាក់នោះមិនបានបណ្តាលឱ្យបាត់បង់ជីវិតក៏ដោយ។ ក្រមព្រហ្មទណ្ឌមិនបានបញ្ញត្តច្បាស់ថា អំពើឈ្លានពានចាំបាច់ត្រូវតែជាបទល្មើសព្រហ្មទណ្ឌឡើយ គ្រាន់តែបានបញ្ជាក់ថាត្រូវតែជាការឈ្លានពានមិនត្រឹមត្រូវតែប៉ុណ្ណោះ បានសេចក្តីថា ទោះបីជាអំពើឈ្លានពាននោះមិនមែនជាបទល្មើសព្រហ្មទណ្ឌ ក៏អាចជាមូលហេតុគ្រប់គ្រាន់នាំឱ្យមានការការពារស្របច្បាប់បានដែរ។ ឧទាហរណ៍ ការចាប់ខ្លួនជនណាម្នាក់ដោយអាជ្ញាធរមានសមត្ថកិច្ចមិនមែនជាការឈ្លានពានមិនត្រឹមត្រូវឡើយ ផ្ទុយទៅវិញ ការការពាររបស់ជនដែលត្រូវចាប់ខ្លួន ពុំមែនជាការការពារស្របច្បាប់នោះទេ។

នៅពេលការឈ្លានពានបានកើតមានឡើង នោះការការពារការឈ្លានពានក៏កើតមានបន្ទាប់ពីនោះ ដើម្បីការពារ ឬទប់ទល់ដោយចាំបាច់។

### គ. ការការពារការឈ្លានពាន

ត្រង់នេះមានន័យថា ត្រូវមានការឈ្លានពានជាមុន ហើយបទល្មើសដែលយើងប្រព្រឹត្តដើម្បីទប់ទល់នឹងការឈ្លានពានត្រូវចាំបាច់ (ប្រសិនបើយើងអាចជៀសវាងតាមមធ្យោបាយផ្សេងគឺគេចាត់ទុកថាមិនចាំបាច់ទេ) ដែលយើងមានតែផ្លូវមួយគត់ដើម្បីប្រព្រឹត្តបទល្មើសតទល់ជាមួយនឹងការឈ្លានពាន ហើយការប្រើប្រាស់មធ្យោបាយនោះទៅតាមសមាមាត្រនឹងទំហំគ្រោះថ្នាក់នៃការឈ្លានពាន[135]។

តាមច្បាប់ ការការពារការឈ្លានពានត្រូវមានលក្ខណៈដូចតទៅ៖

**- ការការពារត្រូវតែកើតឡើងក្នុងពេលជាមួយគ្នានឹងការឈ្លានពាន៖** មានន័យថា ការការពារត្រូវតែធ្វើឡើងភ្លាមៗ ក្នុងខណៈដែលការឈ្លានពានបានកើតឡើង។ ប្រសិនបើការឈ្លានពានបានបញ្ចប់ទៅហើយទើបធ្វើការតបតជាក្រោយ នោះវាគឺជាការសងសឹកទៅវិញទេ មិនមែនជាការការពារស្របច្បាប់ឡើយ។ឧទាហរណ៍ បុគ្គលម្នាក់បានដកកាំភ្លើងបាញ់ចំពោះអ្នកឈ្លានពានខ្លួនពេលដែលអ្នកឈ្លានពានបានវ៉ៃមកលើខ្លួនហើយក៏រត់គេចបែរខ្នង ហើយខ្លួនក៏ដកកាំភ្លើងបាញ់ នេះមិនមែនស្ថិតក្នុងការការពារស្របច្បាប់ទេ ព្រោះថាអ្នកដែលឈ្លានពាននោះ

[135] ប្រសាសន៍របស់ឯកឧត្តម ផូវ សំភី អគ្គនាយកនៃអគ្គនាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍លើវិស័យយុត្តិធម៌, អគ្គលេខាធិការរងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី "ក្រមព្រហ្មទណ្ឌ" ដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌សហការណ៍ជាមួយក្រសួងព័ត៌មានតាមរយៈទូរទស្សន៍ជាតិកម្ពុជាឆ្នាំ២០១០។

បានរត់ ហើយគ្រោះថ្នាក់ដែលកើតពីការឈ្លានពាននោះបានបាត់ឡើង ហើយទម្ងន់នៃការឈ្លានពាននោះវាមានលក្ខណៈស្រាល។

**- ការការពារត្រូវតែចាំបាច់៖** ការការពារត្រូវតែចាំបាច់សម្រាប់ស្រោចស្រង់ផលប្រយោជន៍ដែលត្រូវបានគំរាមកំហែង មានន័យថា ការការពារត្រូវតែជាការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិ ឬនិយាយម្យ៉ាងទៀតបានថា ប្រតិកម្មតបតរបស់អ្នកការពារ គឺជាមធ្យោបាយតែមួយគត់ដើម្បីអាចបញ្ចៀសការឈ្លានពានបាននៅក្នុងកាលៈទេសៈនៃរឿងហេតុនាពេលនោះ។ ក្នុងន័យនេះ ភាពបន្ទាន់នៃគ្រោះថ្នាក់ជាឧបសគ្គសំខាន់មួយដែលធ្វើឱ្យជនរងគ្រោះមិនអាចជ្រើសរើសយកការប្រើប្រាស់មធ្យោបាយផ្សេងៗទៀតបានក្រៅតែពីការប្រព្រឹត្តបទល្មើសជាការតបតទៅលើអ្នកឈ្លានពានវិញ ដូចជាការប្ដឹងអាជ្ញាធរមានសមត្ថកិច្ច ឬក៏រត់គេចខ្លួនចេញពីការឈ្លានពាន។ ឧទាហរណ៍ ក្រោយពីបានគេចរួចផុតពីការឈ្លានពានម្ដងហើយ **ក** បានទៅយកកាំភ្លើងនៅផ្ទះរបស់ខ្លួន មកបាញ់ទៅលើ **ខ** ដែលជាអ្នកបានឈ្លានពានមកលើខ្លួន។ នៅក្នុងករណីបែបនេះ អំពើរបស់ **ក** មិនមែនជាការចាំបាច់សម្រាប់ការពារខ្លួនទៀតទេ។ មួយវិញទៀត នៅក្នុងករណីខ្លះ ជនរងគ្រោះស្ថិតក្នុងស្ថានភាពកាន់តែទទួលរងនូវគ្រោះថ្នាក់ថែមទៀតប្រសិនបើជនរងគ្រោះព្យាយាមរត់គេចពីការឈ្លានពានជាជាងប្រឈមមុខតបតទៅនឹងការឈ្លានពានវិញ។ ហេតុនេះ ទោះបីជានៅក្នុងស្ថានភាពដែលជនម្នាក់អាចរត់គេចខ្លួនបានតែនៅទីបំផុតបែរជាមិនរត់គេចហើយនៅប្រឈមមុខតបតទៅលើអ្នកឈ្លានពានវិញក៏ដោយ ក៏អាចចាត់ទុកថាជាការការពារស្របច្បាប់បានដែរ។

**- មធ្យោបាយការពារដែលប្រើប្រាស់ត្រូវតែគ្មានវិសមាមាត្រជាមួយនឹងទម្ងន់នៃការឈ្លានពាន៖** មានន័យថា មធ្យោបាយដែលបានប្រើប្រាស់ត្រូវតែឆ្លើយតបទៅតាមសភាពធ្ងន់ធ្ងរនៃការឈ្លានពានមិនត្រឹមត្រូវនោះ។ ជាការពិត ការវាយតម្លៃអំពីវិសមាមាត្រនៃមធ្យោបាយការពារខ្លួន និងទម្ងន់នៃការឈ្លានពាន គឺអាស្រ័យទៅតាមករណីនីមួយៗដូចជា កាលៈទេសៈ ឬបុគ្គលិកលក្ខណៈរបស់អ្នកដែលទទួលរងនូវការឈ្លានពានជាដើម ហេតុដូច្នេះ ប្រសិនបើគ្រាន់តែមានគោលដៅដើម្បីការពារទ្រព្យសម្បត្តិតែប៉ុណ្ណោះ អ្នកការពារមិនអាចឈានរហូតដល់ថ្នាក់ទៅសម្លាប់អ្នកឈ្លានពានបានទេ មានន័យថា តម្លៃនៃទ្រព្យសម្បត្តិមិនអាចសមាមាត្រ ឬប្រៀបធៀបផ្ទឹមនឹងជីវិតមនុស្សបានឡើយ។ ឧទាហរណ៍ ដើម្បីទប់ទល់នឹងបុរសម្នាក់ដែលបានចាប់ និងបង្ខាំងរូបនាង ព្រមទាំងមានបំណងចាប់រូបនាងរំលោភសេពសន្ថវៈទៀតនោះ នារីរងគ្រោះក៏ស្រវាបានកំណាត់ឈើស្រួចមួយ ហើយចាក់ទៅលើបុរសឈ្លានពានរូបនាង បណ្ដាលឱ្យបុរសនោះស្លាប់ ក្នុងខណៈពេលដែលបុរសនោះកំពុងតែសង្គ្រប់ពីលើរូបនាងបម្រុងនឹងរំលោភ។ ក្នុងករណីដូចនេះគួរតែចាត់ទុកថា អំពើរបស់នារីរងគ្រោះ មានសមាមាត្រជាមួយនឹងទម្ងន់នៃអំពើឈ្លានពាន ពីព្រោះថា ការបំពានខាងផ្លូវភេទលើនារីម្នាក់ គឺជាអំពើដែលមានលក្ខណៈធ្ងន់ធ្ងរ ដែល

គប្បីឱ្យនារីរងគ្រោះតបតទៅវិញបែបនេះបាន។ ដូចនេះ នារីរងគ្រោះមិនត្រូវទទួលខុសត្រូវដោយសារតែអំពើសម្លាប់អ្នកដែលបានឈ្លានពានលើរូបនាងឡើយ។

មានករណីមួយទៀតដែលក្នុងក្របខណ្ឌនៃការការពារស្របច្បាប់បានកំណត់សន្មត់ថាជាការការពារស្របច្បាប់តែម្តង ហើយវាទាក់ទងនឹងបន្ទុកនៃភស្តុតាង។ ក្នុងករណីដែលច្បាប់សន្មត់ថាស្ថិតក្នុងការការពារស្របច្បាប់នេះ គឺបន្ទុកនៃភស្តុតាងធ្លាក់ទៅលើស្ថាប័នដែលចោទប្រកាន់អាជ្ញាធរមានសមត្ថកិច្ច។ ដូច្នេះក្នុងករណីនេះច្បាប់បានកំណត់ករណី **២ យ៉ាង**ដែលស្ថិតក្នុងការការពារស្របច្បាប់ថា៖

❖ **ករណីទី១** ត្រូវសន្មត់ថាជាការការពារស្របច្បាប់នៅក្នុងករណី បទល្មើសត្រូវបានប្រព្រឹត្តដើម្បីរុញច្រានការចូលក្នុងពេលយប់ដោយមានការកាប់គាស់ទម្លុះទម្លាយដោយហិង្សា ឬដោយយកកលល្បិចនៅក្នុងកន្លែងដែលមានមនុស្សរស់នៅនៅពេលយប់។ ហេតុនេះ ការចូលក្នុងពេលយប់នៅកន្លែងដែលមានមនុស្សរស់នៅតាមរយៈការប្រើប្រាស់សោរក្លែង ឬក៏កាប់គាស់ទម្លុះទម្លាយ អនុញ្ញាតឱ្យម្ចាស់ទីកន្លែងប្រើមធ្យោបាយទប់ទល់ដើម្បីរុញច្រានអ្នកនោះវិញ។

❖ **ករណីទី២** បទល្មើសបានប្រព្រឹត្តដើម្បីការពារខ្លួនប្រឆាំងនឹងការលួច ឬការប្លន់ ដែលអនុវត្តដោយហិង្សា។ ដូច្នោះស្ថិតក្នុងស្ថានភាពដែលមានចោរប្លន់ ឬលួចដោយប្រើហិង្សា ប្រើប្រាស់អាវុធ យើងអាចប្រើមធ្យោបាយដើម្បីទប់ទល់វិញ ដែលត្រង់នេះយើងស្ថិតក្នុងស្ថានភាពនៃសច្ចាធារណ៍នៃការការពារស្របច្បាប់ មានន័យថាបន្ទុកភស្តុតាងត្រូវធ្លាក់ទៅលើអាជ្ញាធរមានសមត្ថកិច្ច គឺអយ្យការជាអ្នករកភស្តុតាងថាយើងមិនស្ថិតក្នុងស្ថានភាពនៃការការពារស្របច្បាប់ទេ។ សច្ចាធារណ៍ ឬការសន្មត់ថាការការពារស្របច្បាប់នេះ ពុំមានលក្ខណៈដាច់ខាតទេ គឺអាចត្រូវរំលាយដោយភស្តុតាងផ្ទុយ ហេតុដូច្នេះហើយបានជាទោះបីយើងស្ថិតនៅក្នុងស្ថានភាពនៃការសន្មតថាការការពារស្របច្បាប់ក៏ដោយក៏មិនអនុញ្ញាតឱ្យយើងប្រើប្រាស់នូវមធ្យោបាយតទល់មានវិសមាមាត្រជាមួយនឹងអំពើឈ្លានពានទេ ហើយដែលយើងយល់ច្បាស់ទៀត។

កាលបើអំពើមួយត្រូវបានចាត់ទុកថាជាការការពារស្របច្បាប់ហើយ ចារីមិនត្រឹមតែមិនទទួលខុសត្រូវព្រហ្មទណ្ឌប៉ុណ្ណោះទេ គឺថែមទាំងមិនត្រូវទទួលខុសត្រូវរដ្ឋប្បវេណីទៀតផង។ ជាក់ស្តែង សូម្បីក្រមរដ្ឋប្បវេណីបានចែងថា អំពើការពារជាធម្មានុរូប សំដៅទៅលើអំពើរំលោភដែលពុំអាចជៀសវាងបាន ដើម្បីការពាររូបរាងកាយ ឬទ្រព្យសម្បត្តិរបស់ខ្លួន ឬរបស់អ្នកដទៃចំពោះអំពើបំពានមិនត្រឹមត្រូវ ហើយដែលស្ថិតក្នុងករណីដែលពេលវេលានៃអំពើបំពាន និងអំពើរំលោភនោះស្ថិតជិតគ្នា និងមានតុល្យភាពរវាងវិធីការពារ និងកម្រិតនៃអំពើបំពាននោះ[136]។ ផ្អែកតាមនិយមន័យខាងលើបង្ហាញឱ្យយើងឃើញថា ទោះបីជាក្រមរដ្ឋប្បវេណីមិនបានប្រើពាក្យដូចគ្នាទាំងស្រុងជាមួយនឹងពាក្យនៅក្នុងក្រមព្រហ្មទណ្ឌ ក៏ខ្លឹមសារ និងលក្ខខណ្ឌតម្រូវនៃ **កិច្ចការពារជាធម្មានុរូប** និង**ការការពារ**

[136] មាត្រា ៧៥៥ កថាខណ្ឌ ១, ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧ ។

**ស្របច្បាប់** មិនខុសប្លែកគ្នាទេ។ ហេតុដូច្នេះ អ្នកប្រព្រឹត្តអំពើការពារជាធម្មានុរូបមិនទទួលខុសត្រូវចំពោះការខូចខាតដែលបានកើតឡើងនោះឡើយ[137]។

ដូចគ្នានេះដែរ ស្ថានភាពចាំបាច់ក៏ជាមូលហេតុមួយក្នុងចំណោមមូលហេតុបីនៃមូលហេតុខាងក្រៅបុគ្គលនៃចារី ឬអ្នកប្រព្រឹត្តបទល្មើសផងដែរ។

### ៣.២.២.៣. ស្ថានភាពចាំបាច់

គោលការណ៍ចុងក្រោយដែលជាមូលហេតុមួយដែរដែលនាំឱ្យអ្នកប្រព្រឹត្តបទល្មើសរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ មានន័យថាគាត់ប្រព្រឹត្តបទល្មើស តែគាត់មិនទទួលខុសត្រូវព្រហ្មទណ្ឌ ហើយមិនទទួលទណ្ឌកម្មព្រហ្មទណ្ឌដែរ ដែលហៅថា **ស្ថានភាពចាំបាច់**។ ស្ថានភាពចាំបាច់ គឺជាស្ថានភាពរបស់បុគ្គលម្នាក់ដែលឈានទៅដល់ការប្រព្រឹត្តបទល្មើសណាមួយ គឺមូលហេតុដោយសារតែបុគ្គលនោះមានបំណងចង់ជួយស្ដារនូវផលប្រយោជន៍មួយផ្សេងទៀតដែលត្រូវបានគំរាមកំហែងដោយគ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមាន។

ស្ថានភាពចាំបាច់នេះវាទាល់តែស្ថិតនៅពេលដែលគ្រោះថ្នាក់កំពុងមាន ឬដែលនឹងកើតមាន (**ក**) ដែលត្រូវធ្វើការការពារជាចាំបាច់(**ខ**) ហើយការការពារនោះគឺគ្មានវិសមាមាត្រជាមួយនឹងទម្ងន់នៃគ្រោះថ្នាក់(**គ**)។

#### ក. គ្រោះថ្នាក់កំពុងមាន ឬដែលនឹងកើតមាន

ជាដំបូង ជនដែលប្រព្រឹត្តបទល្មើសដោយសារតែមានស្ថានភាពចាំបាច់ត្រូវរកភស្តុតាងអំពីគ្រោះថ្នាក់ដែលជាកត្តាជំរុញឱ្យខ្លួនទៅប្រព្រឹត្តបទល្មើស។ គ្រោះថ្នាក់នេះអាចជាគ្រោះថ្នាក់ដែលគំរាមកំហែងខ្លួនចារីផ្ទាល់តែម្តង ឬគំរាមកំហែងតតិយជន ឬក៏គ្រាន់តែគំរាមកំហែងលើទ្រព្យសម្បត្តិណាមួយក៏បាន។ ស្ថានភាពចាំបាច់គឺច្បាប់កំណត់លក្ខខណ្ឌថា បទល្មើសត្រូវចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ការពារទ្រព្យសម្បត្តិ ប្រឆាំងនឹងគ្រោះថ្នាក់ដែលកំពុងនឹងកើតមាន ឬដែលនឹងកើតមាន ហើយគ្មានវិសមាមាត្ររវាងមធ្យោបាយការពារ និងទម្ងន់នៃគ្រោះថ្នាក់។

ឧទាហរណ៍៖ ដើម្បីកុំឱ្យកូនរបស់ខ្លួនអត់អាហារបរិភោគដែលអាចនឹងស្លាប់បាត់បង់ជីវិត ស្ត្រីជាម្តាយបានសម្រេចចិត្តលួចបាយ ឬអង្ករយកមកដាំឱ្យកូនដើម្បីចិញ្ចឹមជីវិតកូន។ សកម្មភាពនេះគឺជាការបញ្ចៀសពីគ្រោះថ្នាក់ដល់អាយុជីវិតកូនរបស់ចារីដែលបានប្រព្រឹត្តអំពើលួច។

#### ខ. ការការពារជាចាំបាច់

ដើម្បីឱ្យមានយុត្តិកម្មបាន បទល្មើសដែលប្រព្រឹត្តដោយចារីត្រូវតែជាអំពើចាំបាច់ដើម្បីការពារខ្លួនឯងការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិ។ ត្រង់ចំណុចនេះមានន័យថា ការប្រព្រឹត្តបទល្មើសជាជម្រើសដ៏ប្រសើរ

[137] មាត្រា ៧៥៦ កថាខណ្ឌ ២, ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧ ។

បំផុតដើម្បីអាចបញ្ចៀសគ្រោះថ្នាក់បាន។ ចំពោះការវាយតម្លៃថា ការការពារតាមរយៈការប្រព្រឹត្តបទល្មើសជាការការពារចាំបាច់ ឬអត់ ឬយ៉ាងណានោះគឺអាស្រ័យទៅតាមអង្គហេតុនៃករណីនីមួយៗ។

ឧទាហរណ៍៖ នារីម្នាក់បានសម្រេចចិត្តលួចសាច់គោគេ ដើម្បីឱ្យកូនរបស់នាងបានបរិភោគនូវអាហារឆ្ងាញ់ជាងធម្មតា។ ក្នុងស្ថានភាពបែបនេះ នារីខាងលើមិនអាចលើកសំអាងពីស្ថានភាពចាំបាច់ដើម្បីឱ្យបានរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ពីព្រោះថាគឺពិតជាពុំមានការចាំបាច់ឡើយ។

**គ. ការការពារដែលគ្មានវិសមាមាត្រជាមួយនឹងទម្ងន់គ្រោះថ្នាក់**

នៅត្រង់នេះចារីត្រូវរកភស្តុតាងមកបង្ហាញឱ្យឃើញច្បាស់ថាបទល្មើសដែលខ្លួនបានប្រព្រឹត្តមានលក្ខណៈសមាមាត្រទៅនឹងភាពធ្ងន់ធ្ងរនៃគ្រោះថ្នាក់។ ផលវិបាកនៃបទល្មើសត្រូវតែមានតម្លៃតិចជាង ឬក៏យ៉ាងហោចណាស់ស្មើនឹងតម្លៃដែលចារីមានបំណងចង់ជួយស្រោចស្រង់សង្គ្រោះ។ ភាពសមាមាត្រនៃមធ្យោបាយការពារ និងទម្ងន់នៃគ្រោះថ្នាក់ត្រូវវាយតម្លៃទៅតាមស្ថានភាពនៃករណីនីមួយៗ។

ក្នុងស្ថានភាពចាំបាច់ចារីមានជម្រើសពីរយ៉ាងគឺ៖

- ទី១ ទទួលយកការខូចខាតដែលនឹងកើតមាន ដោយសុខចិត្តបដិសេធមិនព្រមប្រព្រឹត្តបទល្មើស។
- ទី២ ត្រូវតែប្រព្រឹត្តបទល្មើស ដើម្បីបញ្ចៀសការខូចខាត[138]។

ឧទាហរណ៍៖ អ្នកបើកបរម្នាក់គាត់បានសម្រេចចិត្តថាឆ្លងកាត់គំនូសចរាចរណ៍ដែលហាមឃាត់ដើម្បីជៀសវាងកុំឱ្យបើកបុកអ្នកថ្មើរជើងម្នាក់។ ដូច្នេះយើងឃើញថាអ្នកបើកបរបើកឆ្លងកាត់គំនូសចរាចរណ៍ដែលហាមឃាត់ វាជាបទល្មើសចរាចរណ៍ ប៉ុន្តែដោយសារបុគ្គលនោះស្ថិតក្នុងស្ថានភាពចាំបាច់ដើម្បីជៀសវាងគ្រោះថ្នាក់មួយដែលអាចនឹងបើកបុកអ្នកថ្មើរជើង ហេតុនេះអ្វីដែលស្ថិតជាចម្បងក្នុងស្ថានភាពចាំបាច់គឺជាជញ្ជីងមួយថ្លឹងរវាងផលប្រយោជន៍ដែលការពារ និងផលប្រយោជន៍ដែលលះបង់។ ដូច្នេះផលប្រយោជន៍ដែលត្រូវការពារត្រូវតែធំជាងផលប្រយោជន៍ដែលលះបង់ ឬអាចស្មើ ដែលនេះជាជញ្ជីងដែលគេថ្លឹងក្នុងស្ថានភាពចាំបាច់។

ស្ថានភាពចាំបាច់នេះត្រូវបានចាត់ទុកជាយុត្តិកម្មនៃបទល្មើសមួយដែរ ដែលនៅក្នុងក្រមព្រហ្មទណ្ឌបានចែងយ៉ាងច្បាស់ថា" បុគ្គលដែលស្ថិតនៅក្នុងការចាំបាច់ត្រូវតែប្រព្រឹត្តបទល្មើស នោះគឺមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ... "[139]។

គួរកត់សម្គាល់ជាចុងក្រោយថា ក្រមរដ្ឋប្បវេណីក៏បានចែងពីស្ថានភាពចាំបាច់ផងដែរ។ ក្រមរដ្ឋប្បវេណីបានកំណត់និយមន័យនៃស្ថានភាពចាំបាច់ថា អំពើដោយសារស្ថានភាពចាំបាច់សំដៅទៅលើអំពើរំលោភដែលពុំអាចជៀសវាងបាន ដើម្បីការពាររូបរាងកាយ ឬទ្រព្យសម្បត្តិរបស់ខ្លួន ឬអ្នកដទៃ ចំពោះគ្រោះថ្នាក់បច្ចុប្បន្ន ឬក៏

[138] និតិព្រហ្មទណ្ឌទូទៅ, សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ(ឆ្នាំ ២០២២) ទំព័រ ៣៨៩។
[139] មាត្រា ៣៥, ក្រមព្រហ្មទណ្ឌ លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩ ។

អច្ចាសន្ន(គ្រោះថ្នាក់ដែលហៀបនឹងកើតឡើងយ៉ាងពិតប្រាកដ) ហើយដែលស្ថិតក្នុងករណីមានតុល្យភាពរវាងវិធីការពារ និងកម្រិតគ្រោះថ្នាក់នោះ។ យោងតាមខ្លឹមសារនៃបញ្ញត្តិនេះឃើញថា ស្ថានភាពចាំបាច់តាមក្រមរដ្ឋប្បវេណី មិនខុសប្លែកពីស្ថានភាពចាំបាច់តាមក្រមព្រហ្មទណ្ឌឡើយ។ មួយវិញទៀត ក្រមរដ្ឋប្បវេណីបានកំណត់ពីបញ្ហាសំណងនៃការខូចខាតថា ចំពោះការខូចខាតដែលកើតមានឡើងដោយសារស្ថានភាពចាំបាច់ អ្នកបានប្រព្រឹត្តអំពើដោយសារស្ថានភាពចាំបាច់ពុំទទួលខុសត្រូវឡើយ។ ក្នុងករណីនេះ បុគ្គលដែលបានប្រព្រឹត្តអំពើផ្ទុយច្បាប់ដែលជាមូលហេតុនៃអំពើនោះ គឺជាអ្នកត្រូវទទួលខុសត្រូវ។ ហេតុដូច្នេះ តាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បុគ្គលដែលបានប្រព្រឹត្តបទល្មើសដោយសារស្ថានភាពចាំបាច់ មិនទទួលខុសត្រូវក្នុងការសងការខូចខាតឡើយ ក៏ប៉ុន្តែជនដែលបានបង្កឱ្យមានការប្រព្រឹត្តបទល្មើសគឺជាអ្នកទទួលខុសត្រូវសងការខូចខាតទៅវិញ។

ឧទាហរណ៍៖ ដើម្បីជួយសង្គ្រោះជនរងគ្រោះដែលមិនអាចចាកចេញពីផ្ទះដែលកំពុងតែមានអគ្គិភ័យឆេះឆាប លោក **ក** បានធាក់ទ្វារផ្ទះអ្នកជិតខាងឱ្យរបើកដើម្បីអាចចូលទៅកាន់ផ្ទះរបស់ជនរងគ្រោះ។ ក្នុងករណីបែបនេះ លោក **ក** បានធ្វើឱ្យខូចខាតទ្វារដែលជាទ្រព្យសម្បត្តិរបស់អ្នកដទៃដោយចេតនា ក៏ប៉ុន្តែជាអំពើដែលធ្វើឡើងក្នុងស្ថានភាពចាំបាច់។ ដូច្នេះ លោក **ក** មិនទទួលខុសត្រូវព្រហ្មទណ្ឌ ហើយក៏មិនទទួលខុសត្រូវសងការខូចខាតដែរ។ តាមពិត ជនដែលបង្កឱ្យមានអគ្គិភ័យគឺជាអ្នកត្រូវទទួលខុសត្រូវសងការខូចខាតនោះ មិនមែនឱ្យអ្នកដែលខំជួយសង្គ្រោះដែលធ្វើឱ្យបាក់បែកខូចខាតទ្វារជាអ្នកចេញសងទេ។

សរុបមកប្រសិនបើប្រៀបធៀបកម្មវត្ថុនៃការការពារនៅក្នុងស្ថានភាពចាំបាច់គឺដូចគ្នានឹងការការពារនៅក្នុងករណីការការពារស្របច្បាប់ តែអ្វីដែលធ្វើឱ្យស្ថានភាពចាំបាច់ខុសពីការការពារស្របច្បាប់នោះគឺដោយសារចារីប្រឈមនឹងគ្រោះថ្នាក់មួយដែលមិនកើតចេញពីការឈ្លានពានមិនត្រឹមត្រូវ ព្រោះនៅក្នុងការការពារស្របច្បាប់ត្រូវតែមានការឈ្លានពានមិនខុសច្បាប់។ នៅក្នុងស្ថានភាពចាំបាច់ ចារីស្ថិតនៅប្រឈមចំពោះគ្រោះថ្នាក់មួយដែលអាចកើតចេញពីគ្រោះថ្នាក់កើតចេញដោយឯកឯង។ មួយវិញទៀត ស្ថានភាពចាំបាច់ខុសជាមួយនឹងអានុភាពនៃកម្លាំងដោយសារនៅក្នុងស្ថានភាពចាំបាច់នេះ ចារីគាត់មានសេរីភាពក្នុងជម្រើសរបស់ខ្លួន ចំណែកក្នុងស្ថានភាពអានុភាពនៃកម្លាំងចារីមិនអាចទប់ទល់បាន ហើយគ្មានជម្រើសនោះទេ។ ដូច្នេះនៅក្នុងស្ថានភាពចាំបាច់ចារីគាត់មានសេរីភាពក្នុងការប្រព្រឹត្ត ឬមិនប្រព្រឹត្ត។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការស្រាវជ្រាវនូវប្រធានបទស្តីពី " បទល្មើស និងការទទួលខុសត្រូវព្រហ្មទណ្ឌ " រួចមកស បញ្ជាក់ឱ្យឃើញថា ការកំណត់បទល្មើសព្រហ្មទណ្ឌ និងដឹងពីការទទួលខុសត្រូវព្រហ្មទណ្ឌ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការរក្សាឱ្យបាននូវសុខសុវត្ថិភាព និងស្ថិរភាពនយោបាយសង្គម។ តាមការបកស្រាយខាងដើម ចំណុចដែលសំខាន់នៅក្នុងរឿងព្រហ្មទណ្ឌនោះគឺថាតើបុគ្គលបែបណាដែលអាចទទួលខុសត្រូវព្រហ្មទណ្ឌបាន ដែលនៅក្នុងការបកស្រាយខាងលើបានរៀបរាប់យ៉ាងក្បោះក្បាយថា បុគ្គលដែលបានដល់នីតិភាពអាយុចាប់ពី ១៨ឆ្នាំ ឡើង។ ប៉ុន្តែ បុគ្គលដែលអាយុក្រោម ១៨ឆ្នាំ (អនីតិជន) ក៏អាចទទួលខុសត្រូវព្រហ្មទណ្ឌបានដែរប្រសិនបើចរិតគ្រោះថ្នាក់ និងបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ។ ត្រង់នេះអាចនិយាយម្យ៉ាងទៀតបានថា ជាទូទៅឱ្យតែបុគ្គលណាដែលបានប្រព្រឹត្តនូវបទល្មើសព្រហ្មទណ្ឌ ហើយគេរកឃើញថាបទល្មើសមួយនោះមានធាតុផ្សំគ្រប់គ្រាន់អស់ហើយ នោះបុគ្គលដែលប្រព្រឹត្តបទល្មើសនោះត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌ។ ទោះជាយ៉ាងនេះក្តី ក៏មានករណីអញ្ញត្រកម្មផងដែរដែលបុគ្គលម្នាក់បានសម្រេចចិត្តប្រព្រឹត្តបទល្មើសដោយសារស្ថានភាពចាំបាច់ ការការពារស្របច្បាប់ ស្ថិតក្រោមអានុភាពកម្លាំងបង្ខំ ឬមួយប្រព្រឹត្តបទល្មើសក្នុងស្ថានភាពមានវិបល្លាសស្មារតីជាដើម នោះច្បាប់ពុំតម្រូវឱ្យជននេះទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។

យ៉ាងណាមិញ ច្បាប់ព្រហ្មទណ្ឌគឺជាច្បាប់សាធារណៈ ដូចនេះការបង្កើតច្បាប់នេះឡើងមានគោលបំណងដើម្បីរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈជូនប្រជាពលរដ្ឋ និងប្រជាជាតិទាំងមូល។ ហេតុនេះដើម្បីទទួលបាននូវសុខសណ្តាប់ធ្នាប់សាធារណៈល្អមួយ ច្បាប់ព្រហ្មទណ្ឌបានចែងពីទោស និងបទល្មើសដែលជាសកម្មភាពបង្កឱ្យមានចលាចល គ្រោះថ្នាក់ដល់សង្គម និងដាក់ទោសទៅលើជនណាដែលបានប្រព្រឹត្តបទល្មើសទាំងនោះ។ មួយវិញទៀត ដើម្បីឱ្យបុគ្គលណាម្នាក់ទទួលខុសត្រូវព្រហ្មទណ្ឌបាន ទាល់តែបុគ្គលនោះបានបំពេញនូវធាតុផ្សំ ៣ យ៉ាងដែលច្បាប់ព្រហ្មទណ្ឌបានកំណត់នោះរួមមាន ធាតុនីត្យានុកូល(ធាតុច្បាប់) ធាតុសត្យានុម័ត(ធាតុសម្ភារៈ) និងចុងក្រោយគឺធាតុអត្តនោម័ត(ធាតុចិត្តសាស្ត្រ) ពោលគឺប្រសិនបើធាតុផ្សំទាំង ៣ នេះបានបំពេញគ្រប់អស់ហើយ បុគ្គលដែលបានប្រព្រឹត្តបទល្មើសគឺមិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ ក៏ប៉ុន្តែប្រសិនបើខ្វះតែធាតុផ្សំណាមួយវិញ នោះគេមិនអាចចាត់ទុកថាបុគ្គលនោះប្រព្រឹត្តបទល្មើសបានឡើយ។ រីឯការដាក់ទោសទៅលើជនដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌវិញ គឺច្បាប់ព្រហ្មទណ្ឌក៏បានធ្វើការបែងចែកនូវចំណាត់ថ្នាក់បទល្មើសនីមួយៗ ដើម្បីងាយស្រួលក្នុងការដាក់ទោសថាតើបុគ្គលណាខ្លះប្រព្រឹត្តបទល្មើសធ្ងន់ បុគ្គលណាដែលប្រព្រឹត្តបទល្មើសស្រាល ដែលការធ្វើចំណាត់ថ្នាក់បទល្មើសនេះច្បាប់ចែកជា ៣ ចំណាត់ថ្នាក់រួមមានដូចជា បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ។ ប្រសិនបើគ្មានការបែងចែកចំណាត់ថ្នាក់នៃបទល្មើសយ៉ាងនេះទេ នោះប្រាកដជាមានការស្មុគស្មាញខ្លាំងនៅក្នុងការចោទប្រកាន់បទល្មើសហើយ ព្រោះថា បទល្មើសនីមួយៗវា

មិនដូចគ្នានោះទេ វាមានបង្កគ្រោះថ្នាក់ដល់សង្គមធ្ងន់ធ្ងរ ឬពេលខ្លះវាបង្កគ្រោះថ្នាក់លក្ខណៈស្រាល ហេតុនេះហើយទើបច្បាប់ធ្វើការបែងចែកចំណាត់ថ្នាក់បទល្មើសនេះឡើង។

ជាចុងក្រោយ ប្រធានបទមួយនេះចង់បង្ហាញថា បទល្មើសព្រហ្មទណ្ឌ ពិតជាមានសារៈសំខាន់ខ្លាំងមែនទែន ដើម្បីធ្វើឱ្យសង្គមមួយមានសណ្តាប់ធ្នាប់ល្អ មានរបៀបរៀបរយ និងរក្សាបាននូវសន្តិសុខសង្គមដើម្បីប្រទេសជាតិមានការអភិវឌ្ឍន៍ទៅមុខ។

# អនុសាសន៍

# អនុសាសន៍

តាមរយៈការស្រាវទៅលើប្រធានបទខាងលើរួចមកយើងសង្កេតឃើញថា បទល្មើសដែលបានកើតឡើងទាំងអស់ សុទ្ធតែត្រូវបានអនុវត្តទៅតាមនីតិវិធីច្បាប់កំណត់ក្នុងខ្លឹមសារច្បាប់ ពោលគឺនៅពេលដែលបទល្មើសបានកើតឡើង នោះជនដែលបានប្រព្រឹត្តបទល្មើសត្រូវតែទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនមិនថាស្ថិតក្នុងឋានៈជាចារី សហចារី ជាអ្នកផ្តើមគំនិត ឬជាអ្នកសមគំនិតនោះទេ កាលបើធាតុផ្សំទាំងឡាយដែលច្បាប់កំណត់បានបំពេញសព្វគ្រប់ហើយ ជនដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌ។

ជាការពិត ច្បាប់បានចែងពីបទល្មើស និងទណ្ឌកម្មសម្រាប់ដាក់ទៅលើជនដែលបានប្រព្រឹត្តបទល្មើសគឺមានគោលបំណងធានាឱ្យបាននូវសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ ការពាររាល់អំពើប្រឆាំងនឹងមនុស្សប្រឆាំងនឹងការប៉ះពាល់ដល់បូរណភាពបុគ្គល ក៏ដូចជាប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ សេរីភាព សិទ្ធិមនុស្ស រួមទាំងអំពើលួច ឬបំផ្លិចបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃជាដើម ហើយជនដែលបានប្រព្រឹត្តរាល់អំពើទាំងនោះនឹងត្រូវផ្តន្ទាទោសទៅតាមទម្ងន់នៃអំពើរបស់ខ្លួន។ រាល់ការផ្តន្ទាទោសទៅលើជនណាមួយនោះ គឺវាទាក់ទងនឹងស្ថាប័នតុលាការដែលជាអ្នកអនុវត្តច្បាប់ដែលមានចៅក្រមជាអ្នកកាត់ក្តី រួមទាំងស្ថាប័នអយ្យការដែលមាន ព្រះរាជអាជ្ញាជាអ្នកធ្វើការចោទប្រកាន់លើបទល្មើសព្រហ្មទណ្ឌ និងមន្ត្រីដែលមានសមត្ថកិច្ចដទៃទៀត។ ការអនុវត្តច្បាប់ត្រូវតែធ្វើឡើងស្របទៅតាមច្បាប់ មិនលម្អៀង ដើម្បីធានាបាននូវការកាត់ក្តីទៅលើបទល្មើសមួយដោយភាពយុត្តិធម៌។

ទន្ទឹមនឹងនេះ ពេលខ្លះក៏មានភាពខ្វះចន្លោះតែងតែកើតមានឡើងផងដែរ។ ហេតុនេះ ដើម្បីឱ្យមានការកំណត់បទល្មើសមួយប្រកបដោយភាពល្អប្រសើរ និងធ្វើការដាក់ទោសលើជនល្មើសឱ្យមានភាពយុត្តិធម៌ រាជរដ្ឋាភិបាលគួរធ្វើការពង្រឹង និងបំពេញបន្ថែមនូវចំណុចខ្វះខាតមួយចំនួនមានតាមលំដាប់លំដោយដូចតទៅ៖

១. ពង្រឹងការអនុវត្តនីតិវិធីគ្រប់ដំណាក់កាល ពោល តាំងពីដំណាក់កាលនគរបាលយុត្តិធម៌ គឺរៀបចំបង្កើតឱ្យមានការបណ្តុះបណ្តាលជំនាញដល់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងការស្រាវជ្រាវស្វែងរកបទល្មើស រួមទាំងនីតិវិធីនៃការឃាត់ខ្លួន ចាប់ខ្លួន ឃុំខ្លួន និងសួរចម្លើយដើម្បីសរសេរកំណត់ហេតុជាដើម។

២. ស្ថាប័នអយ្យការត្រូវធ្វើសេចក្តីថ្លែងការណ៍ឱ្យបានច្បាស់លាស់ ជៀសវាងភាពស្រពិចស្រពិល ដើម្បីធ្វើសេចក្តីថ្លែងការណ៍ដែលទាក់ទងនឹងភាពមាន ឬគ្មានពិរុទ្ធរបស់ជនជាប់ចោទណាមួយមុនពេលដែលតុលាការជំនុំជម្រះ។

៣. ស្ថាប័នតុលាការដែលកាត់ក្តីដោយចៅក្រមត្រូវតែរក្សាឱ្យបាននូវយុត្តិធម៌ មិនលម្អៀង និងជៀសវាងការវិនិច្ឆ័យក្តីមុនមានសេចក្តីសម្រេចជាស្ថាពរ ពោលគឺចៅក្រមធ្វើការជំនុំជម្រះត្រូវធ្វើឡើងដោយមានភាពឯករាជ្យ។

៤. លើកស្ទួយវិស័យអប់រំនៅតាមសហគមន៍នីមួយៗ និងលើកទឹកចិត្តក្មេងៗជំនាន់ក្រោយឱ្យខំប្រឹងប្រែងសិក្សារៀនសូត្រ។

៥. ធ្វើការផ្សព្វផ្សាយច្បាប់ទៅដល់ប្រជាពលរដ្ឋឱ្យបានយល់ដឹងគ្រប់ៗគ្នា រួមទាំងការចូលរួមក្នុងកិច្ចការសង្គមផងដែរ ដើម្បីឱ្យប្រជាពលរដ្ឋបានយល់ដឹងពីច្បាប់ និងរួមគ្នាកសាងប្រទេសជាតិ។

ជាអវសាន យើងសង្ឃឹមយ៉ាងមុតមាំថា ទៅថ្ងៃអនាគតនៅពេលដែលប្រជាជនមានការយល់ដឹងច្រើននឹងកាត់បន្ថយនូវការកើតមានបទល្មើស ហើយប្រជាជនគ្រប់គ្នាបែរងាកមករកការកសាងប្រទេសដោយចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការកសាងប្រទេសជាតិដើម្បីយើងទាំងអស់គ្នាបានរស់នៅក្នុងសង្គមមួយដែលមានច្បាប់គ្រប់គ្រងល្អជាគំរូដល់ប្រទេសជិតខាង ធ្វើការពង្រឹងផ្នែកវិស័យអប់រំ និងធនធានមនុស្សដើម្បីការអភិវឌ្ឍន៍ប្រកបដោយចីរភាព៕

# ឯកសារយោង

## ❖ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០២០៨/០០៨ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០០៨។
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០០៩។
- ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧។
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ៨ ខែធ្នូ ឆ្នាំ ២០០៧។
- ច្បាប់ស្តីពី យុត្តិធម៌អនីតិជន ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ២០១១។
- ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ១៩៩៥។
- កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ១៩៦៦។
- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ៨ មីនា ១៩៩៣។
- ច្បាប់ព្រហ្មទណ្ឌអន្តរកាល, ១០ កញ្ញា ១៩៩២។

## ❖ឯកសារដែលចងក្រងជាសៀវភៅ និងអត្ថបទផ្សេងៗ

- សៀវភៅសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត, នីតិព្រហ្មទណ្ឌទូទៅ បោះពុម្ពឆ្នាំ ២០២២។
- សៀវភៅសាស្ត្រាចារ្យ កៅ សីហា, នីតិព្រហ្មទណ្ឌទូទៅខ្មែរ បោះពុម្ពឆ្នាំ ២០១៣។
- សៀវភៅសាស្ត្រាចារ្យ ជួន ប៊ុនធី, នីតិព្រហ្មទណ្ឌពិសេស ឆ្នាំ២០២១។
- សៀវភៅសាស្ត្រាចារ្យ សែ វ៉េង, នីតិព្រហ្មទណ្ឌទូទៅ បោះពុម្ពឆ្នាំ ២០១៣។
- វចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត។
- ប្រសាសន៍របស់ឯកឧត្តម កើត រិទ្ធ អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ ក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី "ក្រមព្រហ្មទណ្ឌ"ដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌សហការណ៍ជាមួយក្រសួងព័ត៌មានតាមរយៈទូរទស្សន៍ជាតិកម្ពុជា ឆ្នាំ២០១០។
- ប្រសាសន៍របស់ឯកឧត្តម ផូវ សំភី អគ្គនាយកនៃអគ្គនាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍លើវិស័យយុត្តិធម៌, អគ្គលេខាធិការរងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រីក្នុង កម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី "ក្រមព្រហ្មទណ្ឌ"ដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌សហការណ៍ជាមួយក្រសួងព័ត៌មានតាមរយៈទូរទស្សន៍ជាតិកម្ពុជា ឆ្នាំ២០១០។

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១៖ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

ឧបសម្ព័ន្ធទី២៖ ក្រមព្រហ្មទណ្ឌ

ឧបសម្ព័ន្ធទី៣៖ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

ឧបសម្ព័ន្ធទី៤៖ ច្បាប់ស្តីពី យុត្តិធម៌អនីតិជន

# ឧបសម្ព័ន្ធទី១

# រដ្ឋធម្មនុញ្ញ

# នៃ

# ព្រះរាជាណាចក្រកម្ពុជា

# បុព្វកថា

❖❖❖❖

## យើង ប្រជារាស្ត្រខ្មែរ

ដែលធ្លាប់មានអារ្យធម៌ឧត្តុង្គឧត្តម ប្រទេសជាតិស្តុកស្តម្ភ ធំទូលាយ ថ្កុំថ្កើងរុងរឿង កិត្យានុភាពខ្ពង់ខ្ពស់ ភ្លឺចែងចាំងដូចពេជ្រពណ្ណរាយ

បានធ្លាក់ខ្លួនដ៏សែនរន្ធត់ ក្នុងអំឡុងពីរទសវត្សរ៍ចុងក្រោយនេះ ឆ្លងកាត់ទុក្ខសោកវិនាសអន្តរាយ ទ្រុឌទ្រោម ឱនថយមហាសោកស្តាយ

បានភ្ញាក់រលឹក ក្រោកឈរឡើង ចងបាច់ឆន្ទៈមោះមុត ប្តូរផ្តាច់ រួបរួមគ្នា ពង្រឹងឯកភាពជាតិ រក្សាការពារទឹកដីកម្ពុជា អធិបតេយ្យ ថ្លៃថ្លា និងអារ្យធម៌អង្គរដ៏បវរ កសាងប្រទេសជាតិឱ្យទៅជា“កោះសន្តិភាព” ឡើងវិញ ផ្អែកលើប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស ធានាសិទ្ធិមនុស្ស គោរពច្បាប់ ទទួលខុសត្រូវខ្ពស់ ចំពោះវាសនាអនាគតជាតិ ឱ្យបានឈានឡើង រីកចម្រើនល្អលាស់ សម្បូររុងរឿងជានិច្ចនិរន្តរ៍ ។

## ក្នុងឆន្ទៈមោះមុតនេះ

យើងសរសេរចារឹកក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដូចតទៅ :

តំណាងរាស្ត្រមានសិទ្ធិស្នើធ្វើវិសោធនកម្មច្បាប់ ប៉ុន្តែសំណើនេះមិនអាចទទួលយកបានទេ បើវិសោធនកម្មនោះសំដៅបន្ថយប្រាក់ចំណូលសាធារណៈ ឬបន្ថែមបន្ទុកលើប្រជាពលរដ្ឋ ។

**មាត្រា ៩២.-**

ការអនុម័តទាំងឡាយរបស់រដ្ឋសភា ដែលផ្ទុយនឹងគោលការណ៍ រក្សាការពារ ឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ហើយដែលនាំឱ្យប៉ះពាល់ដល់ឯកភាពនយោបាយ ឬការគ្រប់គ្រងរដ្ឋបាលរបស់ប្រទេសជាតិនឹងត្រូវចាត់ទុកជាអាសារវូន្យ។ ក្រុមប្រឹក្សាធម្មនុញ្ញជាអង្គការតែមួយគត់ដែលមានសមត្ថកិច្ចសម្រេចពីមោឃភាពនេះ ។

**មាត្រា ៩៣.- ថ្មី**

ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ ហើយត្រូវបានព្រះមហាក្សត្រទ្រង់ឡាយព្រះហស្ថលេខាប្រកាសឱ្យប្រើ ត្រូវចូលជាធរមាន នៅរាជធានីភ្នំពេញក្នុងរយៈពេលដប់ថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសឱ្យប្រើ និងនៅទូទាំងប្រទេសក្នុងរយៈពេលម្ភៃថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសឱ្យប្រើ ។ ប៉ុន្តែបើច្បាប់នេះបានចែងថាជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេស ក្រោយថ្ងៃប្រកាសឱ្យប្រើ ។

ច្បាប់ដែលព្រះមហាក្សត្រទ្រង់បានឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ ត្រូវចុះក្នុងរាជកិច្ច និងផ្សព្វផ្សាយនៅទូទាំងប្រទេស ឱ្យទាន់តាមពេលកំណត់ខាងលើ ។

**មាត្រា ៩៤.-**

រដ្ឋសភាបង្កើតគណៈកម្មការផ្សេងៗ ដែលចាំបាច់។ ការរៀបចំ និងការប្រព្រឹត្តទៅនៃរដ្ឋសភា នឹងមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ។

**មាត្រា ៩៥.-**

ក្នុងករណីមានសមាជិករដ្ឋសភាទទួលអនិច្ចកម្ម លាលែង ឬប្រាសចាកសមាជិកភាព ដែលកើតមានឡើង៦ខែ យ៉ាងតិចមុនចប់នីតិកាល ត្រូវចាត់ការជ្រើសតាំងជំនួសសមាជិកនោះ តាមល័ក្ខខ័ណ្ឌកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងក្នុងច្បាប់បោះឆ្នោត ។

**មាត្រា ៩៦.-**

តំណាងរាស្ត្រ មានសិទ្ធិដាក់សំណួរដល់រាជរដ្ឋាភិបាល។ សំណួរនេះត្រូវសរសេរជាលាយលក្ខណ៍អក្សរ ប្រគល់ជូនតាមរយៈប្រធានរដ្ឋសភា ។

# ឧបសម្ព័ន្ធទី២

# ក្រម

# ព្រហ្មទណ្ឌ

# ព្រះរាជក្រម

នស/រកម/១១០៩/០២២

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៩ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៦ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

# គន្ថីទី ១
# បទប្បញ្ញត្តិទូទៅ
## មាតិកាទី ១
## ច្បាប់ព្រហ្មទណ្ឌ
### ជំពូកទី ១
### គោលការណ៍ទូទៅ

**មាត្រា ១.–** ដែនអនុវត្តនៃច្បាប់ព្រហ្មទណ្ឌ

ច្បាប់ព្រហ្មទណ្ឌកំណត់បទល្មើស ចង្អុលបង្ហាញបុគ្គលដែលអាចត្រូវបានប្រកាសថាជាអ្នកទទួលខុសត្រូវចំពោះបទល្មើស និងកំណត់ទោស ព្រមទាំងរបៀបនៃការអនុវត្តទោសនេះ ។

នៅក្នុងករណីចាំបាច់ បទដ្ឋានគតិយុត្តដែលចេញដោយអង្គការនីតិប្រតិបត្តិអាចចែងពីបទលហុដែលត្រូវផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់ប៉ុណ្ណោះ ។

**មាត្រា ២.–** និយមន័យ និងចំណាត់ថ្នាក់នៃបទល្មើស

ច្បាប់បញ្ញត្តថា អំពើខុសរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបង្កចលាចលដល់សង្គម ជាបទល្មើស ។ បទល្មើសត្រូវបានចាត់ថ្នាក់ជា បទឧក្រិដ្ឋ បទមជ្ឈិម និង បទលហុ នៅតាមទម្ងន់នៃបទល្មើសនោះ ។

**មាត្រា ៣.–** គោលការណ៍នីត្យានុកូលភាព

មានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន ។

មានតែទោសដែលមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចត្រូវប្រកាសបាន ។

**មាត្រា ៤.–** ចេតនាប្រព្រឹត្តបទល្មើស

គ្មានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត ។

ប៉ុន្តែក្នុងករណីដែលច្បាប់បានចែងទុកមុន បទល្មើសមួយអាចកើតចេញពីការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬ ការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ ។



Kol

**មាត្រា ៥.-** ការបកស្រាយច្បាប់ព្រហ្មទណ្ឌ

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់ត្រូវបកស្រាយយ៉ាងតឹងរ៉ឹង ។ ចៅក្រមមិនអាចពង្រីកវិសាលភាពអនុវត្ត ឬ ប្រព្រឹត្តតាមសទិសភាពបានឡើយ ។

**មាត្រា ៦.-** ការប្រកាសទោស

គ្មានទោសណាមួយដែលអាចត្រូវយកមកអនុវត្តបានឡើយ ប្រសិនបើទោសនោះមិនត្រូវបានប្រកាសដោយតុលាការទេ ។

**មាត្រា ៧.-** លក្ខខណ្ឌនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ដែនអនុវត្តច្បាប់កម្ពុជាក្នុងលំហ ត្រូវបានកំណត់ដោយបទប្បញ្ញត្តិនៃក្រមនេះ លើកលែងតែមានសន្ធិសញ្ញាអន្តរជាតិ ។

**មាត្រា ៨.-** *អវត្តមាននៃនិទណ្ឌភាពក្នុងបទល្មើសធ្ងន់ធ្ងរខាងនីតិមនុស្សធម៌អន្តរជាតិ*

បទប្បញ្ញត្តិនៃក្រមនេះ ពុំអាចនាំឱ្យមានការបង្កើតនូវស្ថានភាពយុត្តិនិសេធ ចំពោះជនរងគ្រោះនៃបទល្មើសធ្ងន់ធ្ងរ ដែលកំណត់ដោយច្បាប់ដោយឡែកទាក់ទងដល់ការរំលោភនីតិមនុស្សធម៌អន្តរជាតិ ទំនៀមទម្លាប់អន្តរជាតិ ឬ អនុសញ្ញាអន្តរជាតិ ដែលទទួលស្គាល់ដោយព្រះរាជាណាចក្រកម្ពុជាឡើយ ។

## ជំពូកទី ២

## ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងពេលវេលា

**មាត្រា ៩.-** ការអនុវត្តច្បាប់ដែលលុបចោលបទល្មើស

បទប្បញ្ញត្តិថ្មីដែលលុបចោលបទល្មើសណាមួយនោះត្រូវអនុវត្តភ្លាម ។ អំពើដែលប្រព្រឹត្តនៅមុនបទប្បញ្ញត្តិនេះចូលជាធរមាន មិនអាចត្រូវចោទប្រកាន់ទៀតឡើយ ។ ការចោទប្រកាន់ដែលកំពុងប្រព្រឹត្តទៅនោះ ត្រូវបញ្ចប់ ។

ប្រសិនបើការផ្តន្ទាទោសជាស្ថាពរត្រូវបានប្រកាសរួចមកហើយ ទោសដែលចេញអំពីការផ្តន្ទាទោសនេះ មិនត្រូវអនុវត្តទេ ឬ ត្រូវតែឈប់អនុវត្ត ។

**មាត្រា ១០.-** ការអនុវត្តច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង ឬ ធ្ងន់ជាង

បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសដែលស្រាលជាងត្រូវអនុវត្តភ្លាម ។ ប៉ុន្តែការផ្តន្ទា-

ទោសដែលជាស្ថាពរហើយនោះ ត្រូវអនុវត្ត ទោះបីទោសដែលប្រកាសនោះធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ។

បទបញ្ញត្តិថ្មីដែលចែងអំពីទោសធ្ងន់ជាង នឹងត្រូវអនុវត្តតែទៅលើអំពើដែលបានប្រព្រឹត្តក្រោយការចូលជាធរមាននៃបទបញ្ញត្តិនោះ ។

**មាត្រា ១១.-** សុពលភាពនៃកិច្ចនីតិវិធី

ការអនុវត្តភ្លាមនៃបទបញ្ញត្តិថ្មី គ្មានអានុភាពទៅលើសុពលភាពនៃកិច្ចនីតិវិធី ដែលបានបំពេញស្របតាមបទបញ្ញត្តិចាស់ឡើយ ។

## ជំពូកទី ៣

## ការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជានៅក្នុងលំហ

### ផ្នែកទី ១

### បទល្មើសដែលបានប្រព្រឹត្ត ឬ ចាត់ទុកថាបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា

**មាត្រា ១២.-** គោលការណ៍ដែនដីនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសទាំងឡាយដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

ដែនដីនៃព្រះរាជាណាចក្រកម្ពុជា រួមបញ្ចូលទាំងលំហអាកាស និងសមុទ្រ ដែលមានចំណងចងភ្ជាប់នឹងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១៣.-** ទីកន្លែងប្រព្រឹត្តបទល្មើស

បទល្មើសត្រូវបានចាត់ថាប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជានៅពេលដែលអំពើណាមួយនៃបទល្មើសនោះ បានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១៤.-** បទល្មើសដែលបានប្រព្រឹត្តនៅក្នុងនាវាកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្នុងនាវាដែលមានសញ្ជាតិខ្មែរ ទោះបីជានាវានោះស្ថិតនៅទីណាក៏ដោយ ។

ROYAUME DU CAMBODGE MINISTERE du PALAIS ROYAL

**មាត្រា ១៥.-** បទល្មើសដែលបានប្រព្រឹត្តនៅក្នុងនាវាបរទេស

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្នុងនាវាបរទេសដែលអាជ្ញាធរកម្ពុជាបានទទួលការអនុញ្ញាតឱ្យពិនិត្យមើល ឬ ឱ្យចាប់នាវាតាមអំណាចនៃកិច្ចព្រមព្រៀងអន្តរជាតិ ។

**មាត្រា ១៦.-** បទល្មើសដែលបានប្រព្រឹត្តនៅក្នុងអាកាសយានកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្នុងអាកាសយានដែលចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ទោះបីជាអាកាសយាននោះស្ថិតនៅទីណាក៏ដោយ ។

**មាត្រា ១៧.-** ការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជាចំពោះអំពើដែលបានចាប់ផ្ដើមប្រព្រឹត្តនៅកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបុគ្គលគ្រប់រូបដែលជាអ្នកផ្ដើមគំនិត ឬ អ្នកសមគំនិតនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងបទឧក្រិដ្ឋ ឬ បទមជ្ឈិម ដែលប្រព្រឹត្តនៅឯបរទេស ប្រសិនបើលក្ខខណ្ឌទាំងពីរដូចខាងក្រោមនេះ ត្រូវបានបំពេញ ៖

-បទល្មើសត្រូវផ្ដន្ទាទោសតាមច្បាប់កម្ពុជា និងតាមច្បាប់បរទេសផង និង

-អត្ថិភាពនៃបទល្មើស ត្រូវបានបញ្ជាក់ដោយសេចក្ដីសម្រេចជាស្ថាពររបស់តុលាការបរទេស ។

**មាត្រា ១៨.-** ការកំណត់បទល្មើសប្រព្រឹត្តដោយនីតិបុគ្គល

ការដាក់ឈ្មោះបទល្មើសដែលប្រព្រឹត្តដោយនីតិបុគ្គលថាជា បទឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុ ត្រូវកំណត់ដោយទណ្ឌកម្មដែលទទួលរងដោយរូបវន្តបុគ្គល ។

## ផ្នែកទី ២

## បទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា

**មាត្រា ១៩.-** បទឧក្រិដ្ឋ ឬ បទមជ្ឈិមប្រព្រឹត្តដោយពលរដ្ឋខ្មែរ

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើគ្រប់បទឧក្រិដ្ឋដែលប្រព្រឹត្តដោយពលរដ្ឋខ្មែរនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទមជ្ឈិមដែលប្រព្រឹត្តដោយពលរដ្ឋខ្មែរ នៅក្នុងប្រទេសក្រៅណាមួយ ប្រសិនបើអំពើនោះត្រូវបានផ្តន្ទាទោសតាមច្បាប់នៃប្រទេសនោះផងដែរ ។

បទប្បញ្ញត្តិទាំងនេះត្រូវអនុវត្តផងដែរ ទោះបីជាជនជាប់ចោទបានទទួលសញ្ជាតិខ្មែរក្រោយអំពើដែលចោទប្រកាន់នេះក៏ដោយ ។

**មាត្រា ២០.-** ជនរងគ្រោះជាជនជាតិខ្មែរ

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវបានអនុវត្តទៅលើគ្រប់បទឧក្រិដ្ឋដែលប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជាដោយពលរដ្ឋខ្មែរ ឬ ដោយជនបរទេសទៅលើជនរងគ្រោះដែលមានសញ្ជាតិខ្មែរ នៅក្នុងពេលដែលបទល្មើសត្រូវបានប្រព្រឹត្ត ។

**មាត្រា ២១.-** ការធ្វើបណ្តឹងចោទប្រកាន់

នៅក្នុងករណីដែលមានចែងនៅក្នុងមាត្រា ១៩(បទឧក្រិដ្ឋ ឬ បទមជ្ឈិមប្រព្រឹត្តដោយពលរដ្ឋខ្មែរ) និងមាត្រា ២០(ជនរងគ្រោះជាជនជាតិខ្មែរ) នៃក្រមនេះ ការចោទប្រកាន់អាចប្រព្រឹត្តទៅបានតាមបណ្តឹងរបស់អយ្យការតែប៉ុណ្ណោះ ។ ការចោទប្រកាន់ត្រូវតែមានបណ្តឹងពីជនរងគ្រោះ ឬ ពីសិទ្ធិវន្ត ឬ បណ្តឹងបរិហារជាផ្លូវការរបស់អាជ្ញាធរនៃប្រទេសដែលជាទីកន្លែងដែលអំពើនោះបានប្រព្រឹត្ត ។

**មាត្រា ២២.-** សមត្ថកិច្ចដោយឡែកចំពោះបទឧក្រិដ្ឋដោយឡែក

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើស ដែលប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ហើយបើបទល្មើសនោះជា :

១-បទល្មើសប្រឆាំងនឹងសុវត្ថិភាពនៃព្រះរាជាណាចក្រកម្ពុជា ។

២-បទល្មើសក្លែងត្រាផ្លូវការនៃព្រះរាជាណាចក្រកម្ពុជា ។

៣-បទល្មើសក្លែងរូបិយវត្ថុ និងធនបត្រជាតិ ដែលមានតម្លៃស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ។

៤-បទល្មើសប្រឆាំងនឹងភ្នាក់ងារទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ។

៥-បទល្មើសប្រឆាំងនឹងទីតាំងទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៣.-** ការមិនចោទប្រកាន់ត្រួតគ្នា និងទោស

ពុំមានការចោទប្រកាន់ណាមួយអាចប្រព្រឹត្តប្រឆាំងនឹងបុគ្គលណាម្នាក់ ដែលត្រូវបានជំនុំជម្រះជាស្ថាពរនៅឯបរទេសចំពោះអំពើល្មើសដដែល ហើយក្នុងករណីដែលមានការផ្តន្ទាទោស បុគ្គលនោះបានបង្ហាញថាខ្លួនបានអនុវត្តទោសរបស់ខ្លួនរួចហើយ ឬ ក៏ទោសត្រូវបានរលត់ដោយការផុតអាជ្ញាយុកាល ។

## មាតិកាទី ២

## ការទទួលខុសត្រូវព្រហ្មទណ្ឌ

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ២៤.-** គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

បុគ្គលម្នាក់ៗ ទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ ។

**មាត្រា ២៥.-** និយមន័យនៃចារី

ត្រូវចាត់ទុកជាចារី ចំពោះបុគ្គលណាដែលប្រព្រឹត្តបទល្មើសដែលត្រូវចោទប្រកាន់។

ត្រូវចាត់ទុកជាចារីផងដែរ ចំពោះបុគ្គលណាដែលប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬ ក្នុងករណីដែលច្បាប់បានចែងទុក ចំពោះបទមជ្ឈិម ។

**មាត្រា ២៦.-** និយមន័យនៃសហចារី

ត្រូវចាត់ទុកជាសហចារី កាលណាមានបុគ្គលច្រើននាក់ បានព្រមព្រៀង ប្រព្រឹត្តបទ-ល្មើសរួមគ្នាដោយផ្ទាល់ ។

ត្រូវចាត់ទុកជាសហចារីផងដែរ កាលណាមានបុគ្គលច្រើននាក់បានព្រមព្រៀងប៉ុន-ប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទមជ្ឈិមដោយផ្ទាល់ក្នុងករណីដែលច្បាប់បានចែងទុក ។

**មាត្រា ២៧.-** និយមន័យនៃការប៉ុនប៉ង

ការប៉ុនប៉ងក្នុងបទឧក្រិដ្ឋ ឬ ក្នុងករណីដែលច្បាប់បានចែងទុកក្នុងបទមជ្ឈិម អាចត្រូវផ្តន្ទាទោសបាន កាលណាលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញ :

- ចារីបានចាប់ផ្តើមអនុវត្តបទល្មើស មានន័យថា ចារីបានប្រព្រឹត្តអំពើដែល

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *



9/26 Kol

មានគោលបំណងដោយផ្ទាល់ដើម្បីប្រព្រឹត្តបទល្មើស និង

-ចារីមិនបានបញ្ឈប់អំពើរបស់ខ្លួនទៅវិញដោយស្ម័គ្រចិត្ត តែត្រូវបានរាំងស្ទះ ឬ អាក់ខាន ដោយឥទ្ធិពលនៃកាលៈទេសៈក្រៅឆន្ទៈរបស់ខ្លួន ។

អំពើត្រៀមបម្រុងដែលពុំមានគោលបំណងដោយផ្ទាល់ ដើម្បីប្រព្រឹត្តបទល្មើស មិនមែនជាការចាប់ផ្តើមអនុវត្តទេ ។

ការប៉ុនប៉ងក្នុងបទលហុ ពុំទទួលការផ្តន្ទាទោសទេ ។

**មាត្រា ២៨.- និយមន័យនៃអ្នកផ្តើមគំនិត**

ត្រូវចាត់ទុកជាអ្នកផ្តើមគំនិតក្នុងបទឧក្រិដ្ឋ ឬ បទមជ្ឈិម ចំពោះបុគ្គលណាដែល :

១-ជំរុញឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទមជ្ឈិមនោះ តាមការណែនាំ ឬ ការបញ្ជា ។

២-បង្កឱ្យមានបទឧក្រិដ្ឋ ឬ បទមជ្ឈិមនោះ ដោយផ្តល់អំណោយ ដោយការសន្យា ឬ ការគំរាមកំហែង ការញុះញង់ ការលួងលោម ឬ ក៏ដោយការរំលោភអាជ្ញា ឬ អំណាចរបស់ខ្លួន ។

អ្នកផ្តើមគំនិតនឹងអាចត្រូវផ្តន្ទាទោសបានលុះត្រាតែបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវបានសម្រេច ឬបានប៉ុនប៉ង ។

អ្នកផ្តើមគំនិតនៃបទឧក្រិដ្ឋ ឬ បទមជ្ឈិម ត្រូវផ្តន្ទាទោសដូចគ្នានឹងចារីដែរ ។

**មាត្រា ២៩.- និយមន័យនៃអ្នកសមគំនិត**

ត្រូវចាត់ទុកជាអ្នកសមគំនិតក្នុងបទឧក្រិដ្ឋ ឬ បទមជ្ឈិម ចំពោះបុគ្គលណាដែលជួយសម្រួលដោយចេតនា ដល់ការប៉ុនប៉ង ឬ ការសម្រេចបទឧក្រិដ្ឋ ឬ បទមជ្ឈិមនោះ ដោយផ្តល់ជំនួយ ឬ ការឧបត្ថម្ភរបស់ខ្លួន ។

អ្នកសមគំនិតនឹងអាចត្រូវផ្តន្ទាទោសបានលុះត្រាតែបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវបានសម្រេច ឬបានប៉ុនប៉ង ។

អ្នកសមគំនិតនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវផ្តន្ទាទោសដូចគ្នានឹងចារីដែរ ។

**មាត្រា ៣០.- និយមន័យនៃអ្នករាជការសាធារណៈ ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត**

១-អ្នករាជការសាធារណៈ មានន័យថា :

ក/ បុគ្គលដែលបម្រើការងារនៅក្នុងស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ឬ

ស្ថាប័នតុលាការដែលត្រូវបានតែងតាំងដោយលិខិតបទដ្ឋានគតិយុត្ត ទោះជាអចិន្ត្រៃយ៍ ឬ ជាបណ្តោះអាសន្នក្តី ទោះជាបានទទួល ឬ មិនបានប្រាក់ឈ្នួលក្តី ដោយមិនគិតពីឋានៈ អាយុ របស់បុគ្គលនោះឡើយ ។

ខ/ បុគ្គលឯទៀត ដែលធ្វើការក្នុងមុខងារសាធារណៈ រួមទាំងទីភ្នាក់ងារសាធារណៈ ឬសហគ្រាសសាធារណៈ ព្រមទាំងស្ថាប័នសាធារណៈដទៃទៀត ដែលមានចែងនៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

២-ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត មានន័យថាជាសមាជិកព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងពលរដ្ឋដែលទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដើម្បីបំពេញមុខងារសាធារណៈដទៃទៀត ។

## ជំពូកទី ២

## មូលហេតុនៃការមិនទទួលខុសត្រូវ ឬ ការសម្រាលនូវការទទួលខុសត្រូវព្រហ្មទណ្ឌ

**មាត្រា ៣១.–** ការមិនទទួលខុសត្រូវដោយសារមូលហេតុវិបល្លាសស្មារតី

កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដែលធ្វើឱ្យ បាត់បង់នូវការដឹងខុសត្រូវរបស់ខ្លួន ជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដែលបន្ថយនូវការដឹងខុសត្រូវរបស់ខ្លួន ជននោះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល ។ ប៉ុន្តែ តុលាការត្រូវគិតគូរអំពីបញ្ហានេះ កាលណាតុលាការកំណត់ទោស ។

កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដោយសារការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬ សារជាតិដែលច្បាប់ហាមឃាត់ មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ។

**មាត្រា ៣២.–** ការអនុញ្ញាតដោយច្បាប់ ឬ អាជ្ញាធរ

ជនណាដែលប្រព្រឹត្តអំពើដែលបានបញ្ញត្ត ឬ អនុញ្ញាតតាមច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ ។

បុគ្គលណាដែលប្រព្រឹត្តអំពើតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ លើកលែងតែអំពើនេះជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់ ។

ប៉ុន្តែ ចារី សហចារី អ្នកផ្ដើមគំនិត ឬ អ្នកសមគំនិតក្នុងបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ឬ បទឧក្រិដ្ឋសង្គ្រាម មិនអាចលើកលែងឱ្យផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ខ្លួនទេ ទោះបីជាក្នុងករណីមានមូលហេតុដូចខាងក្រោមក៏ដោយ :

១-ជនល្មើសនោះបានប្រព្រឹត្តអំពើដែលបញ្ញត្ត អនុញ្ញាត ឬ មិនហាមឃាត់ដោយច្បាប់ជាធរមាន ។

២-បុគ្គលនោះបានប្រព្រឹត្តតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ ។

**មាត្រា ៣៣.-** ការការពារស្របច្បាប់

បុគ្គលណាដែលប្រព្រឹត្តបទល្មើសក្នុងសភាពការពារស្របច្បាប់ មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

ការការពារស្របច្បាប់ ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ :

-បទល្មើសត្រូវបានចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬ ការពារទ្រព្យសម្បត្តិប្រឈមមុខនឹងការឈ្លានពានមួយដែលមិនត្រឹមត្រូវ

-បទល្មើស និងការឈ្លានពាន ត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា និង

-គ្មានវិសមាមាត្រ រវាងមធ្យោបាយការពារដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន ។

**មាត្រា ៣៤.-** សច្ចធារណ៍នៃការការពារស្របច្បាប់

ត្រូវសន្មតថាជាការការពារស្របច្បាប់ នៅក្នុងករណីដូចតទៅ :

១-បទល្មើសត្រូវបានប្រព្រឹត្ត ដើម្បីរុញច្រានការចូលក្នុងពេលយប់ ដោយការកាប់គាស់ទម្លុះទម្លាយ ដោយហិង្សា ឬ ដោយកលល្បិចនៅក្នុងទីកន្លែងដែលមានមនុស្សនៅ ។

២-បទល្មើសបានប្រព្រឹត្ត ដើម្បីការពារខ្លួនប្រឆាំងនឹងការលួច ឬ ការប្លន់ដែលអនុវត្តដោយហិង្សា ។

សច្ចធារណ៍នៃការការពារស្របច្បាប់ ពុំមានលក្ខណៈដាច់ខាតទេ ។ សច្ចធារណ៍ នេះ ត្រូវរំលាយដោយភស្តុតាងផ្ទុយ ។

**មាត្រា ៣៥.-** ស្ថានភាពចាំបាច់

បុគ្គលដែលស្ថិតនៅក្នុងការចាំបាច់ត្រូវតែប្រព្រឹត្តបទល្មើស មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

ស្ថានភាពចាំបាច់ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ :

-បទល្មើសត្រូវបានចាត់ទុកថា ត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬ ការពារទ្រព្យសម្បត្តិ ប្រឆាំងនឹងគ្រោះថ្នាក់ដែលកំពុងកើតមាន ឬ ដែលនឹងកើតមាន និង

-គ្មានវិសមាមាត្ររវាងមធ្យោបាយការពារនិងទម្ងន់នៃគ្រោះថ្នាក់ ។

**មាត្រា ៣៦.-** អានុភាពនៃកម្លាំង ឬ ការបង្ខំ

បុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬ ការបង្ខំ ដែលបុគ្គលនេះមិនអាចទប់ទល់បាន បុគ្គលនេះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

កម្លាំង និងការបង្ខំ អាចចេញមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់មនុស្សតែប៉ុណ្ណោះ ។ កម្លាំង និងការបង្ខំនេះត្រូវតែមិនអាចមើលឃើញជាមុនបាន និងមិនអាចជៀសវាងបាន ។

**មាត្រា ៣៧.-** ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

បុគ្គលដែលមិនទទួលខុសត្រូវព្រហ្មទណ្ឌ មិនត្រូវទទួលទណ្ឌកម្មព្រហ្មទណ្ឌណាមួយទេ ។

## ជំពូកទី ៣
## ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន

**មាត្រា ៣៨.-** នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ ។

**មាត្រា ៣៩.-** វិធានការអនុវត្តចំពោះអនីតិជន

អនីតិជនដែលប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ ។

ប៉ុន្តែ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈ របស់អនីតិជនតម្រូវ ។

**មាត្រា ៤០.-** ប្រភេទនៃវិធានការ

វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភមាន ដូចតទៅ :

១-ការប្រគល់អនីតិជនឱ្យទៅឪពុកម្ដាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬ បុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្ដិសមនឹងទំនុកចិត្ត ។

២-ការប្រគល់អនីតិជនឱ្យទៅសេវាសាធារណៈ ដែលសម្រាប់ទទួលបន្ទុកអនីតិជន ។

៣-ការប្រគល់អនីតិជនឱ្យទៅអង្គការឯកជន ដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន ។

៤-ការប្រគល់អនីតិជនឱ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស ។

៥-ការដាក់អនីតិជនឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ ។

**មាត្រា ៤១.-** ការដាក់ឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ

ក្នុងករណីដាក់ឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការនោះ តុលាការចាត់តាំងបុគ្គលមួយរូបដែលទទួលភារៈធ្វើការតាមដានអនីតិជន ។ បុគ្គលនេះធ្វើរបាយការណ៍ស្ដីពីកិរិយាមារយាទរបស់អនីតិជនឱ្យបានទៀងទាត់ដល់ព្រះរាជអាជ្ញា។ បុគ្គលនេះផ្ដល់ព័ត៌មានដល់ព្រះរាជអាជ្ញាអំពីព្រឹត្តិការណ៍ទាំងអស់ ដែលអាចនាំឱ្យមានការកែប្រែនូវវិធានការនេះ ។

## ជំពូកទី ៤

## ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

**មាត្រា ៤២.-** ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នៅក្នុងករណីដែលមានចែងជាក់លាក់ក្នុងច្បាប់ និងបទដ្ឋានគតិយុត្តផ្សេងទៀត នីតិបុគ្គលដទៃក្រៅពីរដ្ឋ អាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពីបទ-



Ksl

**មាត្រា ៥១.-** ការគិតបញ្ចូលថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន

ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ត្រូវគិតបញ្ចូលទាំងស្រុងទៅក្នុងថិរវេលានៃទោសដាក់ពន្ធនាគារដែលត្រូវទទួល ។

**មាត្រា ៥២.-** ផលនៃទោសពិន័យ

ប្រាក់ពិន័យដែលទទួលបាន ត្រូវបង់ចូលថវិការដ្ឋ ។

## ផ្នែកទី ២

## ទោសបន្ថែម

**មាត្រា ៥៣.-** ប្រភេទនៃទោសបន្ថែម

ទោសបន្ថែមរួមមាន :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈណា ដែលបទល្មើសនោះបានប្រព្រឹត្តនៅក្នុងពេលដែលប្រកបវិជ្ជាជីវៈនេះ ។

៣-ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ ។

៤-ការល្បរលិខិតបើកបរ ។

៥-ការហាមឃាត់ចំពោះការស្នាក់នៅ ។

៦-ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

៧-ការហាមឃាត់ចំពោះការចូល និងការស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះទណ្ឌិតដែលជាជនបរទេស ។

៨-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដែលប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើស ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស ។

៩-ការរឹបអូសវត្ថុ ឬ មូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស ។

១០-ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិ ដែលជាផលកើតចេញពីបទល្មើស ។

១១-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬ ចលនវត្ថុ ដែលលំអទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត ។

១២-ការរឹបអូសយានជំនិះដែលជារបស់ទណ្ឌិត ។

# ជំពូកទី ៥

# មូលហេតុនានាដែលមានផលប៉ះពាល់ដល់ការអនុវត្តទោស

## ផ្នែកទី ១

## អាជ្ញាយុកាលនៃទោស

**មាត្រា ១៤២.-** អានុភាពនៃអាជ្ញាយុកាល

នៅពេលផុតអាជ្ញាយុកាលហើយ ទោសលែងអនុវត្តបានទៀតហើយ ។

**មាត្រា ១៤៣.-** ភាពមិនអាចផុតរលត់អាជ្ញាយុកាលនៃទោសចំពោះបទឧក្រិដ្ឋមួយចំនួន

ទោសដែលប្រកាសពីបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម មិនអាចផុតរលត់អាជ្ញាយុកាលទេ ។

ក្រៅពីបទល្មើសខាងលើ ច្បាប់ពិសេសអាចកំណត់អំពីភាពមិនអាចផុតរលត់អាជ្ញា-យុកាលនៃទោសចំពោះបទឧក្រិដ្ឋផ្សេងទៀតបាន ។

**មាត្រា ១៤៤.-** អាជ្ញាយុកាលនៃទោស

ទោសដែលប្រកាសពីបទឧក្រិដ្ឋមានអាជ្ញាយុកាល ២០ (ម្ភៃ) ឆ្នាំ ។

ទោសដែលប្រកាសពីបទមជ្ឈិមមានអាជ្ញាយុកាល ៥ (ប្រាំ) ឆ្នាំ ។

ទោសដែលប្រកាសពីបទលហុមានអាជ្ញាយុកាល ១ (មួយ) ឆ្នាំ ។

**មាត្រា ១៤៥.-** ចំណុចចាប់ផ្តើមនៃថិរវេលា

ថិរវេលា ២០ (ម្ភៃ) ឆ្នាំ ៥ (ប្រាំ) ឆ្នាំ និង ១ (មួយ) ឆ្នាំ ខាងលើ ដែលមានចែងនៅក្នុងមាត្រា ១៤៤ (អាជ្ញាយុកាលនៃទោស) នៃក្រមនេះ ចាប់គិតពីថ្ងៃដែលសេចក្តីសម្រេចផ្តន្ទាទោស បានក្លាយទៅជាស្ថាពរ ។

**មាត្រា ១៤៦.-** អាជ្ញាយុកាលនៃកាតព្វកិច្ចរដ្ឋប្បវេណីដែលកើតចេញពីសេចក្តីសម្រេចព្រហ្មទណ្ឌ

កាតព្វកិច្ចដែលមានប្រភេទជារដ្ឋប្បវេណី និងដែលមានប្រភពចេញមកពីសេចក្តីសម្រេចព្រហ្មទណ្ឌដែលក្លាយជាស្ថាពរ ផុតអាជ្ញាយុកាលតាមវិធាននៃក្រមរដ្ឋប្បវេណី ។

(បទឃាតកម្មដោយមានទារុណកម្ម អំពើឃោរឃៅ ឬ អំពើវិលោភសេពសន្ថវៈ) នៃក្រមនេះ គឺជាឃាតកម្ម ។

ឃាតកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ ។

**មាត្រា ២០០.-** បទឃាតកម្មគិតទុកជាមុន

ឃាតកម្មគិតទុកជាមុន គឺអំពើសម្លាប់មនុស្សដោយគិតទុកជាមុន ឬ ដោយការលួចស្ទាក់ ។

ការគិតទុកជាមុន គឺជាគម្រោងដែលបង្កើតឡើងមុនអំពើប្រៀតប្រៀនទៅលើរូបបុគ្គលនៃជនរងគ្រោះ ។

ការលួចស្ទាក់ គឺជាអំពើឃ្លាំចាំបុគ្គលណាម្នាក់ ក្នុងរយៈពេលមួយរយៈ ដើម្បីប្រព្រឹត្តអំពើប្រៀតប្រៀនទៅលើរូបបុគ្គលនៃជនរងគ្រោះ ។

ឃាតកម្មគិតទុកជាមុន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ។

**មាត្រា ២០១.-** បទឃាតកម្មដោយការប្រើថ្នាំពុល

ឃាតកម្មដែលប្រព្រឹត្តដោយការប្រើថ្នាំពុល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ។

**មាត្រា ២០២.-** បទឃាតកម្មដែលមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ

ឃាតកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ កាលបើអំពើនេះត្រូវបានប្រព្រឹត្តទៅលើ :

១-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ ។

២-នារីមានគភ៌ កាលបើគភ៌ត្រូវបានគេឃើញជាក់ស្តែង ឬ កាលបើជនល្មើសបានដឹង ។

៣-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃជំងឺ ឬ ពិការភាព កាលបើស្ថានភាពបុគ្គលនេះត្រូវបានគេឃើញជាក់ស្តែង ឬ កាលបើជនល្មើសបានដឹង ។

៤-អ្នករាជការសាធារណៈ នៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬ នៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ។

ROYAUME DU CAMBODGE MINISTRE DU PALAIS ROYAL

៣-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃជំងឺ ឬ ពិការភាព កាលបើស្ថានភាពបុគ្គលនេះត្រូវបានគេឃើញជាក់ស្តែង ឬ កាលបើជនល្មើសបានដឹង ។

**មាត្រា ២១២.-** ស្ថានទម្ងន់ទោសដោយសារគោលដៅ

បទឧក្រិដ្ឋដែលមានចែងនៅក្នុងមាត្រា ២១០(បទទារុណកម្ម និងអំពើឃោរឃៅ) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើអំពើនេះ ត្រូវបានប្រព្រឹត្តទៅលើ :

១-ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីរារាំងជននេះកុំឱ្យប្តឹងហើយហារពីបទល្មើស ឬ សុំឱ្យធ្វើការផ្សះផ្សាលុបលាងសមគកម្ម ។

២-សាក្សី ដើម្បីរារាំងកុំឱ្យឆ្លើយផ្តល់ភស្តុតាងនៅពេលស៊ើបអង្កេត ស៊ើបសួរ សវនាការ ឬ នៅក្នុងនីតិវិធីនៃបណ្តឹងផ្សេងទៀត ។

៣-ជនរងគ្រោះ ឬ ដើមបណ្តឹងរដ្ឋប្បវេណី ពីព្រោះជននេះបានបរិហារពីបទល្មើស ឬ សុំឱ្យផ្សះផ្សាលុបលាងសមគកម្ម ។

៤-សាក្សី ដោយមូលហេតុសាក្សីនេះបានផ្តល់ភស្តុតាងនៅពេលស៊ើបអង្កេត ស៊ើបសួរ សវនាការ ឬ នៅក្នុងនីតិវិធីនៃបណ្តឹងផ្សេងទៀត ។

**មាត្រា ២១៣.-** ស្ថានទម្ងន់ទោសទាក់ទងទៅនឹងចារី

បទឧក្រិដ្ឋដែលមានចែងនៅក្នុងមាត្រា ២១០(បទទារុណកម្ម និងអំពើឃោរឃៅ) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើបទឧក្រិដ្ឋនេះ ត្រូវបានប្រព្រឹត្តដោយអ្នករាជការសាធារណៈ នៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬ នៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ។

**មាត្រា ២១៤.-** ស្ថានទម្ងន់ទោសដោយសារការកាត់អវយវៈ ឬ ពិការភាព

បទឧក្រិដ្ឋដែលមានចែងនៅក្នុងមាត្រា ២១០(បទទារុណកម្ម និងអំពើឃោរឃៅ) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើបទឧក្រិដ្ឋនេះនាំឱ្យមានការកាត់អវយវៈ ឬឱ្យមានពិការភាពជាអចិន្ត្រៃយ៍ដល់ជនរងគ្រោះ ។

ROYAUME DU CAMBODGE MINISTRE DU PALAIS ROYAL

**មាត្រា ២២៤.-** ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ

អំពើហិង្សាដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើអំពើនេះបណ្តាលឱ្យជនរងគ្រោះស្លាប់ ដោយគ្មានចេតនាសម្លាប់ ។

**មាត្រា ២២៥.-** ការចាត់ទុកការប្រើសារធាតុពុលដូចជាអំពើហិង្សាដោយចេតនា

អំពើដែលឱ្យអ្នកដទៃផឹក លេប ឬបញ្ចូលទៅក្នុងខ្លួនអ្នកដទៃ តាមមធ្យោបាយណាក៏ដោយ ដោយចេតនានូវសារធាតុពុលដែលបណ្តាលឱ្យខូចសុខភាព ត្រូវចាត់ទុកជាអំពើហិង្សាដោយចេតនា ។

**មាត្រា ២២៦.-** ការចាត់ទុកការផ្តល់អាហារដែលមានសារធាតុពុល ដូចជាអំពើហិង្សាដោយចេតនា

អំពើលក់ ធ្វើអនុប្បទាន ឬ ឱ្យចំណី ឬ ភេសជ្ជៈ ដោយដឹងថាចំណី ឬ ភេសជ្ជៈនោះ មានសារធាតុពុលនាំឱ្យខូចសុខភាពនោះ ត្រូវចាត់ទុកជាអំពើហិង្សាដោយចេតនា ។

**មាត្រា ២២៧.-** ការចាត់ទុកការបញ្ចូលសារធាតុពុលក្នុងទឹកសម្រាប់បរិភោគដូចជាអំពើហិង្សាដោយចេតនា

អំពើប្រព្រឹត្តឡើងដោយចេតនា ដោយដាក់បញ្ចូលនូវសារធាតុពុលនាំឱ្យខូចសុខភាពទៅក្នុងទឹកសម្រាប់ហូបជាសាធារណៈ ត្រូវចាត់ទុកជាអំពើហិង្សាដោយចេតនា ។

**មាត្រា ២២៨.-** បទហិង្សាស្រាល

អំពើប្រព្រឹត្តទៅលើអ្នកដទៃនូវហិង្សាស្រាល ដែលមិននាំឱ្យមានរបួសទេនោះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០ (ប្រាំពាន់) រៀល ទៅ ១០០.០០០ (មួយសែន) រៀល ។

**មាត្រា ២២៩.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសត្រូវបានប្រព្រឹត្ត

២-ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រមនេះ ។

៣-ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយ ឬ ច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមនេះ ។

៤-ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៦ (ការបិទគ្រឹះស្ថាន) នៃក្រមនេះ ។

៥-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន ដែលបើកចំហដល់សាធារណជន ឬ ដែលប្រើប្រាស់ដោយសាធារណជន តាមបែបបទកំណត់ដោយមាត្រា ១៧៧ (ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន) នៃក្រមនេះ ។

៦-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមនេះ ។

៧-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬ ការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍) នៃក្រមនេះ ។

## ជំពូកទី ៣
## ការបំពានខាងផ្លូវភេទ
### ផ្នែកទី ១
### ការរំលោភសេពសន្ថវៈ

**មាត្រា ២៣៩.-** បទរំលោភសេពសន្ថវៈ

គ្រប់អំពើបញ្ចូលអង្គជាត តាមបែបណាក៏ដោយ ឬ អំពើបញ្ចូលឧបករណ៍ណាមួយទៅក្នុងអង្គជាត ដែលប្រព្រឹត្តទៅលើអ្នកដទៃ ទោះបីមានភេទដូចគ្នា ឬ មិនដូចគ្នាក៏ដោយ ដោយការប្រើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬ ដោយការឆ្លក់និកាស គឺជាបទរំលោភសេពសន្ថវៈ ។

បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់)

## ផ្នែកទី ២
## ការបំពានខាងផ្លូវភេទដទៃទៀត

**មាត្រា ២៤៦.–** បទប្រទូស្តកេរខ្មាស

គ្រប់អំពើប៉ះពាល់ ស្ទាប អង្អែលកេរភេទ ឬ ផ្នែកភេទផ្សេងទៀតរបស់បុគ្គលដទៃ តែបុគ្គលនេះមិនស្ម័គ្រចិត្តទេ ឬ បង្ខំបុគ្គលដទៃឱ្យប្រព្រឹត្តអំពើនេះមកលើខ្លួន ឬ ទៅលើតតិយបុគ្គលក្នុងគោលបំណងធ្វើឱ្យរំជួល ឬ រីករាយដល់ចំណង់ផ្លូវភេទរបស់ជនល្មើស គឺជាអំពើប្រទូស្តកេរខ្មាស ។

អំពើប្រទូស្តកេរខ្មាសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ២៤៧.–** ស្ថានទម្ងន់ទោសដោយសារមធ្យោបាយប្រើប្រាស់ ឬ ទាក់ទងនឹងចារី

បទល្មើសដែលមានចែងក្នុងមាត្រា ២៤៦ (បទប្រទូស្តកេរខ្មាស) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល កាលបើអំពើនេះ ប្រព្រឹត្តឡើង :

១-ដោយការប្រើអាវុធ ឬ ការគំរាមកំហែងនឹងអាវុធ ។

២-ដោយការប្រើគ្រឿងញៀន ឬ គ្រប់វិធីដែលនាំឱ្យជនរងគ្រោះបាត់បង់ ឬ ចុះខ្សោយលទ្ធភាពតទល់ ។

៣-ដោយបុគ្គលដែលមានអំណាចទៅលើជនរងគ្រោះ ។

៤-ដោយបុគ្គលដែលរំលោភអំណាច ដែលមុខងាររបស់ខ្លួនបានប្រគល់ឱ្យ ។

៥-ដោយបុគ្គលច្រើនរូប ដែលប្រព្រឹត្តឡើងក្នុងឋានៈជាចារី សហចារី អ្នកផ្តើមគំនិត ឬ ជាអ្នកសមគំនិត ។

**មាត្រា ២៤៨.–** ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ

បទល្មើសដែលមានចែងក្នុងមាត្រា ២៤៦ (បទប្រទូស្តកេរខ្មាស) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល កាលបើអំពើនេះប្រព្រឹត្តទៅលើ :

១-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ ។

២-នារីមានគភ៌ កាលបើគភ៌ត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង ។

៣-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃជំងឺ ឬ ពិការភាព កាលបើស្ថានភាពបុគ្គលនេះត្រូវបានគេឃើញជាក់ស្តែង ឬ កាលបើជនល្មើសបានដឹង ។

**មាត្រា ២៤៩.–** បទបង្ហាញកេរភេទ

អំពើបង្ហាញកេរភេទដែលនាំឱ្យអ្នកដទៃមើលឃើញ នៅក្នុងទីកន្លែងមួយដែលសាធារណជនអាចមើលឃើញ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ៣ (បី) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ៥០០.០០០ (ប្រាំសែន) រៀល ។

**មាត្រា ២៥០.–** បទរុកគួនខាងផ្លូវភេទ

អំពើរុកគួនខាងផ្លូវភេទ គឺជាអំពើដែលបុគ្គលម្នាក់រំលោភអំណាចដែលមុខងាររបស់ខ្លួនប្រគល់ឱ្យធ្វើការគាបសង្កត់ម្តងហើយម្តងទៀតទៅលើអ្នកដទៃ ក្នុងគោលបំណងទទួលការអនុគ្រោះខាងផ្លូវភេទ ។

អំពើរុកគួនខាងផ្លូវភេទ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ៣ (បី) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ៥០០.០០០ (ប្រាំសែន) រៀល ។

**មាត្រា ២៥១.–** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ ។

**មាត្រា ២៥២.–** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទល្មើសដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាង



Ksl

នៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៤-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៥-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី ២
## ការបរិហារកេរ្តិ៍ និងការជេរប្រមាថ

**មាត្រា ៣០៥.-** បទបរិហារកេរ្តិ៍ជាសាធារណៈ

គ្រប់ការអះអាងបំផ្លើស ឬ ការទំលាក់កំហុសដោយអសុទ្ធចិត្តលើអំពើណាមួយ ដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស ឬ កិត្តិស័ព្ទនៃបុគ្គល ឬ នៃស្ថាប័ន គឺជាការបរិហារកេរ្តិ៍ ។

ត្រូវពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល បទបរិហារកេរ្តិ៍ដែលប្រព្រឹត្តតាមមធ្យោបាយណាមួយ ដូចតទៅ :

១-តាមសំដី ទោះជាប្រភេទណាក៏ដោយដែលបញ្ចេញនៅទីសាធារណៈ ឬនៅក្នុងសាលប្រជុំសាធារណៈ ។

២-តាមលិខិត ឬគំនូរ ទោះជាប្រភេទណាក៏ដោយដែលផ្សព្វផ្សាយនៅក្នុងចំណោមសាធារណជន ឬ ដាក់តាំងឱ្យសាធារណជនមើល ។

៣-តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍សម្រាប់សាធារណជន ។

**មាត្រា ៣០៦.-** អំពើបរិហារកេរ្តិ៍តាមសារព័ត៌មាន

ការបរិហារកេរ្តិ៍ដែលប្រព្រឹត្តតាមសារព័ត៌មាន ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសារព័ត៌មាន ។

**មាត្រា ៣០៧.-** បទជេរប្រមាថជាសាធារណៈ

គ្រប់ពាក្យប្រមាថ គ្រប់ពាក្យមើលងាយ ឬ គ្រប់ពាក្យទ្រគោះ ដែលគ្មានការទំលាក់កំហុសលើអំពើណាមួយ គឺជាការជេរប្រមាថ ។



ksl

# គន្ថីទី ៣

# បទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិ

## មាតិកាទី ១

## ការយកទ្រព្យសម្បត្តិអ្នកដទៃមកធ្វើជាកម្មសិទ្ធិរបស់ខ្លួនដោយទុច្ចរិត

### ជំពូកទី ១

### ការលួច និងបទល្មើសប្រហាក់ប្រហែល

#### ផ្នែកទី ១

#### ការលួច

**មាត្រា ៣៥៣.–** និយមន័យនៃអំពើលួច

អំពើលួច គឺជាអំពើដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិ ឬ វត្ថុផ្សេងទៀតរបស់អ្នកដទៃ តាមគ្រប់មធ្យោបាយក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ។

**មាត្រា ៣៥៤.–** អំពើលួចថាមពល

ត្រូវចាត់ទុកជាអំពើលួច អំពើប្រើប្រាស់ដោយទុច្ចរិតនូវថាមពល ដែលនាំឱ្យខូចប្រយោជន៍អ្នកដទៃ ។

**មាត្រា ៣៥៥.–** អភ័យឯកសិទ្ធិគ្រួសារ

មិនអាចត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបានទេ :

១-អំពើលួចទ្រព្យសម្បត្តិរបស់បុព្វញាតិ ឬបច្ឆាញាតិ ។

២-អំពើលួចទ្រព្យសម្បត្តិរបស់សហព័ទ្ធ ។

**មាត្រា ៣៥៦.–** ទោសដែលត្រូវអនុវត្ត

អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៣៥៧.–** ស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា

អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ (បី) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ក្នុងករណី

## ជំពូកទី ២
## បទល្មើសប្រហាក់ប្រហែលនឹងការឆបោក

### កថាភាគទី ១
### ការទាញយកប្រយោជន៍ដោយរំលោភលើភាពទន់ខ្សោយ

**មាត្រា ៣៨៣.–** បទរំលោភលើភាពល្ងង់ខ្លៅ ឬ ភាពទន់ខ្សោយ

អំពើទាញយកប្រយោជន៍ដោយចេតនាដោយរំលោភលើភាពល្ងង់ខ្លៅ ឬ ភាពទន់ខ្សោយនៃបុគ្គលដែលបណ្តាលមកពីអាយុ ស្ថានភាពមានគភ៌ ជំងឺ ឬ ពិការភាព ដោយបង្ខំបុគ្គលនេះ ឱ្យប្រព្រឹត្តអំពើ ឬ មិនប្រព្រឹត្តអំពើដែលធ្វើឱ្យខូចប្រយោជន៍យ៉ាងធ្ងន់ធ្ងររបស់បុគ្គលនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

### កថាភាគទី ២
### ការបន្លំ

**មាត្រា ៣៨៤.–** បទបន្លំ

អំពើបន្លំ គឺជាអំពើរបស់បុគ្គលដែលដឹងខ្លួនថាគ្មានលទ្ធភាពដាច់ខាតនឹងបង់ថ្លៃ ឬ ដែលសម្រេចចិត្តមិនបង់ថ្លៃ :

១-ឱ្យគេបម្រើម្ហូបអាហារ ឬ ភេសជ្ជៈនៅក្នុងវង្គសាល ភោជនីយដ្ឋាន ឬ នៅក្នុងគ្រឹះស្ថានដទៃទៀត ដែលបើកចំហដល់សាធារណជន ។

២-ឱ្យគេប្រគល់បន្ទប់មួយ និងកាន់កាប់បន្ទប់នេះនៅក្នុងសណ្ឋាគារ ឬ គ្រឹះស្ថានដទៃទៀត ដែលបើកចំហដល់សាធារណជន ។

៣-ឱ្យគេដឹកជញ្ជូនខ្លួនតាមត្រីចក្រយាន តាមរថយន្តឈ្នួល ឬ តាមមធ្យោបាយដឹកជញ្ជូនផ្សេងទៀត ។

អំពើបន្លំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ៣ (បី) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ៥០០.០០០ (ប្រាំសែន) រៀល ។

**មាត្រា ៣៨៥.–** ការប៉ុនប៉ង

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិម ដែលមានចែងនៅក្នុងកថាភាគនេះ ត្រូវផ្តន្ទាទោសដូចបទមជ្ឈិមខាងលើដែរ ។

# ឧបសម្ព័ន្ធទី៣

# ក្រមនីតិវិធីព្រហ្មទណ្ឌ

# នៃ

# ព្រះរាជាណាចក្រកម្ពុជា

នស/រកម/០៨០៧/០២៤

# ព្រះរាជក្រម

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមនីតិវិធីព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៣ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

# គន្ថីទី ១

## បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី

## មាតិកាទី ១

## គោលការណ៍ទូទៅ

## ជំពូកតែមួយ

## គោលការណ៍ទូទៅ

**មាត្រា ១.** – គោលបំណងនៃក្រមនីតិវិធីព្រហ្មទណ្ឌ

ក្រមនីតិវិធីព្រហ្មទណ្ឌ មានគោលបំណងកំណត់អំពីវិធានទាំងឡាយដែលត្រូវគោរព និងប្រព្រឹត្តតាមដោយហ្មត់ចត់ ដើម្បីកំណត់ឱ្យច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយ ។

បទប្បញ្ញត្តិនៃក្រមនេះត្រូវយកទៅអនុវត្តចំពោះរឿងព្រហ្មទណ្ឌ កាលណាពុំមានវិធានដោយឡែកចែងដោយច្បាប់ពិសេសទេនោះ ។

**មាត្រា ២.** – បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី

បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណីគឺជាបណ្តឹងពីរផ្សេងគ្នា ។

បណ្តឹងអាជ្ញា មានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឱ្យឃើញពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននេះតាមច្បាប់កំណត់ ។

បណ្តឹងរដ្ឋប្បវេណី មានគោលបំណងធ្វើឱ្យបានជួសជុលការខូចខាតដែលបណ្តាលមកពីអំពើល្មើសដល់ភាគីរងគ្រោះ ហើយក្នុងគោលបំណងនេះ ឱ្យអ្នករងគ្រោះបានទទួលសំណងជម្ងឺចិត្តចំពោះល្មើស និងសំណងកម្មដែលខ្លួនបានទទួល ។

## មាតិកាទី ២

## បណ្តឹងអាជ្ញា

## ជំពូកតែមួយ

## បណ្តឹងអាជ្ញា

**មាត្រា ៣.** – កម្មវត្ថុនៃបណ្តឹងអាជ្ញា

បណ្តឹងអាជ្ញាអនុវត្តទៅលើបុគ្គលគ្រប់រូប ទាំងរូបវន្តបុគ្គល ទាំងនីតិបុគ្គល ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។

ប្រយុទ្ធប្រឆាំងនឹងការប្រកាន់ពូជសាសន៍ និងការរើសអើង) នៃក្រមនេះ បណ្ដឹងរបស់សមាគម អាចទទួលយកបាន លុះត្រាតែមានភស្តុតាងបញ្ជាក់ថា បានទទួលការយល់ព្រមអំពីសិទ្ធិពីជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់នៃជននេះ ។ ក្នុងករណីបៀតបៀនដល់អាយុជីវិត បណ្ដឹងរបស់សមាគមអាចទទួលយកបាន លុះត្រាតែសមាគមបានបង្ហាញភស្តុតាងបញ្ជាក់ថា បានទទួលការយល់ព្រមអំពីសិទ្ធិពីសិទ្ធិវន្តនៃជនរងគ្រោះ ។

**មាត្រា ២១.** – ចុងចម្លើយនៃបណ្ដឹងរដ្ឋប្បវេណី

បណ្ដឹងរដ្ឋប្បវេណី អាចធ្វើឡើងប្រឆាំងនឹងជនទាំងអស់ដែលត្រូវផ្ដល់សំណងជួសជុលការខូចខាតដែលបណ្ដាលមកពីបទល្មើសរួមមាន :

-ចារី សហចារីនៃបទល្មើស

-អ្នកផ្ដើមគំនិត អ្នកសមគំនិត

-អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ។

**មាត្រា ២២.** – ទំនាក់ទំនងសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌ និងតុលាការរដ្ឋប្បវេណី

បណ្ដឹងរដ្ឋប្បវេណី អាចធ្វើឡើងក្នុងពេលជាមួយគ្នានឹងបណ្ដឹងអាជ្ញា នៅចំពោះមុខសាលាជម្រះក្ដីព្រហ្មទណ្ឌ ។

បណ្ដឹងរដ្ឋប្បវេណីក៏អាចធ្វើបានផងដែរ នៅចំពោះមុខសាលាជម្រះក្ដីរដ្ឋប្បវេណី ។ ក្នុងករណីនេះ បណ្ដឹងរដ្ឋប្បវេណីអាចត្រូវព្យួរសិន ដរាបណាមិនទាន់មានសេចក្ដីសម្រេចជាស្ថាពរមួយត្រូវបានប្រកាសលើបណ្ដឹងអាជ្ញា ។

**មាត្រា ២៣.** – ការប្រកាសជាមុនអំពីពិរុទ្ធភាព

តុលាការព្រហ្មទណ្ឌនឹងអាចសម្រេចការជួសជុលការខូចខាតបាន លុះត្រាតែបានពិនិត្យជាមុនអំពីបាតុភូតនៃបទល្មើសព្រហ្មទណ្ឌ ហើយបានប្រកាសថា ជនជាប់ចោទត្រូវមានពិរុទ្ធជាមុនសិន ។

**មាត្រា ២៤.** – មរណភាពរបស់ជនជាប់ចោទ

ដើមបណ្ដឹងរដ្ឋប្បវេណី អាចសុំឱ្យមានការជួសជុលការខូចខាតពីសិទ្ធិវន្តនៃជនជាប់ចោទបានប្រសិនបើជនជាប់ចោទនេះ ទទួលមរណភាពនៅក្នុងពេលដំណើរការរឿងក្ដីព្រហ្មទណ្ឌ ។ ថ្វីត្បិតតែបណ្ដឹងអាជ្ញាត្រូវរលត់ តុលាការព្រហ្មទណ្ឌនៅតែមានសមត្ថកិច្ចដើម្បីសម្រេចលើបណ្ដឹងរដ្ឋប្បវេណីដែលធ្វើឡើងប្រឆាំងនឹងសិទ្ធិវន្តទាំងនោះ ។

**មាត្រា ២៥.** – ការលះបង់ និងការដកពាក្យប្ដឹងរបស់ជនរងគ្រោះ

ដោយត្រូវបញ្ជូននូវព័ត៌មាន កំណត់ហេតុ លិខិត និងវត្ថុតាងទាំងអស់ ដែលទាក់ទងនឹងបទល្មើសនោះ ភ្ជាប់ជាមួយផង ។

មិនអាចមានការលើកលែងផ្សេងណា ក្រៅពីការលើកលែងស្តីអំពីអាជីវកម្មខាងវិជ្ជាជីវៈក្នុងករណីដែលច្បាប់បានចែងយ៉ាងជាក់លាក់នោះទេ ។

**មាត្រា ៤៣.** – ការចោទប្រកាន់

ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌអាចធ្វើតាម :

-ការបើកធ្វើការស៊ើបសួរ

-ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬ

-តាមនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ។

**មាត្រា ៤៤.** – ការបើកការស៊ើបសួរ

ក្នុងករណីបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ ។

ការស៊ើបសួរត្រូវបានបើក តាមដីកាបញ្ជូនរឿងឱ្យស៊ើបសួរដែលត្រូវប្តឹងទៅចៅក្រមស៊ើបសួរ ។ ការស៊ើបសួរ អាចបើកប្រឆាំងលើ បុគ្គលម្នាក់ ឬច្រើននាក់ ដោយមានចង្អុលប្រាប់ឈ្មោះ ឬប្រឆាំងទៅលើអញ្ញាតជន ។

ដីកាបញ្ជូនរឿងឱ្យស៊ើបសួររួមមាន :

-សេចក្តីសង្ខេបនៃអង្គហេតុ

-ការកំណត់ឈ្មោះបទល្មើស

-ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស និង

-ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន ។

ដីកាបញ្ជូនរឿងឱ្យស៊ើបសួរត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា ។

ទម្រង់ការនេះមានលក្ខណៈដាច់ខាតត្រូវតែគោរព បើពុំដូច្នេះទេ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរនេះ ត្រូវទុកជាមោឃៈ ។

**មាត្រា ៤៥.** – ការចោទប្រកាន់ក្នុងករណីបទមជ្ឈិម

ក្នុងករណីបទមជ្ឈិម ព្រះរាជអាជ្ញាអាច :

-បើកការស៊ើបសួរដោយធ្វើដូចដែលបានចែងដោយមាត្រា ៤៤ (ការបើកការស៊ើបសួរ) នៃក្រមនេះ

-បញ្ជូនជនជាប់ចោទទៅជំនុំជម្រះផ្ទាល់នៅមុខតុលាការជាន់ដំបូង ដោយធ្វើដូចបាន

ចែងនៅក្នុងមាត្រា ៤៦ (ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់) នៃក្រមនេះ ឬ

-បង្គាប់ឱ្យនាំជនជាប់ចោទចូលបង្ហាញខ្លួនភ្លាមនៅមុខតុលាការជាន់ដំបូង ដោយធ្វើដូចដែលបានចែងក្នុងមាត្រា ៤៧ (ការបង្ហាញខ្លួនភ្លាម) និងមាត្រា ៤៨ (នីតិវិធីនៃការបង្ហាញខ្លួនភ្លាម) នៃក្រមនេះ ។

**មាត្រា ៤៦.** – ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺជាបញ្ជាឱ្យជនជាប់ចោទចូលទៅបង្ហាញខ្លួននៅមុខតុលាការជាន់ដំបូង ។ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់រួមមាន :

-អត្តសញ្ញាណនៃជនជាប់ចោទ

-សេចក្តីសង្ខេបនៃអង្គហេតុ

-ឈ្មោះបទល្មើស

-អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស ។

ដីកានេះត្រូវចង្អុលប្រាប់ពីតុលាការ ព្រមទាំងទីកន្លែង កាលបរិច្ឆេទ និងម៉ោងពេលនៃសវនាការ ។ ដីកានេះត្រូវបញ្ជាក់ថា ជនជាប់ចោទអាចពឹងមេធាវីឱ្យអមខ្លួនបាន ។

**មាត្រា ៤៧.** – ការបង្ហាញខ្លួនភ្លាម

ព្រះរាជអាជ្ញាអាចបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទចូលបង្ហាញខ្លួនភ្លាមនៅមុខតុលាការជាន់ដំបូង ប្រសិនបើមានគ្រប់លក្ខខណ្ឌដូចតទៅ :

-បទល្មើសជាបទល្មើសជាក់ស្តែង តាមអត្ថន័យនៃមាត្រា ៨៦ (និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) និងមាត្រា ៨៨ (ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង) នៃក្រមនេះ

-បទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច ១ (មួយ) ឆ្នាំ និងយ៉ាងច្រើន ៥ (ប្រាំ) ឆ្នាំ

-ជនជាប់ចោទជានីតិជន

-រឿងក្តីមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបាន ។

**មាត្រា ៤៨.** – នីតិវិធីនៃការបង្ហាញខ្លួនភ្លាម

កាលណាសម្រេចថា ត្រូវប្រើនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ព្រះរាជអាជ្ញាត្រូវ :

-ពិនិត្យអត្តសញ្ញាណបុគ្គលដែលគេបញ្ជូនមកឱ្យខ្លួន

-ឱ្យដំណឹងដល់ជននោះ អំពីរឿងរ៉ាវដែលចោទប្រកាន់ និងឈ្មោះបទល្មើស

ដោះលែងឱ្យមានសេរីភាពវិញដោយឯកឯង ។

**មាត្រា ៤៩.** – នីតិវិធីកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ក្នុងករណីបទលហុ

ប្រសិនបើរឿងនោះជាបទលហុ ព្រះរាជអាជ្ញាត្រូវកោះជនជាប់ចោទឱ្យចូលខ្លួនទៅមុខតុលាការជំនុំជម្រះដោយផ្ទាល់ ដូចបានចែងនៅក្នុងមាត្រា ៤៦ (នីតិវិធីកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់) នៃក្រមនេះ ។

**មាត្រា ៥០.** – បញ្ជីនៃពាក្យប្តឹង

នៅតាមតុលាការជាន់ដំបូងនីមួយៗ ត្រូវបង្កើតឱ្យមានបញ្ជីអយ្យការមួយសម្រាប់ចុះបណ្តឹងដែលប្តឹងដោយផ្ទាល់ដល់ព្រះរាជអាជ្ញា ឬដែលបញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌ ។

គ្រប់បណ្តឹងទាំងអស់ត្រូវតែចុះក្នុងបញ្ជីដោយមានខ្លឹមសារដូចតទៅ :

-អត្តសញ្ញាណរបស់អ្នកប្តឹង

-កាលបរិច្ឆេទដែលអយ្យការបានទទួលពាក្យប្តឹង

-ប្រភពនៃបណ្តឹង : បណ្តឹងផ្ញើមកផ្ទាល់ចំពោះព្រះរាជអាជ្ញា ឬក៏បញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌

-ប្រភេទនៃរឿងហេតុដែលអ្នកប្តឹងបានរាយការណ៍

-ចំណាត់ការលើពាក្យប្តឹង : ការសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ។

បញ្ជីនៃពាក្យប្តឹងត្រូវកាន់កាប់ដោយលេខាធិការរបស់អយ្យការ ក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញា ។ បញ្ជីអាចត្រូវបានបើកមើលដោយអាជ្ញាធរតុលាការទាំងអស់ ជាអាទិ៍គឺអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

## មាតិកាទី ២
## ចៅក្រមស៊ើបសួរ
## ជំពូកទោល
## ចៅក្រមស៊ើបសួរ

**មាត្រា ៥១.** – ការចាត់តាំងដោយប្រធានតុលាការ

កាលណាចៅក្រមស៊ើបសួរណាម្នាក់ ពុំអាចបំពេញមុខងាររបស់ខ្លួនបានទេ ដោយសារការឈប់សម្រាក ដោយមានជំងឺ ឬដោយមានមូលហេតុឯទៀតផ្សេងទៀត ចៅក្រមស៊ើបសួរផ្សេងទៀត

ក្នុងករណីដែលមានការចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋប្រល័យពូជសាសន៍ ឬបទឧក្រិដ្ឋសង្គ្រាម ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ១ (មួយ) ឆ្នាំបានទេ ចំពោះបទល្មើសនីមួយៗ ។ ប៉ុន្តែ នៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួនបណ្ដោះអាសន្នម្ដងបាន ១ (មួយ) ឆ្នាំ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់ ។

ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យពន្យារការឃុំខ្លួនបណ្ដោះអាសន្ននេះបានតែ ២ (ពីរ) ដងគត់ ។

**មាត្រា ២១១.** – ការពន្យារពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន

កាលណាចៅក្រមស៊ើបសួរសម្រេចថាពន្យារពេលឃុំខ្លួនជាបណ្ដោះអាសន្ន ចៅក្រមស៊ើបសួរត្រូវឱ្យដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សំគាល់របស់ជននេះ ។ កាលណាជនត្រូវចោទមានមេធាវីអមនោះ មេធាវីត្រូវបង្ហាញមធ្យោបាយការពារខ្លួនកូនក្ដីរបស់ខ្លួន ។

ចៅក្រមស៊ើបសួរពន្យារការឃុំខ្លួនបណ្ដោះអាសន្ន តាមដីកាដោយមានសំអាងហេតុ ។ នៅក្នុងដីកានេះ ចៅក្រមស៊ើបសួរត្រូវយោងទៅតាមបទប្បញ្ញត្តិនៃមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន) នៃក្រមនេះ ។ ដីកានេះត្រូវឱ្យដំណឹងជាបន្ទាន់ដល់ជនត្រូវចោទ ។

**មាត្រា ២១២.** – សេចក្ដីសម្រេចទាក់ទងនឹងអនីតិជនមានអាយុតិចជាង ១៤ (ដប់បួន) ឆ្នាំ

អនីតិជនអាយុតិចជាង ១៤ (ដប់បួន) ឆ្នាំ មិនអាចត្រូវឃុំខ្លួនបណ្ដោះអាសន្នទេ ។ ចៅក្រមស៊ើបសួរអាចសម្រេចប្រគល់អនីតិជននេះឱ្យឪពុកម្ដាយ អ្នកអាណាព្យាបាល ឬក្នុងករណីគ្មានអ្នកអាណាព្យាបាល ត្រូវប្រគល់ទៅមជ្ឈមណ្ឌលអប់រំថែរក្សាបណ្ដោះអាសន្ន រង់ចាំសេចក្ដីសម្រេចរបស់តុលាការ ។

**មាត្រា ២១៣.** – ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទឧក្រិដ្ឋទាក់ទងនឹងអនីតិជន មានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ

ចំពោះអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ និងត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋ ថិរវេលាឃុំខ្លួនបណ្ដោះអាសន្នមានដូចតទៅ :

១-ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ (បួន) ខែ បានទេ កាលណាអនីតិជននេះមានអាយុតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ ។

២-ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៦ (ប្រាំមួយ) ខែ បានទេ កាលណាអនីតិជននេះមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។

**មាត្រា ២១៤.** – ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ក្នុងបទមជ្ឈិមទាក់ទងនឹងអនីតិជន មានអាយុ

ចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ

ចំពោះអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ និង ត្រូវចោទប្រកាន់ពីបទមជ្ឈិម ចិរវេលាឃុំខ្លួនបណ្ដោះអាសន្នមានដូចតទៅ :

១-ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ២ (ពីរ) ខែ បានទេ កាលណាអនីតិជននេះមានអាយុតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ ។

២-ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ (បួន) ខែ បានទេ កាលណាអនីតិជននេះមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។

ចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នតាមចំណុចទី ១ និងចំណុចទី ២ ខាងលើនេះ មិនត្រូវលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់សម្រាប់អនីតិជននោះឡើយ ។

**មាត្រា ២១៥.** – ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំដោយចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំវិញបានគ្រប់ពេលវេលា ។

កាលណាចៅក្រមស៊ើបសួរមានបំណងដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំនោះ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញាដើម្បីសុំយោបល់ ហើយបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យ ។ ព្រះរាជអាជ្ញាត្រូវផ្ដល់យោបល់របស់ខ្លួនក្នុងរយៈពេលយ៉ាងខ្លីបំផុត ។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ។

ក្នុងករណីបន្ទាន់ចៅក្រមស៊ើបសួរ អាចបង្គាប់ឱ្យដោះលែងជនត្រូវចោទភ្លាម ដោយមិនរង់ចាំយោបល់របស់ព្រះរាជអាជ្ញា ។ ចៅក្រមស៊ើបសួរត្រូវចង្អុលប្រាប់មូលហេតុនៃការបន្ទាន់នេះនៅក្នុងដីកាសម្រេចរបស់ខ្លួន ។

**មាត្រា ២១៦.** – ការដោះលែងឱ្យនៅក្រៅឃុំ តាមបណ្ដឹងរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាអាចសុំឱ្យដោះលែងជនត្រូវចោទបានគ្រប់ពេលវេលា ។ ចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ។

ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញាអាចប្ដឹងសុំតាមរយៈពាក្យសុំទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ ។

ដីកាដែលសម្រេចមិនព្រមដោះលែងត្រូវមានសំអាងហេតុ ។

**មាត្រា ២១៧.** – ការដោះលែងឱ្យនៅក្រៅឃុំ តាមបណ្ដឹងរបស់ជនត្រូវចោទ

ជនត្រូវចោទអាចដាក់ពាក្យសុំឱ្យដោះលែងនៅក្រៅឃុំបានគ្រប់ពេលវេលា ។ ចៅក្រមស៊ើបសួរបញ្ជូនពាក្យនោះភ្លាមទៅព្រះរាជអាជ្ញា ដើម្បីផ្ដល់យោបល់ និងបញ្ជូនសំណុំរឿងទៅ

# ឧបសម្ព័ន្ធទី៤

# ច្បាប់

## ស្តីពី

# យុត្តិធម៌អនីតិជន

ROYAUME DU CAMBODGE
MINISTRE DU PALAIS ROYAL

២/៣៩

# ព្រះរាជក្រម

នស/រកម/០៧១៦/០០៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ហរោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

## មាត្រា ៦.- សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី

អនីតិជនគ្រប់រូបដែលជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថាបានប្រព្រឹត្តបទល្មើសត្រូវទទួលបាននូវសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធីដូចតទៅ ៖

- សិទ្ធិមិនផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី
- សិទ្ធិមិនទទួលការបង្ខិតបង្ខំឲ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង
- សិទ្ធិរក្សាការសម្ងាត់នៃជីវិតឯកជន
- សិទ្ធិទទួលបានការពិនិត្យសុខភាព និងការព្យាបាល
- សិទ្ធិទទួលបានការឲ្យដំណឹងអំពីបទចោទប្រកាន់
- សិទ្ធិក្នុងការជូនដំណឹងអំពីការចាប់ខ្លួនទៅដល់អ្នកតំណាងដែលច្បាប់បានកំណត់
- សិទ្ធិទទួលបានជំនួយពីមេធាវីដោយការជ្រើសរើស ឬដោយការចាត់តាំងដោយមិនយកកម្រៃ ស្របតាមលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ចាប់តាំងពីដំណាក់កាលដំបូងបំផុតនៃនីតិវិធី
- សិទ្ធិឲ្យមានការចូលរួមពីអ្នកតំណាងដែលច្បាប់បានកំណត់នៅគ្រប់ដំណើរការរឿងក្តី ប្រសិនបើការចូលរួមនេះមិនផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន
- សិទ្ធិទទួលបានជំនួយពីអ្នកបកប្រែភាសាដោយមិនយកកម្រៃ កាលបើមានការចាំបាច់
- សិទ្ធិបង្ហាញភស្តុតាង
- សិទ្ធិស្នើសុំឲ្យកោះហៅសាក្សី និងសួរសាក្សី
- សិទ្ធិស្នើសុំអនុញ្ញាតនៅក្រៅឃុំ
- សិទ្ធិស្នើសុំឲ្យកែប្រែវិធានការត្រួតពិនិត្យតាមផ្លូវតុលាការ
- សិទ្ធិទំនាក់ទំនងជាមួយស្ថានទូត ស្ថានកុងស៊ុល ក្នុងករណីអនីតិជនជាជនបរទេស
- សិទ្ធិផ្សេងៗទៀតដែលមានចែងនៅក្នុងបទដ្ឋានគតិយុត្តជាធរមាន ។

# ជំពូកទី ៣

# ការទទួលខុសត្រូវព្រហ្មទណ្ឌ និងរដ្ឋប្បវេណីរបស់អនីតិជន

## មាត្រា ៧.- ការទទួលខុសត្រូវព្រហ្មទណ្ឌ

នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់ចាប់ពីអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ ។ ប៉ុន្តែ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ លើកលែងតែករណីមានចែងពិសេសនៅក្នុងច្បាប់ផ្សេងទៀត ។